

Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# កម្រងរឿងរ៉ាវរបស់
# ដើមបណ្តឹងរដ្ឋប្បវេណី
# នៅចំពោះមុខ
# អង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

## The stories from **Civil Parties participating** in the **Extraordinary Chambers in the Courts of Cambodia**

2014

# គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

ផ្ទះលេខ៩ Eo ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
**ទូរស័ព្ទលេខ:** (៨៥៥) ០២៣ ៣០១ ៤១៥
**ទូរសារ:** (៨៥៥) ០២៣ ២១៨ ៧៥៩
**អ៊ីម៉ែល:** chracsecretariat@yahoo.com
**គេហទំព័រ:** www.chrac.org

**ប្រធានលេខាធិការដ្ឋាន:** លោក សួន ប៊ុនស័ក្តិ
**ក្រុមការងារ:** លោកស្រី ឡាច ស្រីទូច, លោក ហ៊ុន ស៊ាងហាក់, លោក ប៊ីលី ជាលុងតៃ, កញ្ញា លីនដា ប៊េញខេ និង កញ្ញា មេឌីលីន ហ្សូលី
**អ្នកបកប្រែ:** លោកស្រី ឡាច ស្រីទូច
**រចនាសៀវភៅ:** លោក ព្រុំ រតនា
**គំនូរដោយ:** លោក មឿន ច័ន្ទសុខា និង លោក វ៉ាន់ ណាត
**បោះពុម្ពដោយ:** រោងពុម្ពអន្តរជាតិ

គម្រោងនេះ ត្រូវបានឧបត្ថមមូលនិធិដោយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ)

©រក្សាសិទ្ធិគ្រប់យ៉ាងឆ្នាំ២០១៤ ដោយគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង មិនមានផ្នែកណាមួយនៃសៀវភៅនេះ ឬខ្លឹមសារទាំងស្រុង ត្រូវបានយកទៅផលិតឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ រួមមាន ការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរពីគណៈកម្មាធិការប្រព្រឹត្តិកម្មបានឡើយ។

សៀវភៅនេះ គឺជាគម្រោងមិនយកកម្រៃមួយ សម្រាប់ជូនដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ហាមដាក់លក់ ឬចែកចាយសម្រាប់គោលបំណងពាណិជ្ជកម្ម។

# CAMBODIAN HUMAN RIGHTS ACTION COMMITTEE (CHRAC)

No. 9 Eo, Street 330, Boeung Keng Kang III, Chamcar Mon, Phnom Penh, Cambodia
**Telephone:** +855 (0)23 301 415
**Fax:** +855 (0)23 218 759
**Email:** chracsecretariat@yahoo.com
**Website:** www.chrac.org

**Editors:** Ms. Lach Sreytouch, Mr. Hun Seang Hak, Mr. Billy Chia-Lung Tai, Ms. Linda Behnke, Ms. Madeline Zulli
**Translator:** Ms. Lach Sreytouch
**Layout Designer:** Prum Ratana
**Artwork:** Mr. Moeun Chan Sokha and Mr. Vann Nath

Printed in Cambodia: International Printing House, Phnom Penh, Cambodia

Funding for this project was generously provided by Deutsche Gesellschaft für internationale Zusammenarbeit (GIZ) GmbH.

Copyright © 2014 by the Cambodian Human Rights Action Committee

All rights reserved. This book may not be reproduced in part or in whole, utilized in any form or by any means, electronic or mechanical, including photocopying, recording, or any information storage and retrieval system, without permission in writing from the Cambodian Human Rights Action Committee.

This book is a non-for-profit project dedicated to the Civil Parties participating in the Extraordinary Chambers in the Courts of Cambodia and may not be sold or otherwise distributed for commercial purposes.

# កម្រងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី
# នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

The stories from **Civil Parties participating** in the **Extraordinary Chambers in the Courts of Cambodia**

2014

# មាតិកា


- **អារម្ភកថា** ........ ៨

**១ សេចក្តីផ្តើម** ........ ១០

**២ ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ........ ១២
- ឧក្រិដ្ឋកម្ម និងសំណុំរឿង ........ ១២
- លក្ខណៈពិសេស នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ ១២
- កំណត់សម្គាល់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងចំពោះមុខ អ.វ.ត.ក ........ ១៦

**៣ ប្រវត្តិរឿងរ៉ាវសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹង ការជម្លៀសដោយបង្ខំ និងឧក្រិដ្ឋកម្មផ្សេងៗទៀត** ........ ២២
- *១/ ការចូលមកដល់នៃទ័ពខ្មែរក្រហម និងការជម្លៀសដោយបង្ខំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥* ........ *២៤*
  - លោក មាស សារ៉ាន់ ........ ២៦
  - លោកស្រី ពេជ ស្រីផល ........ ២៨
  - លោក គឹម វ៉ាន់ឌី ........ ៣០
  - លោកស្រី អោ រី ........ ៣២
- *២/ ការបង្ខំឲ្យធ្វើការ* ........ *៣៤*
  - លោកស្រី ឱម ចន្ថា ........ ៣៦
  - លោកស្រី ឈឹម វណ្ណា ........ ៣៨
  - លោកស្រី ហួរ ចន្ថា ........ ៤០
  - លោក ជុំ សុខា ........ ៤២
  - លោក សឿន សុវណ្ណី ........ ៤៤
- *៣/ ការជម្លៀសដោយបង្ខំដំណាក់កាលទីពីរ* ........ *៤៦*
  - លោកស្រី សូផាន់ សូវណ្ណី ........ ៤៨
  - លោកស្រី យឹម សុវណ្ណា ........ ៥០
  - លោកស្រី ឈិន ណារី ........ ៥២
  - លោក សាយ កាណាល់ ........ ៥៤
  - លោកស្រី តាន់ ស៊ីតា ........ ៥៦
- *៤/ ការបង្ខំកុមារឲ្យធ្វើការ* ........ *៥៨*
  - លោកស្រី សេង ស៊ីវត្ថា ........ ៦០
  - លោក អូន ផល្លី ........ ៦២
  - លោកស្រី ចាន់ សុជាតិ ........ ៦៤
  - លោក យិន រំដួល ........ ៦៦
- *៥/ ការដាក់គុក និងធ្វើទារុណកម្ម* ........ *៧០*
  - លោកស្រី ឡាយ បូនី ........ ៧២
  - លោក ស៊ុំ រិទ្ធី ........ ៧៤
  - លោក ណុប អឿន ........ ៧៦
  - លោក ជុំ មុី ........ ៧៨
- *៦/ អាពាហ៍ពិពាហ៍ដោយបង្ខំ* ........ *៨០*
  - លោក អ៊ុម ប៊ុនឈឿន ........ ៨២
  - លោកស្រី ឡាយ គឹមឈាន ........ ៨៤
  - លោកអ៊ុំ ស៊ូ សុទ្ធារី ........ ៨៦
- *៧/ ការបង្អត់អាហារ* ........ *៨៨*
  - លោកស្រី ទឹង សុខា ........ ៩០
  - លោកស្រី ប៉ែ សុផានី ........ ៩២
  - លោកស្រី ប៉ូ ឌីណា ........ ៩៤
  - លោក ចៅ នី ........ ៩៦

- **ប្រភពឯកសារ** ........ ៩៩

# TABLE OF CONTENTS


- **PREFACE ... 9**
- **1 INTRODUCTION ... 11**
- **2 CIVIL PARTIES BEFORE THE EXTRAORDINARY CHAMBERS IN THE COURTS OF CAMBODIA ... 13**
  - The Crimes and the Cases ... 13
  - Key Features of Civil Party Participation ... 13
  - Highlights of Civil Party Participation in Cases Before the ECCC ... 16
- **3 BRIEF STORY OF CIVIL PARTIES RELATED TO FORCED TRANSFER AND OTHER CRIMES ... 23**
  - *Chapter 1: Arrival of Khmer Rouge / Forced Transfer on 17 April 1975 ... 25*
    - Mr. Meas Saran ... 27
    - Mrs. Pech Srey Phal ... 29
    - Mr. Kim Vanndy ... 31
    - Mrs. Or Ry ... 33
  - *Chapter 2: Forced Labor ... 34*
    - Mrs. Om Chantha ... 37
    - Mrs. Chhim Vanna ... 39
    - Mrs. Hour Chantha ... 41
    - Mr. Chum Sokha ... 43
    - Mr. Soeun Sovandy ... 45
  - *Chapter 3: Forced Transfer Phase Two ... 46*
    - Mrs. Sophan Sovandy ... 49
    - Mrs. Yim Sovann ... 51
    - Mrs. Chhin Navy ... 53
    - Mr. Say Kanal ... 55
    - Mrs. Tann Sita ... 57
  - *Chapter 4: Child Forced Labor ... 58*
    - Mrs. Seng Sivutha ... 61
    - Mr. Aun Phally ... 63
    - Mrs. Chan Socheat ... 65
    - Mr. Yin Romduol ... 67
  - Chapter 5: Imprisonment and Torture ... 70
    - Mrs. Lay Bony ... 73
    - Mr. Soum Rithy ... 75
    - Mr. Nob Oeun ... 77
    - Mr. Chum Mey ... 79
  - Chapter 6: Forced Marriage ... 80
    - Mr. Im Bun Chhoeun ... 83
    - Mrs. Lay Kim Chhean ... 85
    - Ms. Sou Sotheavy ... 87
  - Chapter 7: Starvation ... .88
    - Mrs. Ting Sokha ... 91
    - Mrs. Bay Sophany ... 93
    - Mrs. Po Dina ... 95
    - Mr. Chau Ny ... 97
- **Reference Sources ... 99**

# អារម្ភកថា



*លោក **សុក សំអឿន***
*ប្រធានសម្របសម្រួលគណៈ*
*កម្មាធិការប្រព្រឹត្តិកម្ម*

សម្រាប់ប្រជាជនកម្ពុជា និងនៅក្នុងទំព័រប្រវត្តិសាស្រ្តកម្ពុជា គឺពិតជាមិនអាចបំភ្លេចបានទេនូវទំព័រប្រវត្តិសាស្រ្តដ៏ជូរចត់មួយ គឺ *"របបកម្ពុជាប្រជាធិបតេយ្យ"* ដែលគ្រប់គ្រងដោយពួកខ្មែរក្រហម ហើយដែលអ្នកដែលបានឆ្លងកាត់របបនេះតែងតែហៅថា *"របបខ្មែរក្រហម"*។ របបនេះបានឡើងកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវបានផ្តួលរលំនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ របបនេះ បានធ្វើឲ្យប្រជាជនប្រមាណ ១.៧ ទៅ ២.២លាននាក់បានបាត់បង់ជីវិត។ បន្ទាប់ពីរបបខ្មែរក្រហមបានផុតរលត់ទៅ សង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជានៅតែបន្តកើតមាន ហើយសង្គ្រាមស៊ីវិលនេះបានត្រូវបញ្ចប់នៅឆ្នាំ១៩៩៨ គឺដោយសារតែរចនាសម្ព័ន្ធនយោបាយ និងយោធារបស់ខ្មែរក្រហមបានត្រូវកម្ទេចចោលទាំងស្រុង។

រហូតមកទល់ពេលនេះ ប្រវត្តិរឿងរ៉ាវដ៏ជូរចត់ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងអំឡុងរបបខ្មែរក្រហមនៅតែត្រូវបាននិយាយប្រាប់ដោយអ្នកជំនាន់មុនទៅអ្នកជំនាន់ក្រោយ តាមរយៈការនិយាយប្រាប់ដោយផ្ទាល់ពីអ្នកដែលបានឆ្លងកាត់របបដោយផ្ទាល់ ឬតាមរយៈកម្រងឯកសារនានា។ សៀវភៅរឿងរ៉ាវនេះ ត្រូវបានផលិតឡើងដើម្បីបន្តរក្សាទុកនូវប្រវត្តិរឿងរ៉ាវពិតរបស់អ្នកដែលនៅរស់រានមានជីវិតក្នុងរបបខ្មែរក្រហមឲ្យនៅតែរស់រវើកជានិច្ច ហើយក៏ជាការរួមចំណែកលើកទឹកចិត្តដល់ជនរងគ្រោះទាំងឡាយក្នុងការចូលរួមចែករំលែកបទពិសោធន៍របស់ខ្លួនផងដែរ។

តាមរយៈសៀវភៅនេះ ខ្ញុំជឿជាក់ថាអ្នកជំនាន់ក្រោយរបស់កម្ពុជាពិតជាបានទទួលនូវការយល់ដឹងបន្ថែមពីឆាកជីវិតពិតរបស់ប្រជាជននៅក្នុងអំឡុងរបបខ្មែរក្រហម ដែលទាក់ទិននឹងការបង្ខំឲ្យចាក់ចេញពីផ្ទះសំបែង ការបាត់បង់សាច់ញាតិការបង្ខំឲ្យធ្វើការ ការដាក់ឲ្យទៅជាអ្នកទោស ការបង្អត់អាហារ ការរំលោភបំពានផ្លូវភេទ។ល។

ជាចុងក្រោយ ខ្ញុំជឿជាក់ថា សៀវភៅរឿងរ៉ាវនិងសក្ខីកម្មសង្ខេបនេះ នឹងចូលរួមរក្សាទុកនូវការចងចាំរបស់ជនរងគ្រោះសម្រាប់កូនចៅជំនាន់ក្រោយរបស់ពួកគេបានយល់ដឹងតៗគ្នា។

ភ្នំពេញ, ខែមីនា ឆ្នាំ២០១៤



**សុក សំអឿន**

# PREFACE

***Mr. Sok Samoeurn***
*Chairperson of Cambodian Human Rights Action Committee*

For the Cambodian people, *"Democratic Kampuchea"* or the *"Khmer Rouge regime"* represents a bitter and dark chapter in the country's history. Under the control of the Khmer Rouge, 1.7 to 2.2 million lives were lost between 17 April 1975 and 6 January 1979 through inhuman acts perpetrated by the Khmer Rouge Regime. The civil war continued to ravage through Cambodia after the fall of the regime until 1998 when the political and military structure of the Khmer Rouge came to a complete end.

The bitter stories of the Cambodian people who lived through the Khmer Rouge regime have been passed down from the older generation to the younger generation through words of mouth and through the dissemination of the few documents that remain. This storybook has been produced to preserve the true stories of Khmer Rouge survivors, so that their stories are not lost to future generations. We also hope that through this project, we can encourage other survivors to share their experiences as well.

I believe this book will allow the younger generation of Cambodians to gain more knowledge and understanding of life under the Khmer Rouge regime; including forced transfer from home, loss of relatives, forced labor, being imprisoned, starvation, sexual violence, etc.

Finally, I believe that this storybook with its brief testimonies will play a role in preserving the memories of the survivors for the knowledge of their next generation.

Phnom Penh, March 2014

**Sok Samoeurn**

# ១ សេចក្តីផ្តើម

សៀវភៅនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសមាជិកចំនួន២១ ដែលកំពុងធ្វើការក្នុងវិស័យលើកស្ទួយសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋនិងសន្តិភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សៀវភៅកម្រងរឿងរ៉ាវដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវបានកែសម្រួលពីសៀវភៅដើមដែលមានចំណងជើងថា *"កម្រងរឿងរ៉ាវ និងសក្ខីកម្មសង្ខេបរបស់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ នៅសាលាក្តីខ្មែរក្រហម"* ដែលគណៈកម្មាធិការប្រព្រឹត្តិកម្មបានបោះពុម្ពផ្សាយកាលពីខែមិថុនា ឆ្នាំ២០១៣។ ការកែសម្រួលនេះ បានបញ្ចូលបន្ថែមនូវរឿងរ៉ាវដើមបណ្តឹងរដ្ឋប្បវេណីថ្មីមួយចំនួនទៀត ជាមួយនឹងគំនូរដែលបង្ហាញអំពីទិដ្ឋភាពមួយចំនួនដែលបានកើតឡើងនាពេលនោះ។

សៀវភៅនេះ ត្រូវបានចងក្រងឡើងដើម្បីជាផលប្រយោជន៍នៃការចូលរួមថែរក្សានូវរឿងរ៉ាវ ប្រវត្តិសាស្ត្រដែលបានឆ្លងកាត់ដោយជនរងគ្រោះ ដែលជាអ្នកធ្លាប់បានរស់ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហៅកាត់ថា *"របបខ្មែរក្រហម"*។ អត្ថបទដែលមាននៅក្នុងសៀវភៅនេះ គឺជាការចងក្រងនូវរឿងរ៉ាវពិតរបស់ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ហៅកាត់ថា"សាលាក្តីខ្មែរក្រហម"។ ខ្លឹមសាររឿងទាំងអស់នេះ គឺត្រូវបានដកស្រង់ចេញមកពីទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងសក្ខីកម្មរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ។ ក្រុមការងារចងក្រងប្រវត្តិរឿងរ៉ាវនៃគណៈកម្មាធិការប្រព្រឹត្តិកម្ម បានជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដែលកំពុងធ្វើវិភាគទាននូវរឿងរ៉ាវរបស់ខ្លួនដើម្បីទទួលបានការយល់ព្រមពីពួកគាត់សម្រាប់ការបោះពុម្ពផ្សាយ និងដើម្បីពិនិត្យឡើងវិញនូវរាល់ខ្លឹមសារនៃអត្ថបទរឿងរបស់ពួកគាត់។ ដំណើរការនេះ មានបំណងដើម្បីធានាអត្ថបទរឿងទាំងអស់ គឺត្រឹមត្រូវ និងពិតប្រាកដ។

ក្នុងអំឡុងដំណាក់កាលបិទបញ្ចប់នៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ គណៈកម្មាធិការប្រព្រឹត្តិកម្ម បានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីទទួលស្គាល់សៀវភៅនេះជាគម្រោងសំណងតាមផ្លូវតុលាការ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមានទោស។ ដោយសារសៀវភៅ នេះនឹងត្រូវបានបោះពុម្ពមុនអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមសម្រាប់សំណុំរឿង០០២/០១ យើងមិនដឹងថាតើសៀវភៅនេះនឹងក្លាយទៅជាគម្រោងសំណងមួយតាមផ្លូវតុលាការ ឬយ៉ាងណានោះទេ។ ជាលទ្ធផល គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមឧទ្ទិសសៀវភៅនេះជូនដល់ដួងវិញ្ញាក្ខន្ធនៃក្រុមគ្រួសារសាច់ញាតិរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់។ សូមឲ្យសៀវភៅនេះ ជួយគាំទ្រដល់ពួកគាត់ក្នុងការដោះស្រាយជាមួយអតីតកាលដែលប៉ះទង្គិចផ្លូវចិត្តរបស់ខ្លួន និងផ្តល់ជាកំណត់ត្រាមួយសម្រាប់ប្រជាជនកម្ពុជាជំនាន់ក្រោយដើម្បីសិក្សាស្វែងយល់។

យើងជឿជាក់ពីសារៈសំខាន់ គឺថាអំពើឃោរឃៅយង់ឃ្នងនានាដែលបានប្រព្រឹត្តដោយរបបខ្មែរក្រហម គឺមិនត្រូវបានបំភ្លេច។ យើងសង្ឃឹមថា សៀវភៅនេះនឹងជាវិភាគទានដល់ការរក្សាប្រវត្តិសាស្ត្រ និងក្រើនរំលឹកថាសោកនាដកម្មដ៏សោកសង្រេងបែបនេះត្រូវតែត្រូវបានទប់ស្កាត់កុំឲ្យកើតមានជាថ្មីម្តងទៀត។

តាំងនាមឲ្យគណៈកម្មាធិការប្រព្រឹត្តិកម្ម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានចែករំលែករឿងរ៉ាវរបស់ខ្លួនដោយសេចក្តីក្លាហាន និងយ៉ាងសប្បុរស។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះការខិតខំប្រឹងប្រែង បូជាទាំងកម្លាំងកាយចិត្តរបស់ក្រុមការងារចងក្រងប្រវត្តិរឿងរ៉ាវដែលរួមមាន លោកស្រី **ឡាច ស្រីទូច** លោក **ហ៊ុន ស៊ាងហាក់** លោក **ប៊ីលី ជាលុងតែ** កញ្ញា **លីនដា ប៉េញខេ** និង កញ្ញា **មេឌីលីន ហ្សូលី**។ សូមកោតសរសើរជាពិសេសដល់លោកស្រី **ឡាច ស្រីទូច** ជំនួយការគម្រោងនៃគណៈកម្មាធិការប្រព្រឹត្តិកម្ម ដែលបានធ្វើកិច្ចការនេះមួយផ្នែកធំ។ លើសពីនេះ ខ្ញុំក៏សូមអរគុណដល់អង្គភាពសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការជួយតាក់តែងនូវអត្ថបទទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងអគុណផងដែរដល់អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពកិច្ចការសាធារណៈរបស់សាលាក្តី លោក-លោកស្រីមេធាវីជាតិនិងអន្តរជាតិ អង្គការសមាជិក និងអង្គការដៃគូរនានា។ ជាចុងក្រោយ យើងសូមថ្លែងអំណរគុណដល់អង្គការម្ចាស់ជំនួយ គឺអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ដែលបានជួយគាំទ្រថវិកាដល់គម្រោងនេះឲ្យបានទទួលជោគជ័យ។

ភ្នំពេញ, ខែមីនា ឆ្នាំ២០១៤
លេខាធិការប្រតិបត្តិ

**សួន ប៊ុនស័ក្តិ**

# INTRODUCTION

This storybook has been compiled by the Cambodian Human Rights Action Committee (CHRAC), a coalition of 21 Cambodian NGOs and Associations working in the fields of human rights, democracy, rule of law, and peace in the Kingdom of Cambodia. This Civil Party Storybook is an expanded and updated version of “the Story and Testimony of Civil Parties in Case 002/01 before the ECCC” which CHRAC published in June 2013. This book includes all of the Civil Party stories from the old storybook; as well as the additional stories of new civil parties with the illustrations relating to what happened during that time.

Both storybooks have been produced for the sake of preserving historical stories of the victims who have lived through the Khmer Rouge Regime (also called the Democratic Kampuchea Regime). The stories in this book represent the true experiences of survivors who applied to be Civil Parties at the Extraordinary Chambers in the Courts of Cambodia (ECCC), also known as the Khmer Rouge Tribunal. Most of the accounts were extracted from victim information forms and testimonies before the ECCC. Our team at CHRAC has met with each of the contributing Civil Parties individually to obtain their consent for publication and to review and develop their story. Through this process, we aimed to ensure that all stories are accurate and authentic.

During the closing phase of the trial for Case 002/01, CHRAC requested the Trial Chamber to recognize this storybook as a judicial reparation project if the accused persons are found guilty. Since this book is being printed before the Trial Chamber issues its judgment for Case 002/01, we do not know yet whether this book will become an official reparation project. Regardless of the outcome, CHRAC would like to dedicate this work to the spirit of the Civil Parties, their relatives and all survivors of Khmer Rouge regime. May this storybook help support them in dealing with their traumatic past and provide a record for future generations of Cambodians to learn from.

We believe it is important that the atrocities committed by the Khmer Rouge regime are never forgotten. Through this storybook, we hope to contribute to the preservation of the history and create a reminder that such horrific crimes have to be prevented from happening again.

On behalf of CHRAC, I would like to express our sincere gratitude to all Civil Parties who have courageously and generously shared their stories. I would also like to acknowledge the hard work and dedication of the story compilation team: Ms. **Lach Sreytouch**, Mr. **Hun Seanghak**, Mr. **Billy Chia-Lung Tai**, Ms. **Linda Behnke** and Ms. **Madeline Zulli**. My special appreciation goes to **Ms. Lach Sreytoch**, CHRAC’s Project Assistant, who has done a major part of the work, because she selected and edited the stories in direct consultation with the Civil Parties, and also translated all of them into English. Moreover, I would like to thank the Lead Co-lawyers for Civil Parties Section for generously assisting us with the introductory chapter about the Civil Parties before the ECCC; the Victim Support Section; Public Affairs Section of the ECCC; national and international Civil Party Lawyers; NGO members and partners. Finally, we could not have realized this project without the generous financial support of our donor Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

Phnom Penh, March 2014
Executive Secretary

**Mr. Suon Bunsak**

# ២ ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[១]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ហៅកាត់ថា **សាលាក្ដីខ្មែរក្រហម** ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនៅឆ្នាំ២០០៣ និង ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុង តុលាការកម្ពុជាឆ្នាំ២០០១ (ធ្វើវិសោធនកម្មឆ្នាំ២០០៤)។ យោងតាមឯកសារទាំងនេះ អ.វ.ត.ក មានអំណាចដើម្បី *«ជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត»* ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្ត ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[២]។ អ.វ.ត.ក បានចាប់ដំណើរការជាផ្លូវការនៅក្នុងឆ្នាំ២០០៦ ដោយការិយាល័យសហព្រះរាជអាជ្ញាបានចាប់ផ្ដើមការស៊ើបអង្កេតបឋមទៅលើជនសង្ស័យ ៥រូប។

អ.វ.ត.ក គឺ ជាតុលាការពិសេសមួយនៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាដែលមានបុគ្គលិកជាអ្នកវិជ្ជាជីវៈជាតិនិងអន្តរជាតិ និងទទួលការ ឧបត្ថម្ភថវិការួមគ្នាពីរាជរដ្ឋាភិបាល កម្ពុជា និងប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិ។ ដោយសារលក្ខណៈដោយឡែកនៃរចនាសម្ព័ន្ធរបស់តុលាការ និងដោយមានការចូលរួមរបស់រដ្ឋាភិបាល និងបុគ្គលិកជាតិ និងអន្តរជាតិ ដូច្នេះហើយ អ.វ.ត.ក ត្រូវបានគេហៅជាញឹកញាប់ថា *«សាលាក្ដីកូនកាត់»*។

អ្វីដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែសាលាក្ដីខ្មែរក្រហមមាន នោះគឺការចូលរួមរបស់ជនរងគ្រោះជា *«ភាគីមួយនៃរឿងក្ដី»* នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខសាលាក្ដីនេះ ដែលគេហៅពួកគាត់ថា *"ដើមបណ្ដឹងរដ្ឋប្បវេណី"*។ អ.វ.ត.ក មានកេរ្ដិ៍ឈ្មោះល្បី ដោយសារមានគំនិតច្នៃប្រឌិតថ្មីដ៏សំខាន់មួយនៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ព្រោះថាសាលាក្ដី នេះបានផ្ដល់ឱកាសដ៏ច្រើនសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏ធំមួយនេះចូលរួម និងទទួលបានអត្ថប្រយោជន៍ពីដំណើរការស្វែងរកយុត្តិធម៌ព្រហ្មទណ្ឌមួយនេះ។

## ឧក្រិដ្ឋកម្ម និងសំណុំរឿង

ច្បាប់នៃ អ.វ.ត.ក អនុញ្ញាតឱ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានបង្កើតឡើងនៅក្នុងច្បាប់ ជាតិនិងអន្តរជាតិ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម (ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)[៣]។ ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត ឧក្រិដ្ឋកម្មទាំងនេះ អាចរួមបញ្ចូលអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងចំពោះមុខ អ.វ.ត.ក ដូចខាងក្រោមនេះ៖

### ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

- ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការបាត់ខ្លួនដោយបង្ខំ
- ការធ្វើទុក្ខបុកម្នេញ (ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា)
- ការនិរទេស និងការជម្លៀសដោយបង្ខំ
- ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ដោយបង្ខំ
- ការធ្វើបាបដោយអមនុស្សធម៌ និងអំពើប៉ះពាល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស

១ ជំពូកនេះត្រូវបានរៀបចំឡើងដោយមានការសហការជាមួយនឹងអង្គភាពសហមេធាវីនាំមុខនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

២ មាត្រា ២ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ (ធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤) (បន្ទាប់ពីនេះហៅថា «ច្បាប់ អ.វ.ត.ក») អាចរកបាននៅគេហទំព័រ http://www.eccc.gov.kh/document/legal/law-on-eccc

៣ មាត្រា ៣ថ្មី ដល់មាត្រា ៨នៃច្បាប់ អ.វ.ត.ក

# CIVIL PARTIES BEFORE THE EXTRAORDINARY CHAMBERS IN THE COURTS OF CAMBODIA[1]

The Extraordinary Chambers in the Courts of Cambodia (ECCC), sometimes called the Khmer Rouge Tribunal, was established by agreement between the Royal Government of Cambodia and the United Nations in 2003 and the Law on the Establishment of the Extraordinary Chambers in the Courts of Cambodia in 2001 (revised in 2004). According to these founding documents, the ECCC has the power to "bring to trial the most senior leaders of Democratic Kampuchea and those who were most responsible" for crimes committed from 17 April 1975 to 6 January 1979.[2] The ECCC officially launched its work in 2006 with preliminary investigations into 5 suspects carried out by the Office of the Co-Prosecutors.

The ECCC is a special court within the structure of the Cambodian court system which is staffed by national and international professionals and funded jointly by the Royal Government of Cambodia and the member states of the United Nations. Due to its unique structure and the involvement of national and international governments and staff, the ECCC is often called a "hybrid tribunal."

The participation of victims as "parties" (civil parties) to criminal proceedings before the ECCC is unprecedented in the history of international criminal tribunals. The ECCC is renowned for this groundbreaking component of its design which is an important innovation in international criminal justice, as it provides greater opportunities for victims of mass crime to access, participate in and benefit from the criminal justice process.

## THE CRIMES AND THE CASES

ECCC law allows for the prosecution of crimes established in national and international law, including crimes against humanity, genocide and war crimes (grave breaches of the Geneva Conventions).[3] Among others, these crimes can encompass the following acts which have been alleged in cases before the ECCC:

- murder, killing and extermination;
- imprisonment, confinement, torture and enforced disappearances;
- persecution (on political, racial and religious grounds);
- deportation and forced transfer;

1 This chapter was prepared in cooperation with the Civil Party Lead Co-Lawyers' Section of the Extraordinary Chambers in the Courts of Cambodia.
2 Article 2 new, Law on the Establishment of the Extraordinary Chambers in the Courts of Cambodia for the Prosecution of Crimes Committed during the Period of Democratic Kampuchea, 10 August 2001 (revised 27 October 2004) (hereinafter "ECCC Law), available at available athttp://www.eccc.gov.kh/en/document/legal/law-on-eccc.
3 Articles 3 new – 8, ECCC Law.

និង

- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងទៀងទាត់[៤]

ក្នុងសំណុំរឿង០០១ លោក **កាំង ហ្គេក អ៊ាវ** (ហៅឌុច) ដែលជាអនុប្រធាន និងបន្ទាប់មក ជាប្រធានមន្ទីរសន្តិសុខ ស-២១ ត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាម ) ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ និងតំបន់ពាក់ព័ន្ធ។ គាត់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត[៥]។

ក្នុងសំណុំរឿង០០២ មានជនជាប់ចោទ ៤រូប គឺលោក **នួន ជា** អតីតអនុលេខាធិការបក្សកុម្មុយនីស្តកម្ពុជា, លោក **ខៀវ សំផន** អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ, លោក **អៀង សារី** អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និងលោកស្រី **អៀង ធីរិទ្ធ** អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដែលជាភរិយារបស់លោក អៀង សារី។ ពួកគាត់ត្រូវបានចោទប្រកាន់នៅក្នុងឆ្នាំ២០១០ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (លើក្រុមជនជាតិវៀតណាម និងជនជាតិចាម) និងឧក្រិដ្ឋកម្មសង្គ្រាម កើតឡើងយ៉ាងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា[៦]។ នៅឆ្នាំ២០១១ លោកស្រី អៀង ធីរិទ្ធ ត្រូវបានពិនិត្យឃើញថាមិនមានកាយសម្បទា (លក្ខខណ្ឌសុខភាព) គ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការទេ ដោយសារសមត្ថភាពខួរក្បាលមានការធ្លាក់ចុះកាន់តែយ៉ាប់យ៉ឺននាំឲ្យមានជំងឺវង្វេង។ ដូច្នោះហើយដំណើរការជំនុំជម្រះក្តីលើលោកស្រីត្រូវបានព្យួរ(ផ្អាក)។ពេលនេះលោកស្រីស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ[៧]។ នៅឆ្នាំ២០១៣ លោក អៀង សារី បានស្លាប់។ ដូច្នេះដំណើរការនីតិវិធីជំនុំជម្រះក្តីប្រឆាំងនឹងរូបគាត់ត្រូវបានរំលត់(បញ្ចប់)[៨]។ លោក នួន ជា និងលោក ខៀវ សំផន នៅតែស្ថិតក្នុងការឃុំខ្លួន និងកំពុងត្រូវបានជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២។

សហចៅក្រមស៊ើបអង្កេត បច្ចុប្បន្នកំពុងតែធ្វើការស៊ើបអង្កេតទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ ចំពោះឧក្រិដ្ឋកម្មដែលកើតនៅខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តរតនៈគីរី ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ ជនសង្ស័យមិនត្រូវបានបង្ហាញឈ្មោះជាសាធារណៈនៅឡើយទេ នៅក្នុងសំណុំរឿងទាំងពីរនេះ។

## លក្ខណៈពិសេស នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃរបបខ្មែរក្រហម មានលទ្ធភាពក្នុងការចូលរួមក្នុងដំណើរការនីតិវិធីជំនុំជម្រះក្តីរបស់ អ.វ.ត.ក ក្នុងឋានៈជាភាគីមួយនៃរឿងក្តី (“ដើមបណ្តឹងរដ្ឋប្បវេណី”)។ នេះជាចំនុចមួយដែលខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត។ ក្នុងឋានៈជាភាគីនៃរឿងក្តីនៅក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិស្របច្បាប់ដ៏សំខាន់មួយចំនួន និងមានតួនាទី និងសំលេងដ៏សំខាន់នៅចំពោះមុខតុលាការ។ លក្ខណៈពិសេសរបស់តុលាការមួយនេះ យកលំនាំតាមច្បាប់កម្ពុជា ដែលអនុញ្ញាតឲ្យជនរងគ្រោះក្លាយជាភាគីមួយនៃរឿងក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ជនរងគ្រោះក៏អាចចូលរួមក្នុងឋានៈជាអ្នកប្តឹងធម្មតាបានដែរ ប៉ុន្តែមិនមានសិទ្ធិចូលរួមជាភាគីក្នុងនីតិវិធីតុលាការទេ។

វិធានរបស់តុលាការបញ្ជាក់ថា ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវដាក់ពាក្យសុំតាមរយៈអង្គភាពគាំពារជនរងគ្រោះ។ នៅក្នុងពាក្យសុំ

---

៤ សូមមើល ដីកាដំណោះស្រាយសំណុំរឿង០០១ ឯកសារលេខ D99 (ឯកសារកោសលុបសម្រាប់ប្រើជាសាធារណៈ) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ និងដីកាដំណោះស្រាយសំណុំរឿង០០២ ឯកសារលេខ D427 (ឯកសារកោសលុបសម្រាប់ប្រើជាសាធារណៈ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០

៥ សូមមើល សាលក្រមសំណុំរឿង០០១ ឯកសារលេខ E188 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ និងសាលដីកាសំណុំរឿង០០១ ឯកសារលេខ F28 ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

៦ ដីកាដំណោះស្រាយនៃសំណុំរឿង០០២ ឯកសារលេខ D427 (ឯកសារកោសលុបសម្រាប់ប្រើជាសាធារណៈ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០

៧ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទលោកស្រី អៀង ធីរិទ្ធ ឯកសារលេខ E138/1/7 ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១

៨ សូមមើល http://www.eccc.gov.kh/articles/25890 និង http://www.eccc.gov.kh/articles/25977

- forced marriage and rape in forced marriages;
- inhumane treatment and attacks against human dignity; and
- depriving a prisoner of war or civilian of the right to a fair and regular trial.[4]

In Case 001, **Kaing Guek Eav** (alias Duch), who was the Deputy and then Chairman of S-21, was convicted of crimes against humanity and grave breaches of the Geneva Conventions (war crimes) for crimes committed at the S-21 Security Center and its related sites. He was sentenced to life in prison.[5]

In Case 002, **Nuon Chea**, former Deputy Secretary of the Communist Party of Kampuchea, **Khieu Samphan**, former Head of State of Democratic Kampuchea, Ieng Sary, former Minister of Foreign Affairs, and **Ieng Thirith**, former Minister of Social Affairs and the wife of **Ieng Sary**, were charged in 2010 with crimes against humanity, genocide (against the Vietnamese and Cham) and war crimes alleged to have occurred widely throughout Cambodia.[6] In 2011, **Ieng Thirith** was found unfit to stand trial due to her deteriorating brain function and proceedings against her were suspended, though she remains under judicial supervision.[7] In 2013, **Ieng Sary** died and proceedings against him were terminated.[8] Nuon Chea and Khieu Samphan remain in detention and on trial for the crimes alleged in Case 002.

The co-investigating judges are currently carrying-out investigations for Cases 003 and 004 in Takeo, Banteay Meanchey, Battambang, Pursat, Kampong Thom, Kampong Cham, Kampong Chhnang, Ratanakiri, and Preah Sihanouk Provinces and Phnom Penh. The suspects have not yet been publicly named in these cases.

## KEY FEATURES OF CIVIL PARTY PARTICIPATION

Unlike any other international criminal court, victims of the Khmer Rouge in Cambodia have the possibility of participating in the proceedings of the ECCC as parties (“civil parties”). Status as a party to the proceedings grants civil parties a number of important legal rights and gives them a substantial role and voice in the cases before the Court. This feature of the Court derives from Cambodian law, which allows victims to be parties to criminal cases. Victims are also able to participate as simple complainants, but without the same procedural rights.

The rules of the court specify that, in order to become a civil party, victims must submit an application through the Victims Support Section. In their application, the victim must demonstrate that s/he has suffered harm as a consequence of a crime alleged in a case before the ECCC. This may include harm suffered by a person as a consequence of a crime committed against a relative.[9]

The main purposes of civil party participation at the ECCC are to participate in the criminal proceedings of the Court by supporting the prosecution and to seek collective and moral reparations.[10] Civil parties before the ECCC enjoy several key rights, including the right

4 See Closing Order, Case 001, Doc. No. D99 (public redacted version), 8 August 2008 and Closing Order, Case 002, Doc. No. D427 (public redacted version), September 15, 2010.
5 See Judgment, Case 001, Doc. No. E188, 26 July 2010 and Appeal Judgment, Case 002, Doc. No. F28, 3 February 2012.
6 Closing Order, Case 002, Doc. No. D427 (public redacted version), September 15, 2010.
7 See Decision on Immediate Appeal against the Trial Chamber’s Order to Release the Accused Ieng Thirith, Doc. No. E138/1/7, 13 December 2011.
8 See http://www.eccc.gov.kh/en/articles/accused-person-ieng-sary-dies and http://www.eccc.gov.kh/en/articles/co-prosecutors-submit-report-passing-ieng-sary.
9 Article 3, Practice Direction on Victim Participation (Rev. 1), available at http://www.eccc.gov.kh/en/documents/legal/practice-direction-victims-participation-revision-1.
10 Rule 23(1), Internal Rules of the ECCC (Rev. 8) (hereinafter “Internal Rules”), available at http://www.eccc.gov.kh/en/document/legal/internal-rules-rev8.

របស់ខ្លួន ជនរងគ្រោះត្រូវបង្ហាញថាខ្លួនបានទទួលរងព្យសនកម្ម (ការខូចខាត) ដែលជាផលលំបាកនៃឧក្រិដ្ឋកម្ម ដែលចោទប្រកាន់នៅក្នុងសំណុំរឿងណាមួយនៅចំពោះមុខ អ.វ.ត.ក។ ការខូចខាតនេះ គឺរួមបញ្ចូលផងដែរទាំងការបាត់បង់ញាតិសន្ដាន ដែលជាជនរងគ្រោះ ដោយសារឧក្រិដ្ឋកម្មទាំងនោះ[៩]។

គោលបំណងសំខាន់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក គឺដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់តុលាការ ដោយគាំទ្រការចោទប្រកាន់ និងដើម្បីស្វែងរកសំណងសមូហភាព និងសំណងផ្លូវចិត្ត[១០]។ ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ទទួលបានសិទ្ធិដ៏សំខាន់ជាច្រើន មានជាអាទិ៍ សិទ្ធិក្នុងការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌជាភាគីមួយនៃរឿងក្ដី សិទ្ធិទទួលបានមេធាវីតំណាងឲ្យខ្លួន និងសិទ្ធិទាមទារសំណង[១១]។ តាមរយៈមេធាវីតំណាងរបស់ពួកគេ ដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិមួយចំនួនផងដែរនៅក្នុងនីតិវិធី ដូចជាសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ និងសិទ្ធិស្នើសុំឲ្យមានការស៊ើបអង្កេត។

វិធាននីតិវិធីនៃតុលាការត្រូវបានកែប្រែ ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ បានចូលរួមនីតិវិធីក្នុងនាមជាបុគ្គលក្នុងអំឡុងពេលមុនការជំនុំជម្រះចាប់ផ្ដើម និងចូលរួមក្នុងនាមជាផ្នែកមួយនៃក្រុមរួម ដែលក្នុងនោះផលប្រយោជន៍ត្រូវបានតំណាងដោយ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយត្រូវបានគាំទ្រដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបន្តបន្ទាប់[១២]។

នៅ អ.វ.ត.ក ដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិក្នុងការស្នើសុំសំណងផ្លូវចិត្ត និងសមូហភាព ដែលអាចត្រូវបានផ្ដល់ជូន ប្រសិនបើមានសាលក្រមផ្ដន្ទាទោសនៅក្នុងសំណុំរឿងនោះ។ ប្រភេទនៃសំណងនេះ មានបំណងទទួលស្គាល់ការខូចខាតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបណ្ដាលមកពីអំពើឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយទណ្ឌិត និងផ្ដល់អត្ថប្រយោជន៍ដែលប៉ះប៉ូវដល់ការខូចខាតទាំងនេះ[១៣]។ សំណងសមូហភាព និងសំណងផ្លូវចិត្ត មានគោលបំណង ១)ដើម្បីប៉ះប៉ូវការរងទុក្ខខាងផ្លូវចិត្ត (សំណងលក្ខណៈផ្លូវចិត្ត) និង ២) ដើម្បីផ្ដល់ជូននូវអត្ថប្រយោជន៍ដល់ជនរងគ្រោះគ្នាច្រើន (សំណងលក្ខណៈសមូហភាព)។ យោងតាមច្បាប់របស់ អ.វ.ត.ក សំណងមិនរួមបញ្ចូលការទូទាត់ជាប្រាក់កាសដល់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

## កំណត់សម្គាល់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងចំពោះមុខ អ.វ.ត.ក

ក្នុងសំណុំរឿង០០១ ជនរងគ្រោះ ៩៤នាក់ បានដាក់ពាក្យសុំដើម្បីក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងចំណោមចំនួនទាំងអស់នោះ មានជនរងគ្រោះចំនួន៩០នាក់ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះត្រូវបានតំណាងដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៤ក្រុម។ ក្នុងអំឡុងពេលសវនាការ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២២នាក់ ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ បានផ្ដល់សក្ខីកម្មផ្ទាល់មាត់ចំពោះមុខតុលាការ។

ក្នុងសំណុំរឿង០០២ ជនរងគ្រោះជាង ៤.០០០នាក់ បានដាក់ពាក្យសុំដើម្បីក្លាយខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង។ ក្នុងចំណោមចំនួនទាំង

---

៩ មាត្រា៣ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ (វិសោធនកម្មលើកទី១) ដែលអាចរកបាននៅ http://www.eccc.gov.kh/sites/default/files/legal-documents/PD_Victims_Participation_rev1_Kh[1].pdf។

១០ វិធាន២៣ (១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិសោធនកម្មលើកទី៨) (បន្ទាប់ពីនេះហៅថា "វិធានផ្ទៃក្នុង") ដែលអាចរកបាននៅ http://www.eccc.gov.kh/document/legal/15232។

១១ វិធាន២៣ នៃវិធានផ្ទៃក្នុង អ.វ.ត. ក

១២ សូមមើលវិធាន១២ ស្ទួនពីរ និងវិធាន២៣ (៣) នៃវិធានផ្ទៃក្នុង នៃ អ.វ.ត. ក

១៣ សូមមើល វិធាន២៣ ស្ទួនបួន (១) នៃវិធានផ្ទៃក្នុង នៃ អ.វ.ត. ក

to participate in criminal proceedings as a party, the right to a lawyer to represent them and the right to claim reparation.[11] Civil parties, through their lawyers, are also entitled to a number of procedural rights, such as the right to appeal and the right to request investigations.

As a result of amendments made to the rules of the Court, civil parties in Case 002 participate on an individual basis in the period before the trial starts and as part of a single, consolidated group, the interests of which are represented by the Civil Party Lead Co-Lawyers, who are supported by civil party lawyers, in the trial phase and beyond.[12]

At the ECCC, civil parties have a right to request moral and collective reparations which may be granted if there is a guilty verdict in the case. This type of reparation is intended to acknowledge the harm to civil parties caused by the crimes of the convicted person and provide benefits that address this harm.[13] Collective and moral reparations aim 1) to address the emotional suffering and harm to individual and societal values (moral component) and 2) to provide benefits to large groups of victims (collective component). Under the rules of the ECCC, reparations cannot include monetary payments to civil parties.[14]

## HIGHLIGHTS OF CIVIL PARTY PARTICIPATION IN CASES BEFORE THE ECCC

In Case 001, 94 victims applied to become civil parties. Of these, 90 civil parties were admitted and remained civil parties to the case when the judgment was issued. These civil parties were represented by 4 civil party lawyer teams. During the trial, 22 of these civil parties gave oral testimony before the Court.

In Case 002, more than 4,000 victims applied to become civil parties to the case. Of these, 3,867 civil parties were admitted and retained this status at the close of the first segment of trial (Case 002/01). A number of national and international NGOs made tremendous and highly successful efforts both throughout Cambodia and the world over to assist over 50% of all Case 002 civil parties in filing their applications before the Court.[15] A significant number of other applications were facilitated by civil party lawyer teams and the Victims Support Section.

At all stages of the proceedings, civil parties have made important contributions to the search for justice. During the investigation phase, civil party lawyers asked the investigating judges to look into issues such as allegations of sexual violence, forced marriage and mistreatment of the Khmer Kampuchea Krom, as well as to investigate the assets of the Accused.

During the Case 002/01 trial, civil party evidence proved to be very important. In this trial, 31 civil parties gave oral testimony before the Court. Over 100 civil party written statements (such as victim information forms) were cited during hearings and nearly 600 of such documents were admitted into evidence. At the close of trial, a great deal of this civil party evidence was relied upon by the Prosecution and lawyers for civil parties to support their final arguments on the guilt of the accused.

11 Rule 23, Internal Rules.
12 Rules 12ter and 23(3), Internal Rules.
13 Rule 23quinquies(1), Internal Rules.
14 Rule 23quinquies(1), Internal Rules.
15 See CHRAC 2010 Annual Report, page 10, available at www.chrac.org.

អស់ មានជនរងគ្រោះចំនួន ៣,៨៦៧នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួនបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងទទួលបានជោគជ័យខ្ពស់ ទាំងនៅទូទាំងប្រទេសកម្ពុជា និងពិភពលោក ក្នុងការជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង ៥០% ក្នុងសំណុំរឿង០០២ ដើម្បីដាក់ពាក្យប្តឹង នៅចំពោះមុខតុលាការ[១៤]។ ការដាក់ពាក្យប្តឹងមួយចំនួនទៀត ត្រូវបានជួយសម្រួលដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ។

នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណី បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការស្វែងរកយុត្តិធម៌។ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេត មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសុំឱ្យចៅក្រមស៊ើបអង្កេត ដើម្បីស៊ើបអង្កេតទៅលើបញ្ហាដូចជា ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការធ្វើបាបដល់ខ្មែរកម្ពុជាក្រោម ក៏ដូចជាការស៊ើបអង្កេតលើទ្រព្យសម្បត្តិរបស់ជនជាប់ចោទ។

ក្នុងអំឡុងពេលសវនាការសំណុំរឿង០០២ វគ្គ១ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញថាមានសារៈសំខាន់ខ្លាំងណាស់។ នៅក្នុងសវនាការនេះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១នាក់ បានផ្តល់សក្ខីកម្មផ្ទាល់មាត់នៅចំពោះមុខតុលាការ។ មានសេចក្តីថ្លែងការណ៍ជាលាយលក្ខ័អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីជាង ១០០ច្បាប់ (ដូចជា ទម្រង់ព័ត៌មានជនរងគ្រោះ) ត្រូវបានលើកឡើងក្នុងអំឡុងពេលសវនាការ និងក្នុងចំណោមឯកសារទាំងនេះ មានឯកសារចំនួនជិត៦០០ច្បាប់ទៀត ត្រូវបានគេទទួលស្គាល់ថាជាភស្តុតាង។ នៅពេលបិទសវនាការ ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនត្រូវបានប្រើប្រាស់ដោយព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការគាំទ្រអំណះអំណាងក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ពួកគេស្តីពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

ក្នុងអំឡុងពេលសវនាការសំណុំរឿង០០២ វគ្គ១ ដែលមានចំនួន ២២២ថ្ងៃ គឺមានការមកទស្សនាដោយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៣៨៣ដង ត្រូវបានអញ្ជើញមកចូលរួមស្តាប់សវនាការ (ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់អាចមកលើសពីមួយដង និងជាមធ្យមមានដើមបណ្តឹងរដ្ឋប្បវេណីមកចូលរួមចំនួន ២៥នាក់ក្នុងមួយថ្ងៃ) ក្រោមការសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះ។ អង្គការអន្តរការីក៏បានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមកចូលរួមស្តាប់សវនាការផងដែរ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់លម្អិតអំពីប្រភេទនៃសំណង ដែលពួកគេស្វែងរកនៅក្នុងពាក្យប្តឹង និងតាមរយៈសំណើរបស់ខ្លួនដែលបានផ្តល់ជូនដោយមានការប្រឹក្សាជាមួយមេធាវី រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការគាំទ្ររបស់ខ្លួនជាផ្លូវការដល់គម្រោងសំណងទាំងនេះ។ សហមេធាវីនាំមុខ ក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងជាមួយសង្គមស៊ីវិលផ្សេងទៀត ក្រុមហ៊ុន និងរដ្ឋាភិបាល បានបង្កើតគម្រោងសំណងចំនួន ១៣គម្រោង ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ទទួលស្គាល់ថាជាសំណងតាមប្រព័ន្ធតុលាការ[១៥]។ ជាក់ស្តែង ម្ចាស់ជំនួយដែលជារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលមួយចំនួនមកពីជុំវិញពិភពលោក បានផ្តល់នូវជំនួយថវិកាដែលចាំបាច់ដល់គម្រោងជាច្រើន។

គម្រោងសំណង ដែលបានស្នើសុំក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងជា៣ជំពូកធំៗគឺ៖ ការរំឭក និងការគោរពវិញ្ញាណក្ខ័ន្ធ ការស្តារនីតិសម្បទា និងការចងក្រងឯកសារ និងការអប់រំ ប៉ុន្តែភាគច្រើននៃគម្រោងទាំងនេះផ្តល់ផលប្រយោជន៍ផ្សេងៗជាច្រើនដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

១៤ សូមមើលរបាយការប្រចាំឆ្នាំរបស់គណៈកម្មាការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ឆ្នាំ២០១០ទំព័រទី១០, ដែលអាចរកបាននៅគេហៈទំព័រ www.chrac.org

១៥ សូមមើល សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០ស្ទួន នៃវិធានផ្ទៃក្នុង, ឯកសារលេខ E218/7/6 ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣

Over the 222 days of trial hearings in Case 002/01, 5,383 civil party visits were made to the ECCC to attend these hearings under the coordination of the Victims Support Section. Intermediary organizations also invited a significant number of civil parties to attend these hearings.

The civil parties themselves, through their civil party applications and feedback that they provided in consultations with their civil party lawyers, have detailed the types of reparations that they seek. The Royal Government of Cambodia has officially offered its support to these projects. The Lead Co-Lawyers, in close cooperation with civil party lawyers, the Victims Support Section and a variety of civil society, business and government partners, have developed 13 reparation projects which Civil Parties have requested be recognized by the Trial Chamber of the ECCC as judicial reparation.[16] Fortunately, a number of governmental and non-governmental donors have come forward to provide the funding necessary to realize most of these projects.

The reparation projects requested on behalf of civil parties were developed in three main areas: remembrance and memorialization, rehabilitation and documentation and education. Many of the projects offer benefits in more than one of these areas. In Case 002/01, these projects include:

- An official national day of remembrance;
- A project to construct public memorials, such as stupas, and organize activities at memorial sites;
- A memorial dedicated to victims of the Khmer Rouge in Phnom Penh;
- A memorial dedicated to victims of the Khmer Rouge in Paris, France;
- Truth-telling “testimonial therapy” ceremonies to help victims recover from trauma;
- Self-help groups to assist victims to talk about and recover from trauma;
- Permanent exhibitions on forced transfer in provincial museums;
- Mobile exhibitions on forced transfer;
- Addition of a chapter on forced transfer and Tuol Po Chrey in a teacher’s guidebook used to educate youth about Democratic Kampuchea;
- A Community Peace Learning Center at Samraong Khnong Pagoda in Battambang Province;
- The publication and distribution of an illustrated storybook documenting civil party experiences under the Khmer Rouge;
- The printing of the Case 002/01 Trial Chamber Judgment in full-text and summary form and its distribution to civil parties; and
- The publication of all civil party names in the Case 002/01 Trial Chamber Judgment as well as their publication on the ECCC website.

At the time this book goes to print, the judges of the Trial Chamber have not yet issued their judgment in Case 002/01. If the Accused in Case 002/01 are found guilty, the judges may acknowledge the benefit that these projects offer in addressing the harm experienced by civil parties by recognizing any of the projects listed above as

16 See Civil Party Lead Co-Lawyers Rule 80bis Final Claim for Reparations with Confidential Annexes, Doc. No. E218/7/6, 8 October 2013.

ដ៏ទៃទៀត។ ក្នុងសំណុំរឿង០០២ វគ្គ១ គម្រោងសំណងទាំងនេះ រួមមាន៖

- ទិវាជាតិនៃការចងចាំ
- គម្រោងសាងសង់ស្តូបសាធារណៈ និងការរៀបចំសកម្មភាពនៅកន្លែងរំលឹកទាំងនោះ
- គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងរាជធានីភ្នំពេញ
- គម្រោងសាងសង់បូជនីយដ្ឋានរំឭកដល់ជនរងគ្រោះនៃរបបខ្មែរក្រហមនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង
- ពិធីរៀបរាប់រឿងរ៉ាវពិត "ការព្យាបាលផ្លូវចិត្តតាមបែបធ្វើសក្ខីកម្ម" ដើម្បីជួយជនរងគ្រោះឲ្យធូរស្បើយពីការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ
- ក្រុមជួយខ្លួនឯង ដើម្បីជួយដល់ជនរងគ្រោះអោយនិយាយពីរឿងរ៉ាវរបស់ខ្លួនចេញមកក្រៅនិងដើម្បីឲ្យធូរស្បើយពីការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ
- ការតាំងពិពរណ៍អចិន្ត្រៃយ៍ស្តីពីការជម្លៀសដោយបង្ខំក្នុងសារមន្ទីរតាមខេត្ត
- ការតាំងពិពរណ៍ចល័តស្តីពីការជម្លៀសដោយបង្ខំ
- ការបញ្ចូលជំពូកមួយស្តីពីការជម្លៀសដោយបង្ខំ និងទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ទៅក្នុងសៀវភៅមគ្គុទេសន៍របស់គ្រូបង្រៀន ដើម្បីអប់រំដល់យុវជន អំពីរបបកម្ពុជាប្រជាធិបតេយ្យ
- ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅ "វត្តសំរោងក្នុង" ខេត្តបាត់ដំបង
- ការបោះពុម្ព និងការចែកជូនកូនសៀវភៅស្តីពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរបបខ្មែរក្រហម
- ការបោះពុម្ពសាលក្រមទាំងមូលនៃសំណុំរឿង០០២ វគ្គ១ របស់អង្គជំនុំជម្រះសាលាដំបូងនិងសាលក្រមសង្ខេប និងការចែកជូនសាលក្រមនេះទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី
- ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ទៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ វគ្គ១ និងការបោះពុម្ពផ្សាយនៅលើគេហទំព័រនៃ អ.វ.ត.ក ។

នៅពេលសៀវភៅនេះត្រូវបានបោះពុម្ព ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញផ្សាយ សាលក្រមរបស់ខ្លួនក្នុងសំណុំរឿង០០២ វគ្គ១ នៅឡើយទេ។ ប្រសិនបើជនជាប់ចោទក្នុងសំណុំរឿង០០២ វគ្គ១ ត្រូវបានរកឃើញថាមានទោស ចៅក្រមអាចនឹងទទួលស្គាល់នូវផលប្រយោជន៍ ដែលគម្រោងទាំងនេះផ្តល់ជូន ដើម្បីជាការប៉ះប៉ូវដល់ការខូចខាតដែលកើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការទទួលស្គាល់គម្រោងណាមួយ ដែលបានរ៉ាយរ៉ាប់ខាងលើ ថាជាសំណងតាមផ្លូវតុលាការ។ គម្រោងសំណងទាំងនេះ ភាគច្រើនផ្តល់ផលប្រយោជន៍ជូនដល់ជនរងគ្រោះ និងសង្គមកម្ពុជាទូទៅផងដែរ។

ដូចដែលបានកត់សម្គាល់ខាងលើ សៀវភៅដែលអ្នកកំពុងតែអានឥឡូវនេះ គឺត្រូវបានធ្វើឡើង និងស្នើសុំធ្វើជាគម្រោងសំណងនៅក្នុងសំណុំរឿង០០២ វគ្គ១។ កូនសៀវភៅនេះ ត្រូវបានស្រាវជ្រាវ រចនា និងសរសេរឡើង ដោយគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ព្រមទាំងមានការគាំទ្រ តាមរយៈការផ្តល់មូលនិធិដោយរដ្ឋាភិបាលអាល្លឺម៉ង់។

តាមរយៈការចែករំលែករឿងរ៉ាវពិតប្រាកដរបស់ខ្លួននៅក្នុងសៀវភៅនេះ ដើមបណ្តឹងនឹងទទួលបានអត្ថប្រយោជន៍ ដែលជាឱកាសក្នុងការប្រាប់មនុស្សនៅក្នុងពិភពលោកឲ្យយល់ដឹង និងចាប់អារម្មណ៍ អំពីបទពិសោធន៍ដ៏ជូរចត់ និងការឈឺចាប់បំផុតដែលខ្លួនឯងផ្ទាល់ និងមនុស្សជាទីស្រឡាញ់របស់ខ្លួន បានទទួលរងក្នុងអំឡុងរបបខ្មែរក្រហម ព្រមទាំងឲ្យមនុស្សទូទៅទទួលស្គាល់ ការខំប្រឹងប្រែង សេចក្តីក្លាហាន និងការតស៊ូព្យាយាម ដែលពួកគេបានបង្ហាញមកខាងក្រៅ ក្នុងការស្វែងរកយុត្តិធម៌។

សៀវភៅនេះ ក៏មានគោលបំណងផងដែរក្នុងការប្រើប្រាស់ដើម្បីអប់រំដល់សាធារណជន ជាពិសេស ក្មេងជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផលប៉ះពាល់របស់វាមកលើអ្នកដែលបានរស់នៅក្នុងរបបនោះ ដើម្បីកុំឲ្យមានអំពើដ៏សាហាវយង់ឃ្នងបែបនេះ កើតមានឡើងសាជាថ្មីម្តងទៀតមកលើប្រទេសកម្ពុជា។

judicial reparations. Many of these projects will also have a wider reach and benefit victims and Cambodian society more generally.

As noted above, the illustrated storybook that you are reading now was developed and requested as a Case 002/01 reparation project. This book was researched, designed and written by the Cambodian Human Rights Action Committee (CHRAC) and generously supported through funding provided by the German government.

It is hoped that the civil parties who share their painful and true stories in this book will benefit from being able to tell the world of their experiences under the Khmer Rouge and be acknowledged not only for their and their loved ones' anguish, but also for the strength, courage and perseverance they have displayed. It is also an objective of this book, that it be used to educate the public, especially Cambodia's younger generations, about Khmer Rouge history and its effect on those who lived it, so that these atrocities are never again repeated in Cambodia.

# ៣ ប្រវត្តិរឿងរ៉ាវសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការជម្លៀសដោយបង្ខំ

ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី (សរុបចំនួន ៣,៨៦៧នាក់ ក្នុងសំណុំរឿង០០២) ក្នុងដំណើរការរបស់សាលាក្តីខ្មែរក្រហម គឺមានសារៈសំខាន់ក្នុងគោលបំណងរួមមួយរបស់ជនរងគ្រោះដែលចង់បង្ហាញដល់សាធារណជនទូទៅដឹងឮ និងចូលរួមជាផ្នែកមួយនៃកំណត់ត្រាប្រវត្តិសាស្ត្រ និងការស្វែងរកការពិតចំពោះអ្វីដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម។ ការចងក្រងប្រវត្តិរឿងរ៉ាវរបស់ជនរងគ្រោះ គឺជាការផ្តល់នូវឱកាសថ្មីមួយទៀតសម្រាប់ឲ្យពួកគាត់ប្រាប់នូវរឿងរ៉ាវរបស់ខ្លួន និងធានាថារឿងរ៉ាវទាំងនោះនឹងត្រូវបានរក្សាទុកសម្រាប់អ្នកជំនាន់ក្រោយ។

ក្នុងខណៈដែលរឿងរ៉ាវខ្លះដែលបានរៀបរាប់ក្នុងសៀវភៅនេះ ត្រូវបានដឹងយ៉ាងទូលំទូលាយចំពោះប្រជាជនកម្ពុជា ក៏ប៉ុន្តែការឈឺចាប់ឯទៀតមិនត្រូវបានចែករំលែកដោយជនរងគ្រោះទេរហូតដល់ថ្ងៃដែលពួកគាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ។ វាក៏មានសារៈសំខាន់ផងដែរសម្រាប់បង្កើនការយល់ដឹងជាទូទៅ ដោយមិនត្រឹមតែដឹងអំពីសោកនាដកម្មដែលបានប្រព្រឹត្តដោយរបបខ្មែរក្រហមនោះទេ តែថែមទាំងដឹងអំពីការឈឺចាប់សោកសង្រេងដែលស្មានមិនដល់របស់ជនរងគ្រោះគ្រប់រូបក្នុងអំឡុងពេលនោះ និងកំពុងបន្សល់ឲ្យពួកគាត់នូវការប៉ះទង្គិចផ្លូវចិត្តរហូតដល់សព្វថ្ងៃ។

ប្រវត្តិរឿងរ៉ាវដែលមានក្នុងសៀវភៅនេះ គឺចាប់ផ្តើមជាមួយការបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានានៅពេលដែលកងទ័ពខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នេះ គឺជាការផ្តោតសំខាន់នៃការជំនុំជម្រះដំណាក់កាលដំបូងនៃសំណុំរឿង០០២ នៅអង្គជំនុំជម្រះសាលាដំបូង (សំណុំរឿង០០២/០១) ដែលវិសាលភាពបានផ្តោតលើការបង្ខំឲ្យចាកចេញក្នុងដំណាក់កាលទី១ (ការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥) និងដំណាក់ទី២ (ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល (ឧត្តរចាស់) និរតី បស្ចិម និងភូមិភាគបូព៌ាចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ ១៩៧៧) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដោយហេតុថាអង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជានក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)[១៦] និងការសម្លាប់មនុស្សនៅទួលពោធិជ្រៃ[១៧]។ ម្យ៉ាងទៀត សៀវភៅនេះក៏មានផ្ទុកនូវរឿងរ៉ាវផ្សេងៗទៀតដែលជនរងគ្រោះបានជួបប្រទះ បន្ទាប់ពីការបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជន រួមមាន ការបង្ខំឲ្យធ្វើការងារជាទម្ងន់ ការបង្ខំជម្លៀសប្រជាជនក្នុងដំណាក់កាលទីពីរ ការបង្ខំឲ្យកុមារធ្វើការជាទម្ងន់ ការដាក់គុកនិងធ្វើទារុណកម្ម ការបង្ខំឲ្យរៀបការ និងការបង្អត់អាហារនិងការអត់ឃ្លាន។

ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងដំណើរការ អ.វ.ត.ក មានចំនួនច្រើន ក្រុមការងារចងក្រងប្រវត្តិរឿងរ៉ាវនៃលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្ម បានជ្រើសយកដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចតែប៉ុណ្ណោះដែលអ្នកទាំងនោះ ដែលមួយចំនួនបានផ្តល់សក្ខីកម្ម ចំពោះមុខតុលាការនៅក្នុងសំណុំរឿង០០២/០១ និងមួយចំនួនផ្សេងទៀតមិនត្រូវបានផ្តល់ឱកាសឲ្យធ្វើសក្ខីកម្មនៅចំពោះមុខតុលាការទេ តែរឿងរ៉ាវរបស់ពួកគាត់ត្រូវបានដកស្រង់ពីទម្រង់បែបបទព័ត៌មានរបស់គាត់ដែលបានប្រមូលដោយអង្គការសមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្ម[១៨] និងត្រូវបានបញ្ជូនតាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្មទៅអង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក។ យើងបានព្យាយាមជ្រើសយកអ្នកចូលរួមដែលមានសាច់រឿងផ្សេងៗគ្នា ឬប្រហាក់ប្រហែលគ្នា ហើយមកពីតំបន់ខុសៗគ្នា។ ម្យ៉ាងទៀត ក្រុមការងារចងក្រងប្រវត្តិរឿងរ៉ាវ ក៏បានពិគ្រោះយោបល់ជាមួយនឹងជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗផងដែរ ដើម្បីទទួលបានការយល់ព្រមពីពួកគាត់សម្រាប់ការបោះពុម្ពផ្សាយនូវប្រវត្តិរឿងរ៉ាវទាំងនេះ។

---

១៦ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ៥

១៧ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ តុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ទំព័រ១១៧

១៨ សមាគមអាដហុក (ADHOC), វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ (KID), ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP), ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) និងសមាគមខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA)

# BRIEF STORY OF CIVIL PARTIES RELATED TO FORCED TRANSFER AND OTHER CRIMES

All 3,867 Civil Parties participating in the second case before the ECCC have something in common – they want to tell their personal story to the public, contribute to the historical records, and seek the truth of what has happened during the Khmer Rouge regime. This compilation of victims' stories provides the Civil Parties with an additional opportunity to tell their stories and ensure that those stories will be preserved for future generations.

While some of the stories told in this book are widely known to Cambodians, many other sufferings have never been shared by the victims until the day they were giving evidence inside the ECCC court room. It is important to raise general awareness, not only about the atrocities the Khmer Rouge regime committed, but also about the inconceivable pain and grief all victims went through, leaving many of them traumatized until today.

All stories in this book start with the forced transfer from the city of Phnom Penh and other urban areas when the Khmer Rouge troops took power on 17 April 1975. This is the main focus of the first trial of Case 002 at the Trial Chamber (Case 002/01). The scope of that trial includes the first forced transfer (forced movement of Phnom Penh and other urban areas in April 1975), second forced transfer (forced movement of the people from the Central [former North Zone], Southwest, West, and Northeast Zones during September 1975 to 1977), and crimes against humanity including murder, extermination, persecution (except on religious grounds), forced transfer and enforced disappearance (insofar as they pertain to the movement of population phases 1 and 2) [17], as well as murder at Tuol Po Chrey[18]. However, the stories in this book go beyond the forced transfers, and tell of the different types of crimes perpetrated against the Civil Parties, including forced labour, child forced labour, imprisonment and torture, forced marriage, and starvation.

Given the high number of Civil Parties participating in the ECCC, the story compilation team at CHRAC could chose only a relatively small number of civil party participants, some of whom testified in the court's Case 002/01, while others did not have the chance to testify in the court room. All the stories are based on the victim information forms collected by CHRAC's member organizations[19] and submitted through CHRAC's secretariat to the Victims Support Section at the ECCC. We tried to select a diverse group of participants, representing different regions they are from. The story compilation team also consulted with each participant to receive approval from them to publish their stories and further develop the content of the stories.

17 Severance Order, paragraph 5
18 Decision for Severance of Case 002, after the decision made by the Supreme Chamber, dated 8 Feb 2013, p.117
19 The Cambodian Human Rights and Development (ADHOC), The Khmer Institute of Democracy (KID), The Cambodian Defenders Project (CDP), The Legal Aid of Cambodia (LAC), and The Khmer Kampuchea Krom Human Rights Association (KKKHRA).

ផ្នែក ១
Chapter 1

# ការចូលមកដល់នៃកងទ័ពខ្មែរក្រហម និងការជម្លៀសដោយបង្ខំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

## Arrival of Khmer Rouge / Forced Transfer on 17 April 1975


Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោក មាស សារ៉ាន់



*លោក មាស សារ៉ាន់ កើតក្នុងឆ្នាំ១៩៤៩ មានស្រុកកំណើតខេត្តស្វាយរៀង។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី១៤ និងទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។*

នៅយប់ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំកំពុងធ្វើការនៅក្នុងមណ្ឌល សង់ដឺទ្រីយ៉ាស បុរីកីឡា ក្រុងភ្នំពេញ។ មណ្ឌលនេះ គឺជាកន្លែងបន្ទាន់មួយសម្រាប់ដាក់អ្នកដែលត្រូវរបួសដោយសារគ្រាប់ផ្លោង។ មណ្ឌលនេះ មានបន្ទប់វះកាត់ចំនួន ៥កន្លែង។ នៅយប់នោះ ខ្ញុំបានឃើញភ្លើងឆេះសន្ធោសន្ធៅនៅម្តុំស្ពានមុនីវង្ស និងមានគ្រាប់ផ្លោងធ្លាក់ច្រើនកន្លែង ហើយក៏មានអ្នករបួសច្រើនត្រូវបានដឹកមកកាន់មណ្ឌលនេះ។

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅតែបន្តមើលអ្នករបួសនៅក្នុងមណ្ឌល ហើយមានអ្នករបួសច្រើនណាស់ ទាំងចាស់ ទាំងក្មេង ត្រូវបានដឹកជាបន្តបន្ទាប់យកមកដាក់នៅជាន់ផ្ទាល់ដី ចំណែកអ្នករបួសដែលបានស្លាប់ហើយនោះ ក៏អត់ទានមានអ្នកណាមកយកចេញដែរ។ នៅព្រឹកនោះ ខ្ញុំបានជួយរុំរបួសឲ្យក្មេងស្រីអាយុ៨ឆ្នាំម្នាក់ដែលធ្លាយពោះវៀន និងបុរសម្នាក់កំបុតជើង។ ប្រហែលម៉ោងជិត ១០ព្រឹក មិនមានអ្នករបួសត្រូវបានគេដឹកមកទៀតទេ ប៉ុន្តែអ្នករបួស និងអ្នកដែលកំពុងធ្វើការនៅក្នុងមណ្ឌល បានចាប់ផ្តើមចាកចេញ ពួកគេភ័យខ្លាចព្រោះតែបានឮសូរកាំភ្លើង និងគ្រាប់បែកខ្ទរឡើង។

បន្ទាប់មក ខ្ញុំបានឮអ្នកដែលចុះពីជាន់ខាងលើ (ប្លុកវះកាត់) និយាយថាយោធាខ្មែរក្រហមប្រាប់ថាឲ្យចេញពីមណ្ឌល ព្រោះមានការទម្លាក់គ្រាប់បែករបស់អាមេរិកាំង។ ដោយសារតែមានការតម្រូវឲ្យចាកចេញរបស់ខ្មែរក្រហម អ្នករបួសខ្លះបានចេញពីទីនោះដោយមធ្យោបាយខ្លួនឯង។ ខ្ញុំបានចេញពីទីនោះសំដៅទៅផ្លូវប៉ាស្ទ័រដើម្បីរកប្រពន្ធ ពេលរត់សំដៅទៅផ្លូវហ្នឹង ស្រាប់តែឮសូរបាញ់ផាំងៗ មនុស្សរត់ផាយចេញពីផ្លូវហ្នឹងមក ស្រែកថា *"កុំទៅខាងហ្នឹង! គេមិនឲ្យទៅខាងហ្នឹងទេ! គេសម្លាប់"*។

ហេតុដូច្នេះ ខ្ញុំបានរត់មកផ្ទះខ្លួនឯងដែលនៅខាងកើតវត្តមហាមន្ត្រីវិញ។ នៅតាមផ្លូវមកកាន់ផ្ទះ មនុស្សដែលរត់ឆ្វេចឆ្វាចតាមផ្លូវហ្នឹងប្រាប់ខ្ញុំថា *"គេឲ្យចេញពីក្រុងភ្នំពេញតែ៣ថ្ងៃទេ ទៅឲ្យរហ័ស ពីព្រោះអាមេរិកាំងទម្លាក់គ្រាប់បែកនៅភ្នំពេញ"*។ គ្រាន់តែឮទម្លាក់គ្រាប់បែក ខ្ញុំភ័យ ហើយចូលក្នុងផ្ទះយកបានតែអាវប្រពន្ធមួយគត់។

បន្ទាប់មក ខ្ញុំបានធ្វើដំណើរទៅតាមហ្វូងមនុស្សដែលកំពុងរត់រហូតដល់ផ្លូវមុនីវង្ស។ លើផ្លូវមុនីវង្សមានសភាពចង្អៀតទៅដោយហ្វូងមនុស្សច្រើន កំដៅថ្ងៃដែលចាំងមកកាន់តែក្តៅទៅៗ ហើយក៏មិនមានអ្នកណាជួយផ្តល់បាយទឹកឲ្យយើងបរិភោគនោះឡើយ។ ពេលធ្វើដំណើរជិតដល់ស្ពានមុនីវង្ស ខ្ញុំបានប្រទះឃើញសាកសពមនុស្សពីរនាក់នៅជំរាលខាងឆ្វេងស្ពាន ធ្វើឲ្យខ្ញុំកាន់តែភ័យ។ ដោយសារមនុស្សច្រើន ស្ពានតូច ការធ្វើដំណើរកាន់តែយឺតទៅៗ រហូតដល់ល្ងាច ទើបខ្ញុំបានឆ្លងផុតស្ពានមុនីវង្ស។

ក្រោយពីការជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្ញុំបានធ្វើដំណើរទៅស្រុកកំណើតប្រពន្ធនៅស្វាយស៊ីសុផុន។ ពេលទៅដល់ភូមិកំណើតរបស់ប្រពន្ធ ម្តាយក្មេកខ្ញុំយំពេលឃើញខ្ញុំមកតែម្នាក់ឯងដោយមិនមានប្រពន្ធមកជាមួយ។ បន្តិចក្រោយមក ម្តាយក្មេកខ្ញុំក៏ប្រាប់ថា អង្គការភ្នែកដូចម្នាស់ សូមកូនឯងទៅប្រាប់គេតាមត្រង់។ នៅថ្ងៃនោះ ខ្ញុំបានប្រាប់ខ្មែរក្រហមត្រង់ថា *"ខ្ញុំធ្វើពេទ្យនៅព្រះកេតុមាលា ហើយស្រុកភូមិប្រពន្ធខ្ញុំនៅទីនេះ។ ឥឡូវខ្ញុំបែកពីប្រពន្ធ ខ្ញុំមករកប្រពន្ធ តែរកអត់ឃើញទេ"*។

នៅថ្ងៃទី៣ វេលាម៉ោង ១០យប់ ប្រធានភូមិបានមកហៅខ្ញុំថា *"ឲ្យទៅជួយមើលថ្នាំដែលផ្ញើមកពីស្រុកចិន ព្រោះមិនមានអ្នកណាចេះមើលទេ"*។ គ្រាន់តែចេញផុតពីរបងភូមិ គេបានចាប់ខ្ញុំចង រួចដឹកដើរទៅរហូតធ្វើឲ្យខ្ញុំធ្លាក់រណ្តៅ គេបានទាញខ្ញុំឡើង រួចបន្តដំណើរទៅមុខទៀតរហូតដល់កន្លែងគេរងចាំយើង។ ពេលនោះ មានអ្នកភូមិចំនួន៣ភូមិ បានមកតាមសុំកុំឲ្យយកខ្ញុំទៅសម្លាប់ គេក៏បានដោះលែងឲ្យខ្ញុំត្រឡប់មកវិញ។ ដល់ព្រឹកឡើង គេបានយកឡានយោធាមកដឹកខ្ញុំ នឹងមនុស្សចំនួន១២គ្រួសារទៀតទៅដាក់គុកស៊ីសុផុន។ ខ្ញុំបានជាប់នៅទីនោះចំនួន ៧ថ្ងៃ។ នៅក្នុងគុក ខ្មែរក្រហមបានសួរអំពីប្រវត្តិរបស់ខ្ញុំ ខ្ញុំបានប្រាប់ថា *"ខ្ញុំធ្វើពេទ្យ"* ស្រាប់តែគេនិយាយថា *"ជាពេទ្យអាមេរិកាំង"* ហើយក៏ស្ទុះមកវ៉ៃខ្ញុំតែម្តង។ ខ្ញុំត្រូវបានគេវាយឲ្យសន្លប់ជាច្រើនលើក។ ខ្ញុំអត់យល់សោះ ពេលដែលខ្ញុំប្រាប់ថា ធ្វើពេទ្យស្រាប់តែគេស្ទុះមកវ៉ៃខ្ញុំ។

# MR. MEAS SARAN

*Mr. Meas Saran was born in 1949 at Svay Rieng province. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 14th and 22nd November 2012.*

During the night of 16 April 1975, I was working in San De Triyas Center, Borey Keila, Phnom Penh city. This center was a first emergency place for receiving people who were injured by the explosives of an artillery shell or bomb. This center had five surgery rooms. On that night, I saw the brightly sparkling flame at Monivong Bridge, and there were a lot of explosives at other places as well. Many injured people were sent to the center.

On 17 April 1975, I was still working in the center and the wounded people (including the young and the adult) were subsequently sent to the ground floor of the center, while the people who died had not yet been taken away. On that morning, I helped clean wounds for an eight-year-old girl who was wounded on her belly and for a man whose leg had been cut off by the explosives. At around 10 am, the injured people had stopped being sent to this center, but the injured and people working inside the center started moving out. They were scared because they heard the sound of explosions by gunfire and bomb. Later, I heard the people who were moving down from the upper floor (surgery block) say that the Khmer Rouge military had ordered people to move from the center because there was bombing by the American aircrafts. Due to the order to move by the Khmer Rouge, some wounded people left on their own way. I left toward Pasteur Street in order to find my wife, but when I went towards that road, I suddenly heard the sound of explosives and saw people running back and yelling, *"Do not move to that way! Khmer Rouges do not allow going on that way! They will kill!"*. As a result, I ran to my home located nearby Mohamontrei Pagoda. On the way to my home, the people who were traveling told me that *"the Khmer Rouge ordered us to leave the city for only three days, move quickly, because the American aircrafts will bomb Phnom Penh city"*. When I heard the word *"bombing"*, I was fearful. I went to my home and took only a shirt of my wife.

Then, I traveled on Monivong road with the crowd people. All the people traveled under the heat of the sun and I did not see anyone come to offer us food or water. When we moved close to Monivong Bridge, I found two corpses at the left slope of the bridge, which caused me to feel more frightened. Due to the small bridge and the large crowd of people, we moved very slowly. It was not until late evening that I could just cross to the other side of bridge.

After the eviction from Phnom Penh city, I traveled to my wife's homeland at Svay Sisophon area. When I reached my wife's home village, my mother-in-law cried when saw me coming alone, without my wife. A few minutes later, my mother-in-law told me *"Angkar has a lot of eyes like a pineapple, so you have to speak honestly about your personal story"*. On that day, I went to tell the Khmer Rouge honestly *"I am a medical staff at Preah Ketomealea hospital, and my wife's home village is in here, I just come here to find her, but unfortunately did not meet her"*. On the third day, during night at 10pm, the village chief came to me and said, "Please help us to check the medicine sent from China, because nobody can read it". When I moved out of the village's fence, I was arrested, tied up, and later on they made me walk until I fell down in a pit, they pulled me out from the pit and continued moving forward to a waiting place. Once there, the villagers from three villages came to beg the Khmer Rouge not to take me to be killed, so they released me to go back. The next morning, the Khmer Rouge transported me and 12 other families on a military truck to a jail in Sisophon Prison. I was imprisoned there for seven days. In the prison, the Khmer Rouge asked me about my biography, I told them *"I am a medical staff"*. Suddenly they were yelling "You are an American doctor" and I was beaten many times fainting several times during the beating. I still do not understand why, when I only said that I was just medical staff, they swooped in to hit me immediately.

# លោកស្រី ពេជ ស្រីផល



*លោកស្រី ពេជ ស្រីផល កើតក្នុងឆ្នាំ១៩៥២ មានស្រុកកំណើតនៅខេត្តបាត់ដំបង។ លោកស្រីគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១២។*

នៅម៉ោងប្រហែលប្រាំបីប្រាំបួន ខ្ញុំបានឮសូរមីក្រូគេប្រកាសនៅតាមថ្នល់ (មុខចេនឡា) ក្រោយមកទៀត ខ្ញុំបានឃើញកងទ័ពស្លៀកឈុតខ្មៅ ពាក់ស្បែកជើងកង់ឡាន និងមានកាន់កាំភ្លើងវែង និងកងទ័ពខ្លះលីកាំភ្លើងត្រយ៉ូងចេក ហើយដើរជាជួរនៅតាមថ្នល់។ ខណៈហ្នឹង ខ្ញុំបានឮគេស្រែកថា *"ភ្នំពេញរំដោះបានហើយ ពួកយើងមានសន្តិភាពហើយ"*។ បន្តិចក្រោយមក ខ្ញុំបានឃើញគេបំបែកកងទ័ពដែលកំពុងដើរជាជួរទៅតាមច្រកផ្លូវតូចៗដោយមានមីក្រូនិងកាំភ្លើង។ កងទ័ពទាំងនោះបានប្រកាសថា *"ស្រុកទេសយើងសន្តិភាពហើយ បងប្អូនរៀបចំអីវ៉ាន់ចេញទៅ កុំនៅទៀត ចេញតែបីថ្ងៃទេ ដើម្បីឲ្យទាហានខ្មែរក្រហមរៀបចំទីក្រុង ហើយបើសិនជាមិនចេញទេក្នុងបីថ្ងៃហ្នឹង កងទ័ពអាមេរិកាំងនឹងមកម្លាក់គ្រាប់បែកកំទេចទីក្រុងភ្នំពេញចោលហើយ ដូច្នេះដើម្បីសេចក្តីសុខរបស់បងប្អូនទាំងអស់គ្នាដែលនៅក្នុងទីក្រុងហ្នឹង ត្រូវតែនាំគ្នាចេញឲ្យអស់ក្នុងថ្ងៃហ្នឹង"*។

ពេលពួកខ្មែរក្រហមប្រាប់ឲ្យខ្ញុំចេញពីផ្ទះ ខ្ញុំបានសុំអង្វរពួកគេថា *"ចាំជុំគ្នាសិនបានចេញ"*។ ពួកឈ្លបខ្មែរក្រហម បានប្រាប់ថា *"នៅពេលដែលគេត្រឡប់មកវិញក្នុងថ្ងៃហ្នឹង ត្រូវតែឃើញចេញឲ្យអស់ បើសិនមិនចេញទេគេមកវិញដឹងគ្នាហើយ"*។ នៅវេលាម៉ោងជិតបី កងទ័ពហ្នឹងគេត្រឡប់មកម្តងទៀត ហើយគេថា *"ចេញមិនចេញ? ចេញមិនចេញ? បើមិនចេញ អញបាញ់ងាប់ ចេញមិនចេញ?"*។ ខណៈនោះ ខ្ញុំបានឃើញឈ្លបម្នាក់យកដងកាំភ្លើងវ៉ៃទៅលើគ្រួសារមួយដែលរស់នៅជិតផ្ទះរបស់ខ្ញុំ ដោយសារគ្រួសារនោះមិនព្រមចាកចេញ។ ម្តាយខ្ញុំឃើញអញ្ចឹង នឹកឃើញថា *"កូនអើយ យើងចេញទៅ។ បើយើងនៅ យើងគេចមិនផុតពីគេវ៉ៃ គេបាញ់ពួកយើងទេ"*។

ហេតុដូច្នេះ សមាជិកគ្រួសាររបស់ខ្ញុំសរុប១៣នាក់ បូករួមទាំងទារកម្នាក់ (កូនរបស់ខ្ញុំ) និងជីដូនចាស់ម្នាក់ទៀតផងនោះ បានបង្ខំចិត្តចាកចេញនៅថ្ងៃនោះ។ នៅថ្ងៃជម្លៀសនោះ ខ្ញុំបានបែកពីឪពុក ប្តី និងបងប្អូន តែក្រោយមកបានជួបជុំឪពុក និងប្តីវិញនៅចំនុចចំការដូង។ តាមផ្លូវធ្វើដំណើរដោយសារតែការបង្ខំឲ្យបន្តដំណើរទៅមុខរហូតរបស់កងទ័ពខ្មែរក្រហម ខ្ញុំបានធ្លាក់ខ្លួនឈឺទាស់ និងបានស្លាប់កូនប្រុសម្នាក់ (អាយុ៣ ឬ៤ខែ) ព្រោះតែគ្មានទឹកដោះសម្រាប់បំបៅកូន។ គ្រួសារខ្ញុំត្រូវពួកវាដកយកហូល ផាមួងបីកំប្លេ ខោអាវ៥កំប្លេ មាស២តម្លឹង និងថ្នាំពេទ្យមួយប្រអប់។ គ្រានោះ ពួកខ្មែរក្រហមបានប្រើពាក្យថា *"ពួកសក្តិភូមិត្រូវទម្លាក់អីវ៉ាន់មកឲ្យអស់ អង្គការស្នើ"*។

នៅភូមិព្រៃត្រប់ គ្រួសារដែលជម្លៀសពីភ្នំពេញ ត្រូវបានគេហៅថា *"អ្នក១៧មេសា"* ហើយយកទៅផ្ញើឲ្យស្នាក់នៅតាមផ្ទះអ្នកមូលដ្ឋានចាស់ ក្រោយមកគេបានហៅអ្នក១៧មេសាទាំងអស់ទៅចូលរួមក្នុងអង្គប្រជុំមួយ ដើម្បីកត់ឈ្មោះអ្នកណាប្រកបមុខរបរអីខ្លះនៅទីក្រុងភ្នំពេញ។ អ្នកដែលមានមុខរបរជាទាហាន ជាអ្នកធ្វើការ (មន្ត្រីរាជការ) ជាសិស្ស ឬនិស្សិតបញ្ញវន្ត ត្រូវបានគេកត់ឈ្មោះ រួចដឹកតាមឡានយកទៅសម្លាប់ចោល ដោយពួកខ្មែរក្រហមប្រាប់ថា *"ឥឡូវ អ្នកមានឈ្មោះឡើងឡានមក ទៅភ្នំពេញវិញ ព្រោះរៀបចំហើយៗ ស្អាតបាតអស់ហើយ"*។ ខ្ញុំបានដឹងរឿងដឹកយកទៅសម្លាប់នេះពីពូម្នាក់ដែលកំពុងបរទេះគោតាមផ្លូវបានខ្សឹបប្រាប់ឪពុកខ្ញុំ ខណៈពេលដែលគ្រួសារខ្ញុំទាំងអស់កំពុងត្រូវបានគេបញ្ឆោតយកទៅសម្លាប់ផងដែរ។

# MRS. PECH SREY PHAL

*Mrs. Pech Srey Phal was born in 1952 in Battambang province. As an admitted Civil Party in Case 002, she testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 5 December 2012 and recalls her experience when the Khmer Rouge soldiers took over Phnom Penh.*

On the morning of 17 April 1975, I heard the announcement through a loudspeaker along the road (front of Chenla) and saw the soldiers dressed in black uniforms and car-tyre sandals with rifles in their arms. Some of them carried big guns and walked in lines down the main road. Meanwhile, I heard them yell, *"Phnom Penh is liberated, we all get peace"*. Afterwards, I saw those soldiers separate to walk down the smaller roads with loudspeakers and guns, announcing that *"our country is in peace, so we all have to prepare our belongings to leave for three days, in order for the Khmer Rouge soldiers to clean up the city."* We were warned that if we did not leave within three days, the American aircrafts would come to bomb the city. The soldiers told us that, *"for safety purposes we all have to move out immediately"*.

When the Khmer Rouge soldiers told me to leave my house, I begged *"please wait for my relatives to come"*. The Khmer Rouge soldiers replied that they wanted to see that all the people had left during that day, warning that they would take action if not. In the afternoon, the Khmer Rouge soldiers came again and said, *"move out, if not we will shoot"*. At that moment, I saw one Khmer Rouge militiaman hit a neighboring family with a rifle handle because that family had refused to leave. My mother saw this situation and said *"My dear child, we have to move. If we stay in here, we cannot escape from being shot or beaten!"* On that day, my family members, thirteen in total including my baby and grandmother, were forced to leave Phnom Penh.

On the way, due to the force used by the Khmer Rouge to keep us moving, I became ill and my son (about three or four months old) died because I was unable to breastfeed. After that, the Khmer Rouge soldiers confiscated my family's belongings such as clothing, gold and a box of medicine, saying, *"Angkar proposes all the capitalist people have to put down all their belongings"*. After leaving from Phnom Penh, my family was allowed to live in Prey Trab village. In that village, the families who were evicted from Phnom Penh city, were considered as the *"17 April people"* and sent to live with the old based people's houses. Later on, the Khmer Rouge convoked all the 17 April people to join a meeting, in order to make a record of their background while living in Phnom Penh city. The people who used to serve as soldiers, civil servants, students or intellectuals had their names listed down and were loaded onto a truck for their execution, even though the Khmer Rouge said *"Now, the people who are named on the list have to take the truck back to Phnom Penh, because the city is already prepared and cleaned up"*. I knew the story of transporting the people for execution from one uncle who, while driving an ox-cart on the way, whispered this information to my father. My entire family was being cheated to be killed as well.

# លោក គឹម វ៉ាន់ឌី



*លោក គឹម វ៉ាន់ឌី កើតក្នុងឆ្នាំ១៩៦២ មានស្រុកកំណើតនៅខេត្តកំពត។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី០៥ និងទី០៦ ខែធ្នូ ឆ្នាំ២០១២។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រហែលម៉ោង៦ ទៅ ៧ព្រឹក ទ័ពខ្មែរក្រហមបានចូលមកពេញទីក្រុងភ្នំពេញ។ ខណៈនោះ ឪពុកមាខ្ញុំម្នាក់ដែលជាទាហានលន់ នល់ ស័ក្តិ៥ ត្រូវបានទ័ពខ្មែរក្រហមបាញ់សម្លាប់នៅមុខផ្ទះរបស់គាត់។ ម៉ោងប្រហែលប្រាំបួន ខ្ញុំបានឃើញទាហានក្នុងឯកសណ្ឋានពណ៌ខ្មៅ ពាក់មួកប៉ារេ បង់ក្រមា ដាក់កាំភ្លើងឈាង ជិះម៉ូតូសេអិលគ្នាពីរនាក់ (ម្នាក់បើក និងម្នាក់កាន់មីក្រូ) ស្រែករំពងឲ្យប្រជាជនចាកចេញពីក្រុងភ្នំពេញឲ្យឆាប់ជាបន្ទាន់ រយៈពេលតែបីថ្ងៃទេ ដើម្បីកុំឲ្យទាហានអាមេរិកាំងទម្លាក់គ្រាប់បែក។ ពេលហ្នឹង ខ្ញុំ នៅបង្អែបង្អង់មិនទាន់ចាចេញទេ ចាំមើលគេសិន ស្រាប់តែមានកងទ័ពខ្មែរក្រហមមួយខ្សែទៀតមកដល់ ហើយស្រែកថា *"នៅយឺតយ៉ាវ នៅរួញរា ត្រេតត្រតដល់អង្កាល់ទៀត? បន្តិចទៀតយន្តហោះមកដល់ហើយ ប្រញាប់ស្រូតឡើងណា៎ ក្រែងលោបាត់បង់អាយុជីវិតកាន់តែច្រើនទៅៗ"*។

បន្ទាប់មក ខ្ញុំឃើញខ្មែរក្រហមបាញ់កាំភ្លើងឡើងលើបំបែកហ្វូងមនុស្សដែលកំពុងឈរកកកុញគ្នា រួចបង្ខំឲ្យរៀបចំអីវ៉ាន់ចាកចេញពីផ្ទះ។ ប្រហែលថ្ងៃត្រង់ គ្រួសារខ្ញុំបានចេញតាមផ្លូវសន្ធរមុខមកដល់គល់ស្ពានជ្រោយចង្វារ រួចចេញតាមផ្លូវជាតិលេខ៥។ យើងចេះតែទៅ រហូតដល់ភូមិទួល ស្រុកបាធាយ ខេត្តកំពង់ចាម។ យើងបាននៅទីនោះប្រហែល ១ទៅ២សប្តាហ៍ ឪពុកម្តាយខ្ញុំ បានសុំអ្នកមូលដ្ឋានដើម្បីស្នាក់នៅទីនោះបន្តទៀត តែគេមិនអនុញ្ញាតទេ ព្រោះគេថាយើងជាអ្នក១៧មេសា ចំណែកភូមិនេះគឺជាភូមិអ្នក១៨មេសា។ យើងបានធ្វើដំណើរត្រឡប់ក្រោយវិញ ដើម្បីរកផ្លូវទៅស្រុកកំណើតនៅស្រុកអង្គរជ័យ ខេត្តកំពត។ យើងទៅមិនដល់ស្រុកកំណើតទេ ព្រោះខ្មែរក្រហមឲ្យយើងរស់នៅស្រុកប៉ាឡៃឡៃ។ នៅទីនោះ គេបានបែងចែកអ្នក១៧មេសារស់នៅផ្សេង មិនឲ្យរស់នៅច្រឡូកច្រឡំជាមួយអ្នក១៨មេសាទេ។

ក្រោយមក ប្រធានភូមិបានចាត់ឲ្យអ្នក១៧មេសាកាប់ដីធ្វើស្រែ។ គ្រួសារខ្ញុំត្រូវកាប់ដីឲ្យបាន១២ម៉ែត្រការ៉េ ទើបគេឲ្យអង្ករពីរកំប៉ុងសម្រាប់ដាំបាយហូប។ ខ្មែរក្រហមតែងតែសួរខ្ញុំអំពីប្រវត្តិឪពុកម្តាយរបស់ខ្ញុំ តែខ្ញុំមិនបានប្រាប់គេត្រង់ទេ។ ថ្ងៃមួយ ខ្មែរក្រហមបានចាប់ឪពុកខ្ញុំចងស្លាប់សេកបណ្តើរចេញទៅសម្លាប់ ព្រោះគេបានឆែកឃើញរូបថតគាត់ថតលើកប៉ាល់ក្នុងឯកសណ្ឋានទាហានជើងទឹក។ បន្ទាប់មក គេបានតិះដៀលខ្ញុំថា *"ជាកូនអាក្បត់ ប៉ិនកុហកណាស់ មុខឯងនេះ បានសមតែពីរបីកំផ្លៀងទេ ប៉ុណ្ណឹងសោះ ចេះកុហក ចេះភូតភរ។ ឯងដឹងទេ សង្គមនេះគឺសង្គមស្អាតស្អំណាស់ មិនដូចនៅសង្គមឯងទេ"*។ ពេលយប់ ខ្ញុំត្រូវគេដាក់ខ្នោះជើង។ ប្រហែល ១ សប្តាហ៍ទើបគេដោះលែងខ្ញុំ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំ និងគ្រួសារ១៧មេសាឯទៀតចេញពីភូមិ។ យើងត្រូវគេបានបញ្ជូនទៅសហករណ៍ឃុំតាឡូហាទិល ស្រុកបាកាន ខេត្តពោធិសាត់។ នៅទីនោះ ស្ថានភាពរស់នៅកាន់តែលំបាកទ្វេឡើង ព្រោះយើងអត់អាហារកាន់តែខ្លាំង។

# MR. KIM VANNDY

*Mr. Kim Vanndy was born in 1962 at Kampot province. He is a Civil Party in Case 002 and testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 5th and 6th December 2012.*

Early on the morning of 17 April 1975, the Khmer Rouge soldiers entered Phnom Penh city. At that time, my uncle, a Lon Nol soldier (Colonel), was shot dead by the Khmer Rouge in front of his home. About 9 am, I saw the soldiers dressed in black uniforms, wearing caps and scarves, and carrying rifles. The soldiers were riding motorbike, with one soldier driving while another carried loudspeaker and they shouted loudly on the road, ordering people to leave Phnom Penh city for three days to avoid a bombing by American aircrafts. I hesitated to move and waited to see the people around me, when suddenly another line of Khmer Rouge soldiers came in and shouted at me, *"why slow down and hesitate to move? The aircraft will arrive in few minutes, hurry up and go, if not more people will lose their life in here"*.

Later, I saw the Khmer Rouge soldiers shoot into the air to break away the crowed people and forced them to pack up their belongings to move from home. Around the afternoon, my family left on Santor Mukh Street to the edge of Chroy Changvar Bridge and continued our journey on the National Road No.5. We kept going until we reached Tuol village, Batheay district, Kampong Cham province. We stayed there for about one to two weeks. My parents asked the base people for us to stay there, but they did not allow it because we were the *"17 April people"* and this village was for the *"18 April people"*. We went back in order to find a way to our homeland at Angkor Chey district, Kampot province. We could not reach our homeland because the Khmer Rouge forced us to stay at Pa Lelai district. There the Khmer Rouge made the 17 April people live separately from the 18 April people. The village chief assigned the 17 April People to hoe land for farming. My family was ordered to hoe 12 square meters of land and they only offered us two cans of husked rice to eat.

The Khmer Rouge always asked me about the background of my parents, but I never told them the truth. One day, the Khmer Rouge arrested my father, tied his hand behind his back and escorted him be killed, because they found a photograph of my father dressed in a navy uniform on a ship. Later, the Khmer Rouge insulted me saying, *"you are a child of traitor and good at telling lies, you deserve to be slapped in the face, you are still young but you know how to lie. You know, this society is very clean, not the same as your society"*. At night, I was shackled on my leg for about one week until they unshackled me. In mid-1978, the Khmer Rouge transferred my family and other 17 April families from the village. We were transported to the cooperative of Ta Lo Hatil commune, Bakarn district, Pursat province. Our living situation was difficult there as we became more and more starving.

# លោកស្រី អោ រី



*លោកស្រី អោ រី អាយុ ៥០ឆ្នាំ មានស្រុកកំណើតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នក ដែលបានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២២ និងទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២។*

ក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយកបងស្រីខ្ញុំ (ដែលត្រូវរបួសធ្ងន់ដោយសារអំបែងគ្រាប់ផ្លោង) ចេញពីមន្ទីរពេទ្យធំមកដល់ផ្ទះបានពីរបីថ្ងៃ ខ្ញុំបានឃើញកងទ័ពស្លៀកពាក់ខោខ្មៅ អាវខ្មៅ ស្បែកជើងកង់ឡានបង់កក្រម៉ា ដើរជាជួរៗចូលមកទីក្រុងភ្នំពេញ។ ពេលនោះ ពួកខ្មែរក្រហមបានស្រែកតាមមីក្រូថា *"ប្រជាជន អ្នកនៅទីក្រុងភ្នំពេញ សូមអញ្ជើញចេញ គេបោសសម្អាតនៅទីក្រុង ចេញតែ៣ថ្ងៃទេ នឹងវិលត្រឡប់មកវិញ មិនបាច់យករបស់របរអីទៅទេ ទៅតែខ្លួនបានហើយ"*។ ខណៈនោះ មានប្រជាជនខ្លះមិនចង់ចេញទេ ព្រោះស្តាយទ្រព្យរបស់របរនៅពេញផ្ទះ តែខ្មែរក្រហមបានប្រាប់ថា *"គ្មានអ្នកណាយករបស់អ្នកឯងហ្នឹងទេ។ អ្នកឯងចេញទៅ អ្នកឯងទៅតែ៣ថ្ងៃ អ្នកឯងមកវិញ របស់អ្នកឯងនៅដដែលហើយ"*។

ក្នុងពេលធ្វើការជម្លៀសហ្នឹង ម្តាយខ្ញុំសរសៃខ្ចី ព្រោះទើបសម្រាលកូនរួច ហើយណាមួយបងស្រីខ្ញុំកំពុងមានរបួសធ្ងន់ ហេតុដូច្នេះម្តាយខ្ញុំបានប្រាប់ខ្មែរក្រហមថាចាំសុខភាពបានស្រួលបន្តិចសិន ទើបធ្វើការចាកចេញ ប៉ុន្តែពួកខ្មែរក្រហមមិនអនុញ្ញាតទេ ដោយប្រាប់វិញថាចេញតែបីថ្ងៃទេ នឹងត្រឡប់មកវិញហើយ។ ពេលស្រែកប្រកាសឲ្យចេញនោះ ខ្ញុំបានឃើញខ្មែរក្រហមមានកាំភ្លើងក្នុងដៃ បានដើរកៀសប្រជាជនឲ្យចាកចេញ ពួកវាថា *"បើអ្នកណាមិនចេញ អ្នកហ្នឹងចង់ស្លាប់អី គេបោសសម្អាតខ្មាំងឲ្យស្រួតៗចេញក្នុងយប់ហ្នឹង"*។ គ្រួសារខ្ញុំបានចំណាយពេលអស់មួយថ្ងៃមួយយប់ទើបធ្វើដំណើរទៅដល់ស្រុកកំណើតនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល។ មកដល់ស្រុកកំណើត ខ្មែរក្រហមមិនឲ្យយើងចូលទៅនៅក្នុងផ្ទះរបស់ខ្លួនឯងទេ គឺពួកវាឲ្យយើងទៅសង់រោងថ្មីសម្រាប់រស់នៅ ព្រោះគេបានប្រាប់ថាអ្នកមកពីទីក្រុងភ្នំពេញគឺជាអ្នកមូលដ្ឋានថ្មី ដូច្នេះគេមិនឲ្យនៅជិតអ្នកមូលដ្ឋានចាស់ទេ។

ប៉ុន្មានខែក្រោយមក ពួកខ្មែរក្រហមបានជម្លៀសគ្រួសារអ្នកជម្លៀសមកថ្មីទាំងអស់ឲ្យទៅរស់នៅខាងខេត្តពោធិសាត់ និងបាត់ដំបង។ គ្រួសារខ្ញុំត្រូវបានគេបញ្ជូនទៅរស់នៅភូមិចំការតាប៉ូ ឃុំស្នឹង ស្រុកកណ្តៀង ខេត្តពោធិសាត់។ នៅទីនោះបានប្រហែលបួនប្រាំថ្ងៃ សមាជិកគ្រួសារអ្នកចំណូលថ្មីបានត្រូវពួកខ្មែរក្រហមបំបែកឲ្យរស់នៅផ្សេងៗគ្នា។ អ្នកចំណូលថ្មីត្រូវបានគេឲ្យស្នាក់នៅក្នុងរោងវែងៗ ដែលខុសប្លែកពីអ្នកមូលដ្ឋានចាស់ដែលគេមានផ្ទះផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ស្នាក់នៅ។ ក្នុងរបបខ្មែរក្រហមនេះ សមាជិកគ្រួសារខ្ញុំចំនួន៥នាក់ (មានឪពុក ម្តាយ និងបងប្អូន) ត្រូវបានបាញ់សម្លាប់ដោយពួកយោធាខ្មែរក្រហម ចំណែកឯប្អូនប្រុសពៅអាយុ ២ឆ្នាំម្នាក់ ត្រូវបានពួកខ្មែរក្រហមចាប់បោះឡើងលើ ហើយយកចុងកាំភ្លើងចាក់ចំទ្រូងប្រកាច់ស្លាប់ភ្លាមៗ។ ចំណែកឯជីវិតខ្ញុំទៀតសោត ក៏ស្ទើរតែត្រូវបានសម្លាប់ផងដែរនៅខណៈនោះ។

# MRS. OR RY

*Mrs. Or Ry, 50 years old, was born in Khsach Kandal district, in Kandal province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 22nd and 23rd November 2012.*

In April 1975, a few days after bringing my older sister who had been seriously injured by an artillery shell home from hospital, I saw the soldiers dressed in black uniforms, wearing car-tyre sandals and scarves around their necks, walking in lines to Phnom Penh city. At that time, the Khmer Rouge soldiers announced through the loudspeaker, *"the Phnom Penh city dwellers have to move because the city needs to be cleaned up. They are moving only for three days and will be returned to the city, so there is no need to bring belongings. Move without bringing anything"*. Meanwhile, some people did not want to move because they did not want to leave their property behind inside their houses, but the Khmer Rouge soldiers told them *"nobody would take your belongings. You have to move, move only for three days, and your belongings will be still here when you return"*. During the transfer, my mother had just given birth and my older sister was seriously wounded, so my mother told the Khmer Rouge that we could not move. But the Khmer Rouge told her, *"move only for three days and then you will be back"*. During their announcement, I also saw the Khmer Rouge soldiers with rifles walking to force people to leave, while they announced, *"those who deny moving will be killed, the city needs to be cleaned, hurry up and move within the night"*.

My family walked for one day and night to reach the homeland at Tbong Damrie village, Kampong Chamlang commune, Khsach Kandal district. In the homeland, the Khmer Rouge did not allow us to live in our own house, but ordered us to build a new hall to live in. They told us that the Phnom Penh city dwellers were considered as the *"new people"*, and therefore were not allowed to live close to the *"based people"*.

A few months later, the Khmer Rouge retransferred the new people to Pursat and Battambang provinces. My family was sent to live in Chamkar Tapo village, Stung commune, Kandieng district, Pursat province. After living there for about four or five days, family members of the new people were separated to live differently. The new people were ordered to live in long halls, while the based people lived in their own houses. During the Khmer Rouge regime, five members of my family (my father, mother and siblings) were shot dead by the Khmer Rouge militiamen. My youngest brother, who was two years old, was thrown into the air and immediately stabbed dead with a bayonet, and I was almost killed during that time.

ផ្នែក ២
Chapter 2

# ការបង្ខំឲ្យធ្វើការ

## Forced Labor


Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោកស្រី ឱម ចន្ថា



*លោកស្រី ឱម ចន្ថា កើតក្នុងឆ្នាំ១៩៣៩ និងមានស្រុកកំណើតនៅភូមិឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។*

*លោកស្រី គឺជាដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ មុនសម័យខ្មែរក្រហម លោកស្រីជាគិលានុបដ្ឋាយិកានិងធ្មបនៅមន្ទីរពេទ្យ៤០១ទីរួមខេត្តកំពង់ចាម រីឯប្ដីលោកស្រីជាពេទ្យយោធា។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលដល់ទីរួមខេត្តកំពង់ចាម។ ខណៈនោះ ខ្ញុំកំពុងធ្វើការនៅមន្ទីរពេទ្យ៤០១ទីរួមខេត្តកំពង់ចាម។ បន្តិចក្រោយមក ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចេញពីភូមិ រួមទាំងអ្នកជំងឺនៅមន្ទីរពេទ្យក៏ត្រូវចេញដែរ។ គ្រួសារខ្ញុំ និងប្រជាជនឯទៀត បានធ្វើដំណើរក្រោមបញ្ជារបស់ខ្មែរក្រហមរហូតដល់ភូមិស្វាយប៉ុន ស្រុកព្រៃឈរ។ ទៅដល់ទីនោះ ប្រធានភូមិបានឲ្យគ្រួសារខ្ញុំស្នាក់នៅក្នុងរោងមន្ទីរសេដ្ឋកិច្ច។ បន្ទាប់មក គេបានចាត់ប្ដីខ្ញុំឲ្យទៅរកត្រីនៅបឹងរកាកោង ខ្ញុំឲ្យទៅធ្វើស្រែ កូនប្រុសពីរនាក់ឲ្យទៅឃ្វាលគោ និងកូនបីនាក់ទៀតឲ្យទៅរើសអាចម៍គោដើម្បីធ្វើជី។ ចេញទៅរកត្រីបានប្រហែលកន្លះខែ ប្ដីខ្ញុំក៏បានត្រឡប់មកផ្ទះវិញ។

ពីរបីថ្ងៃក្រោយមក ម៉ោង៤ល្ងាច ខ្មែរក្រហមបានមកប្រាប់គាត់ថា *"ទៅធ្វើពលកម្ម"*។ លុះម៉ោង៦ល្ងាច គាត់បានចេញទៅជាមួយនឹងអ្នកផ្សេងៗទៀត ក្រោមការអមដំណើរដោយឈ្លបខ្មែរក្រហម។ ចេញផុតពីភូមិបានប្រហែល៥០០ម៉ែត្រ ស្រាប់តែខ្ញុំឮសម្លេងកាំភ្លើងលាន់រំពង។ រំពេចនោះ ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះដឹងថាប្ដីខ្ញុំត្រូវគេសម្លាប់ហើយ។ យប់នោះ មានបុរសម្នាក់ដែលរួចពីការបាញ់សម្លាប់បានមកប្រាប់ខ្ញុំថា ប្ដីអ្នកស្លាប់ហើយ អ្នកនាំគ្រួសាររត់ទៅ។ ស្អែកឡើង ម៉ោង១០យប់ ខ្ញុំបាននាំគ្រួសារដែលមានសមាជិក១០នាក់រត់ចេញពីទីនេះ តែរត់មិនរួចសោះ។ នៅយប់ទីពីរ យើងបានរត់ម្ដងទៀត។ យើងធ្វើដំណើរអស់រយៈពេលពីរយប់បីថ្ងៃទើបដល់ភូមិអង្គរបាន រួចបានឆ្លងទន្លេទៅកោះតូច។ ពេលទូកកំពុងឆ្លងទន្លេ ខ្មែរក្រហមបានប្រទះឃើញទូកយើង ហើយបានបាញ់ស្រោចលើទូកយើងធ្វើឲ្យយើងភិតភ័យយ៉ាងខ្លាំង តែសំណាងណាស់ដែលគ្រាប់ទាំងនោះមិនត្រូវចំអ្នកណាម្នាក់ក្នុងទូកឡើយ។ បន្ទាប់មក យើងបានឆ្លងទូកពីកោះតូចទៅភូមិឫស្សីស្រុកដែលជាស្រុកកំណើតខ្ញុំ។ យើងនៅភូមិឫស្សីស្រុករហូតដល់ដើមឆ្នាំ១៩៧៦ ទើបខ្មែរក្រហមជម្លៀសយើងចេញពីភូមិតាមទូកមកព្រែកក្ដាម រួចបន្តដំណើរតាមរទេះភ្លើងទៅខេត្តបាត់ដំបង។ ខ្មែរក្រហមបានយកគ្រួសារខ្ញុំទៅដាក់នៅភូមិអូតាកែ ឃុំអូរតាគី។ នៅទីនោះ គេចាត់ឲ្យខ្ញុំទៅលើកប្រឡាយ និងដកសំណាប កូនប្រុសបងគេពិការជើងត្រូវខ្មែរក្រហមបញ្ជារឲ្យទៅបររទេះ និងពុះអុសក្នុងភូមិ កូនម្នាក់ទៀតត្រូវបញ្ជូនឲ្យទៅនៅកងចល័ត និងកូនបីនាក់ទៀតឲ្យទៅរើសអាចម៍គោនៅក្នុងភូមិដើម្បីធ្វើជីដាក់ស្រែ។ រីឯម្ដាយខ្ញុំអាយុជាង៨០ឆ្នាំ ត្រូវឲ្យទៅនៅកងមនុស្សចាស់ក្នុងភូមិ។ ក្រោយមក (ប្រហែលឆ្នាំ១៩៧៧-១៩៧៨) ខ្មែរក្រហមបានចាត់ខ្ញុំឲ្យទៅសមរភូមិមុខដើម្បីធ្វើស្រែគំរូ គឺជាស្រែដែលយកមនុស្សមកទឹមភ្ជួរដីជំនួសគោក្របី។ ពេលនោះ គេបានយកខ្ញុំទឹមជំនួសគោដើម្បីភ្ជួរស្រែ។ បន្ទាប់មកទៀត គេឲ្យខ្ញុំដើរបេះត្រកួនឲ្យបានមួយបាវក្នុងមួយថ្ងៃ។ ព្រោះតែសក់ខ្ញុំរួញ មេកងបានចាត់ទុកខ្ញុំថាជាប្រពន្ធអ្នកធំ។ គេតាមដានខ្ញុំគ្រប់ពេល ព្រោះគេថាប្ដីខ្ញុំជាអ្នកធំវណ្ណៈខ្ពស់សម័យលន់ នល់។

# MRS. OM CHANTHA

*Mrs. Om Chantha, was born in 1939 at Russey Srok village, Srey Santhor district, Kampong Cham province. She is a Civil Party in the second case of the Extraordinary Chambers in the Courts of Cambodia (ECCC). Before the Khmer Rouge regime, she was a nurse and midwife at Hospital 401 of Kampong Cham provincial capital, while her husband was a medic.*

On 17 April 1975, the Khmer Rouge entered the capital of Kampong Cham province. At that time, I was working as a nurse and midwife at Hospital 401 of Kampong Cham provincial capital. The Khmer Rouge forced the people to move out of the village, including the patients at the hospital. My family and other people traveled under the Khmer Rouge's order until we reached Svay Pin village, Prey Chhor district. Over there, the village chief made my family stay in the hall of the Department of Economy. They assigned my husband to go fishing at Rokar Kaung Lake, while I was sent to work in the farm. My two sons were forced to tend cows, and three other children had to collect cow dung to make fertilizer. After going fishing for about half a month, my husband came back home. A few days later, at 4 pm, the Khmer Rouge came and told my husband to *"go to work"*. At 6 pm, he went with other people under the accompaniment of the Khmer Rouge militiamen. Once they were about 500 meters away from village, I heard the loud sounds of gunfire. Suddenly I felt very shocked, because I knew that my husband was killed. That night, a man who had escaped from the shooting came to tell me *"your husband was already killed, so bring your family run away"*. The next night, I brought my ten family members with me to run away from this village, but we could not escape. On the second night, we tried to flee again. It was about two nights and three days before we arrived in Angkor Ban village. We then took a boat across the river to Koh Toch Island. When our boat was crossing the river, the Khmer Rouge found us. They shot at our boat, which caused us to feel very frightened, but luckily, no one on the boat was shot. After that, we kept going by boat from Koh Toch Island to Russey Srok village, which was my native village. We lived in this village until early 1976.

The Khmer Rouge transferred us from my native village by boat to Prek Kdam area and then made us continue by train to Battambang province. The Khmer Rouge took my family to O Ta Ke village, O Ta Ki commune. There, they assigned me to dig a canal and pull out the rice seedlings, my oldest son (his leg was disabled) was ordered to drive ox cart and chop firewood in the village, my younger son was assigned to work in the mobile unit, while three other children were sent to collect cow dung in the village to make fertilizer to put in the rice field. My mother, who was over 80 years old, was ordered to work in the elderly unit in the village. Later, the Khmer Rouge assigned me to work in the model farm at the battlefield – a farm that takes people to plow instead of cows or buffalos. At that time, they got me to yoke instead of cow to plow in the rice field. After that, they ordered me to pick up a sack of water convolvulus per day. Because of my wavy hair, the unit chief considered me the wife of a high-class person. They always kept track of me all the time because they alleged that my husband was a high-class person in Lon Nol regime.

# លោកស្រី ឈឹម វណ្ណា



*លោកស្រី ឈឹម វណ្ណា កើតក្នុងឆ្នាំ១៩៦០ មានស្រុកកំណើតនៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឃើញពួកខ្មែរក្រហមមួយក្រុមធំមានស្ពាយកាំភ្លើង បានសម្រុកចូលទៅក្នុងបន្ទាយទាហាន ហើយបានភ្ជង់កាំភ្លើងបណ្តេញគ្រួសារខ្ញុំ និងគ្រួសារទាហានឯទៀតសរុបចំនួន២០គ្រួសារ។ គេបានប្រាប់ថា *"ចេញទៅឲ្យលឿនៗ អង្គការឲ្យទៅតែបីថ្ងៃទេ មិនបាច់យកអីវ៉ាន់ទៅទេ"*។ ភ្លាមៗនោះ មានខ្មែរក្រហម៤នាក់បានចូលទៅក្នុងផ្ទះ គាស់តុទូ និងកកូរកកាយយកអីវ៉ាន់ចេញពីក្នុងផ្ទះអស់រលីង។ នៅម៉ោង៣រសៀល ពួកខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើដំណើរទៅទិសខាងកើត។ នៅតាមផ្លូវ ពួកខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើដំណើរលឿនៗទៅមុខ ដល់ពាក់កណ្តាលអធ្រាត្រទើបគេឲ្យឈប់សំរាកនៅកណ្តាលព្រៃស្ងាត់។ យើងដាំបាយហូបជាមួយអំបិល។

ពេលខ្លះ ខ្មែរក្រហមឲ្យយើងសំរាកចំកន្លែងអត់មានទឹក ដូច្នេះយើងបានដេកទាំងអត់មានអីហូបឡើយ។ ប្រហែល១ខែ ទើបយើងបានទៅដល់ភូមិសំរោងលើ ឃុំសំរោង ស្រុកស្វាយលើ ខេត្តសៀមរាប។ នៅថ្ងៃបន្ទាប់ខ្មែរក្រហមបានហៅអ្នកជម្លៀសទាំងអស់ទៅចូលរួមប្រជុំ ហើយបានប្រកាសថា *"សូមមន្ត្រីរាជការទាំងអស់អញ្ជើញឡើងឡានទៅធ្វើការងារតាមក្រសួងរៀងៗខ្លួនវិញ"*។ ខណៈនោះ មានសុទ្ធតែប្រុសៗ រួមទាំងឪពុក និងបងប្រុសទី២របស់ខ្ញុំផងដែរ ត្រូវបានខ្មែរក្រហមចាប់រុញឡើងឡានទាំងបង្ខំ រួចដឹកចេញទៅបាត់។ នៅទីនេះ ខ្មែរក្រហមបានឲ្យយើងកាប់គាស់គល់ឈើកាប់ព្រៃ ទាំងយប់ទាំងថ្ងៃ ដោយមិនមានអាហារហូបគ្រប់គ្រាន់ទេ។ មួយអាទិត្យក្រោយមក ពួកខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំ (មានម្តាយ ក្មួយប្រុសស្រីពីរនាក់ បងប្រុសពីរនាក់ និងបងថ្លៃស្រីម្នាក់) ទៅនៅភូមិគោកធ្លក ឃុំគោកធ្លក ស្រុកជីក្រែង ខេត្តសៀមរាប។ នៅទីនោះបាន៥ថ្ងៃ ម្តាយខ្ញុំបានស្លាប់ដោយសារជំងឺ និងការអត់អាហារ។ ក្រោយមក ខ្មែរក្រហមបានបន្តជម្លៀសយើងឲ្យទៅភូមិស្រម៉ ឃុំជីក្រែង ខេត្តសៀមរាប ដែលស្ថិតនៅតាមដងស្ទឹងជីក្រែង។ នៅទីនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំជាកុមារីជំទង់ទៅធ្វើក្នុងកងយុជនយុវនារី។ ពេលខ្លះ ខ្មែរក្រហមបាន ចាត់កងយុវជន យុវនារីទៅធ្វើការឆ្ងាយពីភូមិ ដោយត្រូវធ្វើដំណើរឆ្លងកាត់អូរ ប្រឡាយ ដែលមានទឹកជ្រៅ។ ពេលខ្លះ ខ្ញុំលង់ទឹកស្ទើរស្លាប់ព្រោះតែមិនចេះហែលទឹក។ នៅដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់បងប្រុសខ្ញុំពីរនាក់យកទៅសម្លាប់ ដោយចោទថាគាត់ក្បត់អង្គការ និងជាគេញសើុបការសុីអាយអេ ដូច្នេះ ទុកក៏មិនចំណេញ ដកចេញក៏មិនខាត។ ពេលនោះ ខ្ញុំរន្ធត់ចិត្តនិងឈឺចាប់ខ្លាំងណាស់ចង់តែស្រែកយំឲ្យខ្លាំងៗ។ ក្រោយរបបខ្មែរក្រហម ខ្ញុំបានបាត់បង់សាច់ញាតិសរុបទាំងអស់ចំនួន២៣នាក់ មានដូចជា ឪពុកម្តាយ ក្មួយ២នាក់ បងបង្កើត៥នាក់ បងថ្លៃស្រីទីបី (ស្លាប់ដោយសារជំងឺ ការបង្ខំឲ្យធ្វើការងារ និងគ្មានអាហារហូបគ្រប់គ្រាន់) និងកូនរបស់គាត់អាយុជាងមួយខួប (ស្លាប់ដោយសារគ្មានទឹកដោះបៅ និងជំងឺហើម) ឪពុកធំមួយគ្រួសារសមាជិក៧នាក់ និងម្តាយមីងមួយគ្រួសារសមាជិក៦នាក់។

# MRS. CHHIM VANNA

*Mrs. Chhim Vanna was born in 1960 at Prey Krabas village, Takeo province. She is a Civil Party in the Second Case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 17 April 1975, I saw a big group of the Khmer Rouge soldiers with rifles running to the barracks and pointing rifles at my family to expel us, and other soldiers did the same to other families, in total about twenty families. They said, *"move quickly, Angkar orders to move for only three days, no need to bring anything"*. Suddenly, four Khmer Rouge soldiers went inside our home and brought my possessions out. At 3 pm, the Khmer Rouge forced us to go in the east direction. On the way, the Khmer Rouge forced us to move forward quickly until midnight where they stopped us to rest in the forest. We cooked rice to eat with salt. Sometimes, the Khmer Rouge made us stay in a place that did not have any water, so we slept without having anything to eat.

After about one month, we reached Samrong Leu village, Samrong commune, Svay Leu district, Siem Reap province. The next day, the Khmer Rouge called all people to join a meeting and announced, *"all civil servants have to load into the truck to work at the ministry individually"*. Only men were brought to the truck, including my father and two brothers. The Khmer Rouge pushed those people into the truck forcefully and took them away. Meanwhile, the Khmer Rouge ordered us to dig trees, clear the forest during both day and night with insufficient food to eat. One week later, the Khmer Rouge transferred my remaining family (my mother, two nephews/nieces, two brothers, and one sister-in-law) to live in Kork Thlork village, Kork Thlork commune, Chi Kreng district, Siem Reap province. After living there for five days, my mother died of illness and starvation. The Khmer Rouge transferred us again to live in Sramor village, Chi Keng commune, Siem Reap province, situated along Chi Kreng Small River. Over there, the Khmer Rouge assigned me, only a teenage girl then, to work in the youth mobile unit. Sometimes, the Khmer Rouge assigned my mobile unit to work far from the village and made us cross a canal with deep water. I sometimes nearly drowned to death because I could not swim.

At the beginning of 1976, the Khmer Rouge arrested my two brothers, they were to be killed because they had allegedly betrayed Angkar and were CIA spies – *"keep no benefit, remove no loss"*. At that time, I felt very shocked, upset and wanted to cry loudly. After the Khmer Rouge regime, I had lost twenty three relatives: my parents, two nieces/nephews, five siblings, one sister-in-law (who died because of illness and starvation) and her child (one year old and a half, who died because there was no milk to breastfeed), the family of my uncle totaling seven members, and the family of my aunty totaling six members.

# លោកស្រី ហួរ ចន្ថា



*លោកស្រី ហួ ចន្ថា អាយុ ៦០ឆ្នាំ មានស្រុកកំណើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង។ លោកស្រីគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃអវសាននៃរបប លន់ នល់។ ស្នូរកាំភ្លើងគ្រាំគ្រេងនៅជ្រុងពោធិចិនតុង និងជុំវិញទីក្រុង តាំងពីព្រលប់រហូតដល់ភ្លឺ។ ថ្ងៃទី១៧ ខែមេសា ម៉ោង ៨ព្រឹក ខ្ញុំឃើញប្រជាជនក្បែរខាងគេឈរលើកទង់ជ័យស ចំណែកគ្រួសារនាងខ្ញុំក៏ឈរអបអរស្រែកជ័យយោតាមគេដែរ ព្រោះនឹកថាចប់ហើយសង្គ្រាម សន្តិភាពនឹងមានឡើងវិញហើយ។ ពេលនោះ មានទាហានខ្មែរក្រហមស្លៀកពាក់ឈុតខ្មៅ ទឹកមុខមាំក្មេងៗដើរតាមផ្លូវបន្តបន្ទាប់។ បន្តិចក្រោយមក ទាហានឈុតខ្មៅនេះ បានស្ពាយកាំភ្លើងស្រែកប្រាប់ថា *"ចេញ! ចេញ! មិនឲ្យនៅទីក្រុងទេ។ គេបោសសម្អាតទីក្រុង ៣ថ្ងៃ"*។ ពេលនោះ ខ្មែរក្រហមចេះតែដើរគំរាមឲ្យចេញឆាប់ៗដោយមានការបាញ់កាំភ្លើងទៀតផង។ សភាពការមិនបានដឹងមុននេះ ធ្វើឲ្យយើងភ័យតក់ស្លុកញ័រដៃញ័រជើង។ ខ្ញុំឃើញប្រជាជនណែនពេញផ្លូវខ្លះរែក ខ្លះទូល មានទាំងអ្នកជំងឺព្យួរសេរ៉ូមជាប់នឹងដៃជិះលើកង់ពីក្រោយ ស្ត្រីទើបកើតកូនថ្មីៗ ជនពិការ មនុស្សចាស់ដើរយ៉ាងហេវហត់ស្ទើរលើកជើងពុំរួច និងក្មេងយំទ្រហឹងទារឲ្យពរព្រោះឈឺជើង។ ខ្ញុំក៏បានឃើញខ្មោចទាហាន លន់ នល់ ដេកស្លាប់រដូករណែលតាមដងផ្លូវ។ គ្រួសារខ្ញុំ និងម្តាយក្មេកធ្វើដំណើរតាមព្រែកព្នៅសំដៅស្រុកគាត់នៅស្រុកពុកឫស្សី។

អស់រយៈពេល១៥ថ្ងៃទើបទៅដល់ដីភូមិម្តាយក្មេកខ្ញុំ។ នៅទីនោះយើងគ្មានទីជម្រកស្នាក់នៅទេ ត្រូវសង់ខ្ទមដោយខ្លួនឯង ជាមួយនឹងការហូបចុកមិនគ្រប់គ្រាន់។ ក្នុងខែមិថុនា ឆ្នាំ១៩៧៥ ឈ្លបខ្មែរក្រហមពីរនាក់បានមកដល់មុខផ្ទះ ហើយស្រែកហៅប្អូនថ្លៃប្រុសខ្ញុំឲ្យទៅប្រជុំមួយភ្លែត តាំងពីនោះមកប្អូនថ្លៃខ្ញុំបានបាត់ដំណឹងរហូតទល់សព្វថ្ងៃ។ នៅទីនោះ គេបានចាត់ខ្ញុំទៅច្រូតស្បូវ ដោយសារតែគ្មានស្បែកជើងពាក់ ធ្វើឲ្យជើងខ្ញុំមុតជញ្ជាំងស្បូវចេញឈាម ដើរពុំទាន់គេ ប្រធានក្រុមបានស្តីថា *"នារី១៧មេសា ទន់ជ្រាយ គ្មានចិត្តតស៊ូ"*។ នៅថ្ងៃបន្ទាប់ គេឲ្យទៅច្រូតកក់ ពេលក្រឡេកឃើញឈ្លើងហែលផ្ងារពោះខៀវក្នុងទឹក នាងខ្ញុំរន្ធត់ញាប់ញ័រស្ទើរលោះព្រលឹង ប្រធានក្រុមឃើញក៏ស្ទុះទៅច្រានខ្ញុំឲ្យចុះទឹក មិនឲ្យឡើងគោកទេ បើហ៊ានតែឡើង គេនឹងដាក់ពិន័យ។ ពេលខ្ញុំមានផ្ទៃពោះបានបីខែ គេឲ្យឃ្វាលគោប្អូន។ ខ្ញុំមិនដែលដឹកគោទេតាំងពីតូចមក ហើយខ្លាចគោប្រុសណាស់។ ថ្ងៃមួយគោបោសមែន តែសំណាងល្អមិនមានគ្រោះថ្នាក់ដល់កូនក្នុងផ្ទៃ។ បន្ទាប់មក គេប្រើឲ្យខ្ញុំចិញ្ចឹមជ្រូករហូតដល់ពេលសម្រាលកូន។ ពេលកូនកើតបានពីរខែ គេប្រើឲ្យខ្ញុំទៅឈូសពោតលាយបាយនៅមន្ទីរ។ កូនអាយុ៤ខែ គេឲ្យជាន់អំបិលទុកប្រឡាក់ត្រីប្រហុកផ្អក។ កូនអាយុ៦ខែ គេឲ្យរែងអង្ករ។ កូនអាយុមួយខួប គេឲ្យកិនស្រូវទាញត្បាល់ធំៗ ទុកកូនឲ្យនៅជាមួយយាយចាស់ៗមើល។

មានថ្ងៃមួយ គេឲ្យខ្ញុំទៅដាក់បាយជ្រូក ពេលនោះប្រធានក្រុមចិត្តកំណាចបានធ្វើបាបខ្ញុំ គេថា *"នារីឯងម៉េចក៏រែកតែកន្លះអញ្ចឹង អង្គាល់បានលាយឲ្យស៊ីទាន់វាឃ្លាន បើជ្រូកច្រើនយ៉ាងនេះ?"* ថារួចគេក៏ស្ទុះមកច្រានខ្ញុំឲ្យដួលលើអាចម៍ជ្រូកស្អុយពេញខ្លួន គួរឲ្យឈឺចាប់ណាស់ដែលកម្លាំងខ្ញុំខ្សោយមិនអាចរែកពេញប៉ោតឡើងច្រាំងទន្លេបាន។ ការឈឺចាប់ផ្លូវចិត្តព្រោះរងនូវការមើលងាយរើសអើងពីពួកកម្មាភិបាលថ្នាក់ក្រោម ព្រមជាមួយរាងកាយទ្រុឌទ្រោមដោយខ្វះសារជាតិអាហារ ខ្ញុំឈរស្ទើរទប់ខ្លួនពុំជាប់ព្រោះបាត់បង់ភាពកក់ក្តៅ និងសេចក្តីសង្ឃឹមទៅអនាគត។ ចំណែកប្តីខ្ញុំត្រូវគេចាត់ឲ្យទៅភ្ជួររាស់ និងទៅលើកទំនប់នៅកន្លែងឆ្ងាយ យូរៗមកផ្ទះម្តង។ ដោយសារការបង្ខំឲ្យធ្វើការ ប្តីខ្ញុំបានកើតជំងឺបេះដូងរីកតាំងពេលនោះមក ហើយជំងឺនេះបន្តរ៉ាំរ៉ៃរហូតដល់គាត់ស្លាប់ក្នុងឆ្នាំ១៩៩៥។ អំឡុងពេលនោះខ្ញុំមានជីវភាពលំបាកបំផុត ព្រោះយើងមានមុខរបរតិចតួចសម្រាប់ទ្រទ្រង់ជីវភាព។ ខ្ញុំត្រូវប្រឈមនឹងការចិញ្ចឹមបីបាច់កូនចំនួន៥នាក់តែម្នាក់ឯង និងមើលថែប្តីដែលកំពុងប្រឈមនឹងជំងឺត្រូវទៅពេទ្យជាញឹកញាប់ ធ្វើឲ្យខ្ញុំទប់ទល់ជីវភាពស្ទើរពុំបាន។

# MRS. HOUR CHANTHA

*Mrs. Hour Chantha, 60 years old, was born at Ba Phnom district, Prey Veng province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 29th May 2013.*

On 16 April 1975 was the end of the Lon Nol regime. From dusk till dawn the sound of gunfire was explosive at Pochentong area and around the city. At around 8am on 17 April, I saw people standing nearby, raising a white flag, while my family also stood to welcome because we thought that the war had ended and that peace would come. At that time, the young Khmer Rouge soldiers dressed in black uniforms with stern facial expressions walked along the road. Later, those Khmer Rouge soldiers with rifles shouted, *"Move! Move! No one is allowed to live in the city. The city needs to be cleaned up within three days"*. At that moment, the Khmer Rouge kept threatening us to leave urgently by shooting their guns. This unpredicted situation made us feel scared and our bodies trembled. I saw the crowd of people on the road, some carrying their belongings on their shoulder while others carried their belongings on their head. I saw a patient with an injection in hand sitting on the back of a bike, a lady who just given birth to her child, people with disabilities, the exhausted elderly walking, and the children crying loudly for their parents to carry them because their leg hurt from the long walk. I saw the dead bodies of Lon Nol soldiers lying down on the street.

My family and mother-in-law went through Prek Pnov to her homeland at Pok Russey district. It took about fifteen days to arrive in her home village. There we did not have any shelter, so we had to build some by ourselves and we had insufficient food to eat. In June 1975, two Khmer Rouge militiamen arrived in front of our shelter and called my brother-in-law to join a meeting for a while. He was never seen again.

I was assigned to harvest thatch. Because I could not wear shoes, I once stumbled and hurt my leg so I could not walk very fast. The village chief said, *"a 17 April lady is so weak and has no patience"*. The next day, I was sent to harvest reed and when I saw leeches in the water, I was shocked. Seeing this, the team chief rushed to push me into the water and would not allow me to get out, otherwise I would be punished. When I became three months pregnant, I was sent to tend four cows. I was afraid of that the cows would fight me. One day, a cow did fight with me, but luckily, it did not hurt my baby or me. They ordered me to feed the pigs until I gave birth to my baby. When my newborn baby was two months old, they assigned me to scrape corn to mix with cooked rice at the department. When my baby was four months old, they got me to paddle salt with fish to make fish paste. When my baby was six months old, they ordered me to screen rice. When my baby was one year old, I was assigned to mill rice by pulling a big pestle while my child was left with a granny to look after. One day, they ordered me to feed pigs. At that moment the vicious team chief mistreated me and said, *"why do you carry only a half loaded container, when it is on time for pigs to eat?"* Later the team chief rushed to push me down into the pig waste and covered my body with it. I felt a lot of suffering because I was so weak that I could not carry a full loaded container.

I have a lot of mental suffering from the discrimination from the lower Khmer Rouge cadres and my body is very weak because of malnutrition. My husband was assigned to plow in the rice field and build a dam in the distant areas; it was a long time before he came back home again. The Khmer Rouge made me feel like I was falling due to the loss of my hope for the future. Because he was forced to work hard, my husband suffered from a heart disease since that time, and he was constantly sick until he died in 1995. During that time, we had a very difficult life because we only had a small business to support our living. I felt alone in taking care of our five children, because I also had to look after my sick husband who frequently needed to go to the hospital, this made me feel like I was almost unable to support the living.

# លោក ជុំ សុខា



*លោក ជុំ សុខា កើតក្នុងឆ្នាំ ១៩៥៥ មានស្រុកកំណើតនៅខេត្តព្រៃវែង។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១២។ មុនឆ្នាំ១៩៧៥ ផ្ទះខ្ញុំនៅពោធិចិនតុង តែដោយសារមានគ្រាប់ផ្លោងចូលទីនេះ ឪពុកខ្ញុំបាននាំគ្រួសារមកនៅក្នុងបុរីកីឡា រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។*

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោងប្រាំបួន ខ្ញុំបានឮសម្លេងកាំភ្លើងផ្ទុះនៅទិសខាងលិចនៃកន្លែងដែលខ្ញុំរស់នៅ។ ខ្ញុំក៏បានឃើញប្រជាជនផ្អើលឈ្លូឆររត់ចុះឡើង និងខ្លះឈរអមផ្លូវ មានទាំងទាហានលន់ នល់ ខ្លះដោះអាវចេញនៅសល់តែខោប៉ារ៉ា ឬខោទាហាន កំពុងកាន់កន្សែងសឈរអមតាមផ្លូវ។ ខណៈនោះ ខ្ញុំក៏បានឈរអមផ្លូវជាមួយគេផងដែរ គឺយើងឈរដើម្បីទទួលស្វាគមន៍ក្បួនទ័ពខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ព្រោះយើងមានសេចក្តីត្រេកអរណាស់ ដោយគិតថាប្រទេសសន្តិភាព លែងមានការភិតភ័យដោយគ្រាប់ផ្លោង ឬការរត់គៀសខ្លួនទៀតហើយ។

ទ័ពខ្មែរក្រហមទាំងនោះមានលីអាវុធគ្រប់ធុន មូរជើងខោម្ខាង ខ្លះបង់កក្រមា ខ្លះយកក្រមាជួតក្បាល ខ្លះពាក់មួកប៉ារ៉េ ខ្លួនប្រឡាក់ដីស្រមកបន្ទាប់មកមានកងទ័ពរថក្រោះ និងកងទ័ពឡានមកតាមក្រោយ។ បន្ទាប់មក មានទាហានខ្មែរក្រហមមួយក្រុមបានកាន់មីក្រូដើរស្រែកថា *“បងប្អូនប្រជាជននៅទីក្រុងភ្នំពេញទាំងអស់ គឺអត់មានទោសពៃណ៍អីទេ។ បងប្អូនប្រកបការងារអ្វីតាមចិត្តទៅ រកស៊ីអ្វីតាមចិត្តទៅ ប៉ុន្តែអង្គការយកទោសតែបនក្បត់០៧ក្បាល មាន លន់ នល់ សិរិមតៈ អ៊ិនតាំ ចេងហេង...”*។ ដល់ម៉ោងប្រហែលជា៣រសៀល មានក្រុមទាហានខ្មែរក្រហមបានស្រែកប្រកាសតាមមីក្រូឲ្យប្រជាជនចេញពីភ្នំពេញជាបន្ទាន់ រយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ពីព្រោះយប់នេះ ឬបន្តិចទៀតយន្តហោះអាមេរិកមកនឹងទម្លាក់គ្រាប់បែក ហើយមិនចាំបាច់យកអីវ៉ាន់ទេ។ ពេលនោះ ឪពុកខ្ញុំបានបើកឡានហ្ស៊ីបនាំគ្រួសារចាកចេញពីភ្នំពេញតាមផ្លូវពោធិចិនតុងទៅសម្រាកចោមចៅមួយយប់។

ស្អែកឡើង យើងបានបន្តដំណើរទៅមុខទៀតតាមផ្លូវជាតិលេខ៣ រួចបានឆ្លងស្ទឹងមួយទៅត្រើងម្ខាង (ចំណុចកំពង់ទួល ស្រុកកណ្តាលស្ទឹង)។ នៅកន្លែងនោះ មានបុស្តិ៍ឆែកឆេររបស់ខ្មែរក្រហមមួយកន្លែង គេបានដកហូតយកឡានហ្ស៊ីបយើង រួចបានស្នើឲ្យឪពុកនិងពូខ្ញុំទៅប៉ុស្តិ៍ដើម្បីគេសួរនាំ ចំណែកម្តាយខ្ញុំ ប្អូនខ្ញុំ យាយតា មីង និងខ្ញុំ គេឲ្យដើរទៅមុខបន្តទៀត។ ដើរបានប្រហែល២គីឡូម៉ែត្រ ឪពុកនិងពូខ្ញុំដើរមកតាមក្រោយ។ ឪពុកខ្ញុំបានប្រាប់ថា គាត់ឃើញមនុស្សជាច្រើនត្រូវគេចងជាមួយខ្សែអំបោះ (ដេរបាវអង្ករ) ជាជួរៗនៅទីនោះ គាត់ខ្លាចណាស់ ទើបលួចរត់មក។ យើងបានស្រូតដំណើរទៅមុខរហូតដល់ខ្លោងទ្វារវត្តអង្គក្រូចនៅជាប់ផ្លូវជាតិលេខ៤។ បន្ទាប់មក យើងបានធ្វើដំណើរជាច្រើនដំណាក់ទៀត ទើបទៅដល់ស្រុកកំណើតនៅភូមិត្បូងក្តី ឃុំដំរីពួន ស្រុកព្រៃវែង ខេត្តព្រៃវែង។ នៅភូមិកំណើត អ្នកភូមិដែលធ្លាប់រាប់អានឪពុកខ្ញុំ ពុំសូវរាក់ទាក់ជាមួយឪពុកខ្ញុំទេ។ គ្រួសារខ្ញុំត្រូវបានគេចាត់ឲ្យទៅនៅតាមក្រុមផ្សេងៗគ្នា។ ឪពុកខ្ញុំនៅធ្វើការឲ្យអង្គការបានប្រហែល១០ថ្ងៃ ស្រាប់តែគេមកចាប់គាត់យកទៅរៀនសូត្រនៅមន្ទីរសន្តិសុខត្រពាំងលាក់ត្បាល់ ខាងកើតភូមត្បូងក្តី ព្រោះគេថាគាត់ជាប់និន្នាការទាហានលន់ នល់។

ក្រោយមកទៀត ពូខ្ញុំ ឈ្មោះ មាឃ ត្រូវគេចាប់យកទៅឃុំនៅមន្ទីរសន្តិសុខភូមិសំរោង។ គេបានយកគាត់ទៅទឹមជាមួយអ្នកទោសម្នាក់ទៀតដើម្បីអូសរទេះដឹកអុស និងឈើនៅវត្តត្បូងក្តី ហៅវត្តបញ្ជី។ ចំណែកការរស់របស់ខ្ញុំវិញ គឺត្រូវបានគេបញ្ជូនទៅធ្វើការនៅសហករណ៍ ដូចជា ជីកប្រឡាយ, លើកទំនប់, ឡើងកាប់ស្លឹកត្នោត, ភ្ជួររាស់, ដកស្ទូង, ធ្វើជីធម្មជាតិ (រក និងសែងលាមក, ទឹកនោមនៅតាមផ្ទះ) នៅពេលធុំក្លិនស្អុយខ្លាំង ខ្ញុំបានយកក្រមាបិទមាត់ តែត្រូវពួកខ្មែរក្រហមចោទថាខ្ញុំមិនស្មោះត្រង់នឹងអង្គការ។ ថ្ងៃមួយ អង្គការបានចាប់ខ្ញុំយកទៅដាក់មន្ទីរសន្តិសុខទួលបាស្រី ស្រុកបាភ្នំ។ នៅទីនោះ ជើងខ្ញុំត្រូវបានគេដាក់ខ្នោះ រីឯដៃត្រូវបានគេចងស្លាបសេក។ គេបានសួរចម្លើយខ្ញុំ ដោយវ៉ៃជាមួយរនុកទ្វារត្រង់ក្បាលជង្គង់ស្មា និងខ្នង ដោយពុំដឹងថាខ្លួនឯងមានទោសអី។

# MR. CHUM SOKHA

*Mr. Chum Sokha was born in 1955 at Prey Veng province. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 22 October 2013. Before 1975, my family lived in Pochentong area. Because of the bombing in this area, we moved to Borey Keila area until 17 April 1975.*

On 17 April 1975, at 9 am, I heard the sound of gunfire to the west of my living place. I saw people moving up and down, while some were standing along the road holding white pieces of fabric, including some Lon Nol soldiers. I stood on the road with the others – we wanted to welcome the march of Khmer Rouge soldiers entering Phnom Penh city because we felt great pleasure that the country was in peace, that there was no threat of explosions, and that the people did not have to flee anymore. The Khmer Rouge soldiers carried all kinds of weapons. The soldiers had one side of their trousers rolled up, some wore scarves around their necks, some wore Pa Re hat while others put scarves around their heads. Their bodies were covered with mud and there were tank and army forces coming after them. After these soldiers passed, another group of Khmer Rouge soldiers carried loudspeakers that announced, *"all people in Phnom Penh city do not have to be guilty. You all can do the things that you want, because Angkar punished only seven traitors namely Lon Nol, Serei Matak, Cheng Heng,… and so on"*.

At about 3 pm, the Khmer Rouge came to announce through the loudspeakers that the people had to *"leave from Phnom Penh urgently for only three days, because on this night or a bit later the American aircrafts will bomb this city, no need to take belongings"*. At that time, my father took our family in our Jeep car along Pochentong Street to stay at Choam Chau area for the night. We kept moving forward the next day on the National Road No. 3 and we passed one small river to the other side (Kampong Tuol area, Kandal Stung district). On that side, there was a checkpoint of Khmer Rouge soldiers. They confiscated our Jeep car and told my father and uncle to go to the checkpoint to provide some information, while my mother, siblings, grandparents, auntie and I kept moving forward. Walking about two kilometers, my father and uncle walked after us. My father told me that he saw many people were tied up in lines with thread (used to swing rice sack). He feared that we should escape quickly from there. We speeded up our journey until we arrived at the gateway of Angk Kroch pagoda linked to the National Road No. 4.

We passed many places before we reached our homeland in Tbong Kdei village, Damrei Puon commune, Prey Veng district, Prey Veng province. In the village, the villagers who used to respect my father were no longer friendly towards my father. My family was assigned to live in different units. My father worked for Angkar for about ten days, before the Khmer Rouge took him for reeducation at Trapaing Leak Tbal security center at the east of Tbong Kdei village. The Khmer Rouge alleged he was a Lon Nol soldier. My uncle Meakh was arrested and detained at Sam Rong village's security center. The Khmer Rouge took him to work with another prisoner to pull the cart in order to transport wood to Tbong Kdei pagoda (so-called Banhchy pagoda).

I was sent to work in the cooperative. I had to dig a canal, build a dam, climb up palm trees to cut its leaves, plow in the rice field, pull out and transplant rice seedlings, make fertilizer by collecting and carrying waste along the houses. When the smell was too much, I covered my mouth with my scarf but the Khmer Rouge alleged I was not honest with Angkar. One day, I was arrested and put in the Tuol Basrey security center at Ba Phnom district. The Khmer Rouge shackled my legs and tied my hands behind my back. I was beaten with the bolt of a door on my knee, shoulders, and back, without ever knowing what mistake I had made.

# លោក សឿន សុវណ្ណី



*លោក សឿ សុវណ្ណី អាយុ ៥៧ឆ្នាំ មានស្រុកកំណើតនៅក្រុងភ្នំពេញ។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៣។*

ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ។ គេបានបង្ខំឲ្យគ្រួសារខ្ញុំចេញពីផ្ទះស្ថិតនៅក្បាលមាន់ចៃ ផ្សារដើមគរ ក្រុងភ្នំពេញ។ ពេលនោះគ្រួសារខ្ញុំមានសមាជិកសរុប១៣នាក់។ ដោយសារផ្លូវចង្អៀតណែនដោយហ្វូងមនុស្ស គ្រួសារខ្ញុំបានបែកគ្នាពេលមកដល់ក្បាលថ្នល់ ដូច្នេះខ្ញុំមិនដឹងថាឪពុកម្តាយ និងបងប្អូនខ្ញុំដែលមានគ្នាទាំងអស់១១នាក់ បានដើរតាមផ្លូវណាទេ។ ពេលនោះ ខ្ញុំនិងបងស្រីបានដើរតាមផ្លូវចាក់អង្រែរហូតដល់ស្រុកស្អាង ខេត្តកណ្តាល។ ពេលរស់នៅទីនោះ ខ្ញុំបានជួយរែកទឹកឲ្យអ្នក១៨មេសាម្នាក់ ហើយគាត់បានខ្សឹបប្រាប់ខ្ញុំថា *“បើគេសួរប្រវត្តិថាធ្វើការអ្វីនោះ ឯងត្រូវប្រាប់គេថាធ្វើស្រែ ធ្វើចំការ ទើបអាចមានជីវិតរស់”*។ ក្រោយមក ពួកខ្មែរក្រហមបានមកសួរនាំអំពីប្រវត្តិរបស់ខ្ញុំ ខ្ញុំបានប្រាប់ថា ខ្ញុំជាកូនវណ្ណៈកសិករ ចំណែកក្រុមគ្រួសារត្រូវអាបេសែងកងដីទម្លាក់កណ្តាលផ្ទះស្លាប់អស់ហើយ។ បន្ទាប់មក ខ្មែរក្រហមបាន ចាត់ឲ្យខ្ញុំទៅនៅក្នុងក្រុមយុវជនចល័ត រីឯបងស្រីទៅនៅកងនារីចល័ត។ គេឲ្យយើងសែងដី លើកទំនប់ និងធ្វើស្រែក្នុង ការដ្ឋានកោះតូច ហើយគេចែកបបរឲ្យយើងហូបតែមួយកូនចានតូចក្នុងមួយពេល។ នៅស្រុកស្អាងនេះ គេបានបែងចែកអ្នក១៨មេសាមុំ អ្នក១៧មេសាមុំ និងអ្នកកម្ពុជាក្រោមមុំ មិនឲ្យរស់នៅលាយឡំគ្នាទេ។

ថ្ងៃមួយ ខ្ញុំឮគេ និយាយថាយកអ្នកកម្ពុជាក្រោមឲ្យទៅធ្វើចម្ការ ខ្ញុំបានសុំគេទៅដែរ ស្រាប់តែគេថា *“មិនបាច់ទៅទេ មិត្តឯងទៅធ្វើអី គេទៅធ្វើចម្ការ”*។ លុះក្រោយមក ខ្ញុំបានលួចសួរគេ ទើបបានដឹងថា គេយកអ្នកទាំងនោះទៅសម្លាប់ចោល។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅនៅអង្គភាពកងស្ទែងដើម្បីដឹកជញ្ជូនគ្រាប់បំរើដល់សមរភូមិមុខ។ ពេលមកធ្វើការនៅអង្គភាពនេះ ខ្មែរក្រហមមិនជឿទុកចិត្តខ្ញុំទេ ព្រោះខ្ញុំជាខ្មែរកម្ពុជាក្រោម ពួកគេបានចោទខ្ញុំថា ក្បាលយួន ខ្លួនខ្មែរ ហើយគេតាមដានខ្ញុំគ្រប់ពេលវេលា។ នៅដើមឆ្នាំ១៩៧៨ ដោយសារសេចក្តីភ័យខ្លាចថាថ្ងៃណាមួយ នឹងត្រូវគេយកទៅសម្លាប់ចោល ខ្ញុំបានលួចរត់ចេញពីកងស្ទែងទៅជាមួយបងប្អូនខ្មែរក្រោម និងជនជាតិវៀតណាមជាច្រើននាក់ទៀត។ ពេលនោះ ពួកខ្មែរក្រហមបានដេញតាមបាញ់ពីក្រោយ ធ្វើឲ្យអ្នកលួចរត់ជាច្រើនត្រូវបានស្លាប់។ ពេលរត់ដល់កំពង់ចម្លង ខ្ញុំបានបន្លំខ្លួនឡើងសាឡាជាមួយបងប្អូនជនជាតិវៀតណាមឯទៀត រួចបន្តដំណើរអស់រយៈពេលជាច្រើនថ្ងៃទើបទៅដល់ផ្ទះម្តាយចុងខ្ញុំនៅភ្នំយាយម៉ៅ ខេត្តរោងដំរី (បច្ចុប្បន្នហៅខេត្តតៃនីញ) ប្រទេសវៀតណាម (ដែលជាទឹកដីខ្មែកម្ពុជាក្រោម)។ នៅទីនេះបានប្រហែលមួយសប្តាហ៍ ម្តាយចុងខ្ញុំបានបញ្ជូនខ្ញុំទៅនៅស្រុកកំណើតឪពុកខ្ញុំឯស្រុកថ្កូវ ខេត្តព្រះត្រពាំង (បច្ចុប្បន្នហៅខេត្តត្រាវិញ) ប្រទេសវៀតណាម (ដែលជាទឹកដីខ្មែរកម្ពុជាក្រោម)។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ជាពេលដែលរដ្ឋាភិបាលវៀតណាមានផែនការកេណ្ឌកម្លាំងទ័ពដើម្បីបញ្ជូនមកប្រទេសកម្ពុជា ដើម្បីចូលរួមជាមួយកងទ័ពរណសិរ្សវាយប្រឆាំងនឹងរបបខ្មែរក្រហម ពេលនោះខ្ញុំបានស្ម័គ្រចិត្តចូលបំរើក្នុងជួរកងទ័ពវៀតណាមជាមួយនឹងបងប្អូនយុវជនខ្មែរកម្ពុជាក្រោមជាច្រើននាក់ទៀត ដោយសង្ឃឹមថានឹងមានឱកាសបានវាយកំចាត់ពួកខ្មែរក្រហម និងរំដោះឪពុកម្តាយ និងបងប្អូនខ្ញុំ រួមទាំងប្រជាជនកម្ពុជាឲ្យរួចផុតពីរបបនរកនេះ។ ប៉ុន្តែ អ្វីដែលនឹកស្មានមិនដល់ ហើយធ្វើឲ្យខ្ញុំសោកសៅស្ទើរឆ្កួតម្តងទៀតនោះ គឺឪពុកម្តាយ និងបងប្អូនខ្ញុំត្រូវពួកខ្មែរក្រហមសម្លាប់ចោលស្ទើរផុតពូជ។ ខ្ញុំខំព្យាយាមស្វែងរកពួកគាត់ស្ទើរគ្រប់ទីកន្លែង តែរកមិនឃើញទាល់តែសោះ។ ក្រោយមក ទើបខ្ញុំបានទទួលដំណឹងថា បងស្រីខ្ញុំម្នាក់ និងប្អូនស្រីខ្ញុំម្នាក់នៅរស់។

# MR. SOEUN SOVANDY

*Mr. Soeun Sovandy, 57 years old, was born in Phnom Penh city. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 4 June 2013.*

In April 1975, the Khmer Rouge soldiers entered Phnom Penh city. They forced my family to leave our home in Kbal Moan Che area, Deum Kor Market, Phnom Penh city. At that time, my family had a total of thirteen members. As the road was narrow and crowded my family members were separated when we arrived in Kbal Thnal area, so I did not know which way my parents and other relatives (in total eleven people) went. My older sister and I went through Chak Angkre Street until we reached Saang district, Kandal province. While living in there, I helped carry water for a man (who was an 18 April people), and he whispered to me *"if someone comes to ask what job you did before, you have to tell them that you worked in the farm, so you can survive"*. When the Khmer Rouge came to ask my background, and I told them *"I am a child of peasant class, my family members already died during the bomb dropped on my home"*.

The Khmer Rouge sent me to live in the youth mobile unit and my older sister went to live in the female youth mobile unit. We were forced to carry land, build a dam, and farm in the Koh Toch working site, and they offered us only a small bowl of watery porridge to eat. In Saang district, they separated the people. The 18 April people lived on one side, and the 17 April people lived on the other side. The Khmer Rouge did not allow us to mix. One day, I heard the Khmer Rouge saying they had taken the Khmer Krom people to work in the farm. I asked if I could go as well, but they replied *"no need to go, why do you want to go over there, those just go to work in the farm"*. Later, I secretly asked someone about this and learnt those people were being sent to be killed.

In November 1977, the Khmer Rouge sent me to the carrier unit in order to carry weapons and military equipment to the battlefield. Upon working in this unit, the Khmer Rouge never trusted me as I was Khmer Krom people. They alleged that I was *"a Khmer body with Vietnamese head"*, and they kept track of me at all times. In early 1978, I feared I would be killed someday so I fled from the carrier unit with other Khmer Krom people and Vietnamese people. The Khmer Rouge chased and shot us, killing many escapees. When running to the dock, I mixed myself with other Vietnamese people on the ferry and traveled for many days until I arrived at my stepmother's home at Yeay Mao Mountain at Rong Damrei province (presently Tay Ninh province), Vietnam.

After staying there for about one week, my stepmother sent me to live in my father's homeland at Thkov district, Preah Trapaing province (currently Tra Vinh province), Vietnam. In November 1978, the time that the Vietnamese government was planning to mobilize the arm forces to send to Cambodia in order to join with the United Front Forces to fight against the Khmer Rouge regime, I volunteered to join in the Vietnamese troops with other Khmer Kampuchea Krom youth people, by hoping that we would disperse the Khmer Rouge soldiers and liberate Cambodian people including my parents and relatives from this hell regime. But, what I could not guess and made me more regretful and almost become mad once again was that my parents and relatives were killed by the Khmer Rouge. I made effort to seek out all of them everywhere but was not able to. After that I only receive information that my older sister and younger sister were still alive.

ផ្នែក ៣

Chapter 3

# ការជម្លៀសដោយបង្ខំដំណាក់កាលទីពីរ

## Forced Transfer Phase Two


Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោកស្រី សូផាន់ សូវណ្ណី



*លោកស្រី សូផាន់ សូវណ្ណី មានអាយុ ៥៧ឆ្នាំ មានស្រុកកំណើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ។ លោកស្រីគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ ដែលបានផ្តល់សក្ខីកម្មក្នុងសវនាការអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំនៅផ្ទះជួបជុំគ្នា។ ខ្ញុំក៏បានឮសូរគេប្រកាសតាមមីក្រូថា *"បងប្អូនត្រូវចាកចេញពីទីលំនៅ បើមិនចាកចេញទេនឹងមានការទម្លាក់គ្រាប់បែកពីអាមេរិកាំង"*។ ឮដូច្នេះ ខ្ញុំមិនជឿទេ ខ្ញុំក៏បានចេញទៅផ្លូវថ្នល់ដើម្បីស្តាប់ទៀត តែនៅឮសូរការប្រកាសដោយប្រើពាក្យដដែលៗ។ ខ្ញុំរត់មកផ្ទះប្រាប់ឪពុកម្តាយអំពីអ្វីដែលខ្ញុំបានឮ។ ឪពុកម្តាយខ្ញុំមិនជឿថាមានការទម្លាក់គ្រាប់បែកទៀតទេ។ និយាយមិនទាន់ផុតផង មានខ្មែរក្រហមបីបួននាក់បានដើរមកដល់មុខផ្ទះខ្ញុំ ស្រែកថា *"ចាំអង្គាល់ទៀត មិនរៀបចំអីវ៉ាន់ចេញ! នៅទ្រេតទ្រោតដល់ណាទៀត ល្មមចេញហើយ! គេចេញគ្រប់គ្នាហើយ"*។ ក្រុមគ្រួសារខ្ញុំភិតភ័យណាស់ ពេលឮការស្រែកសម្លុតឲ្យចាកចេញ។ មិនទាន់បានរៀបចំអីវ៉ាន់ស្រួលបួលផង យើងបានឮសូរកាំភ្លើងពីរបីគ្រាប់បាញ់ឡើងលើជិតផ្ទះ ធ្វើឲ្យយើងកាន់តែភ័យរន្ធត់។ យើងបានចេញដល់ផ្លូវថ្នល់ដែលមានមនុស្សកកកុញណែនណាន់តាន់តាប់។ គ្រានោះ មានគ្រួសារមួយបានលើកដៃសំពះសុំយោធាខ្មែរក្រហមថា *"ក្មួយអើយ ឲ្យខ្ញុំសុំទៅរកកូនវិញនៅក្នុងផ្ទះ"* គេបានស្រែកសម្លុតថា *"មិនឲ្យទៅក្រោយវិញដាច់ខាត មានតែទៅមុខ"*។ យោធាខ្មែរក្រហមទាំងនោះមានស្ពាយកាំភ្លើងភ្ជង់អរេង់ពេញផ្លូវជំរុញឲ្យយើងធ្វើដំណើរទៅមុខជានិច្ច។ ពេលទៅជិតដល់ខេត្តកំពង់ធំ ព្រោះតែអស់កម្លាំងហេវហត់ពេក យើងបានសម្រាកនៅក្នុងវត្តមួយដែលគ្មានមនុស្ស គ្មានព្រះសង្ឃ។ នៅល្ងាចថ្ងៃបន្ទាប់មានឈ្លបខ្មែរក្រហមបីបួននាក់ដើរមកសួរនាំឪពុកខ្ញុំ ហើយប្រាប់យើងឲ្យរស់នៅទីនេះ។ នៅទីនេះ ប្រធានភូមិបានឲ្យក្រុមគ្រួសារខ្ញុំចុះទៅដកសំណាប។ យើងដកបានយឺតព្រោះយើងមិនធ្លាប់ដក គេក៏បំផ្លោងភក់ជះមកគ្រួសារខ្ញុំ។ នៅថ្ងៃទី៥ ឪពុកខ្ញុំបានសុំប្រធានភូមិថាចងទៅរកឪពុកម្តាយនៅខេត្តកំពង់ធំ តែប្រធានភូមិថាចាំទៅសួរថ្នាក់លើសិន បន្តិចក្រោយមកមានឈ្លបបីបួននាក់ដើរមកស្តីឲ្យឪពុកខ្ញុំ។

ស្អែកឡើង មានពូម្នាក់បានមកខ្សឹប ប្រាប់ឪពុកខ្ញុំថា *"ខ្មែរក្រហមគ្រោងយកគ្រួសារអ្នកឯងទៅសម្លាប់ចោលហើយ ព្រោះគេថាអ្នកឯងជានាយទុន ចង់យកកូនរត់ គេចវេះមិនចង់ធ្វើការនៅទីនេះ"*។ ឪពុកខ្ញុំភ័យណាស់ លុះយប់ងងឹតគាត់បាននាំប្រពន្ធកូនរត់ចេញពីទីនេះ។ យើងទៅរហូតដល់ភូមិរកាកោង។ នៅភូមិនោះ ខ្មែរក្រហមបានអនុញ្ញាតឲ្យយើងស្នាក់ក្រោមផ្ទះអ្នកមូលដ្ឋានមួយដែលត្រូវជាក្មួយឪពុកខ្ញុំ។ មួយរយៈក្រោយមក អង្គការចុះឈ្មោះប្រមូលប្រជាជនថ្មីចេញពីភូមិទៅធ្វើស្រែនៅខេត្តពោធិសាត់ និងបាត់ដំបង។ យើងត្រូវបានគេដឹកតាមកាណូតមកព្រែកតាម៉ាក់ខាងកើតភ្នំពេញ។ សម្លេងក្មេងៗយំរកបាយហូបទ្រហឹងពេញកាណូត រីឯម្តាយខ្ញុំយកចានដួសទឹកទន្លេឲ្យកូនផឹក លួងលោមកូនកុំឲ្យយំ អោបកូនជាប់នឹងខ្លួនដោយខ្លាចខ្មែរក្រហមបោះកូនទៅក្នុងទឹក។ មកដល់ច្រាំង ខ្មែរក្រហមបានញាត់យើងចូលក្នុងឡានចេញដំណើរទៅកាន់ចំណតរទេះភ្លើង។ ពេលរទេះភ្លើងដល់ពោធិសាត់ ខ្មែរក្រហមបានបន្តដឹកយើងមកទំលាក់ចោលនៅតំបន់ព្រៃក្នុងសហករណ៍ពោធិពីរ ស្រុកកណ្តៀង ខេត្តពោធិសាត់។ យើងលំបាកវេទនាណាស់នៅទីនោះ ព្រោះគ្មានទីជម្រក គ្មានអាហារបរិភោគ យើងត្រូវកាប់ព្រៃសង់ជម្រកដោយខ្លួនឯង។ គ្រួសារខ្ញុំត្រូវព្រាត់ប្រាស និងបាត់បង់។ ឪពុកឈឺស្លាប់នៅមន្ទីរពេទ្យ បងស្រីម្នាក់និងប្អូនស្រីពីរឈឺស្លាប់ ចំណែកប្អូនប្រុសពៅអាយុ ៨ឆ្នាំ ក៏ស្លាប់ដោយសារការអត់អាហារ។

# MRS. SOPHAN SOVANNDY

*Mrs. Sophan Sovanndy, 57-year-old, was born in Sangkat 1, Phnom Penh city. She is a Civil Party in Case 002 who testified before the Extraordinary Chambers in the Courts of Cambodia (ECCC) on 30 June 2013.*

On 17 April 1975, my family was together at home when I heard the announcement through loudspeakers that *"all the people have to leave from home, if not move, there will be bomb by American aircrafts"*. I did not believe what I heard so I went to the main road to listen, but I still heard the same. I ran back home to tell my parents about what I had heard. My parents did not believe the announcement about the American bombing. Before we could finish the conversation, there were four Khmer Rouges at the front of our home shouting *"Why not prepare belongings to move! It is time to move! Other people already moved"*. My family was fearful when we heard the threats to leave. We had not prepared our belongings completely when we heard the sound of gunfire nearby the house, which made us even more frightened. We walked to reach the very crowded road. At that moment, one family begged the Khmer Rouge military, *"nephew, let me go to seek out my children at home"* to which the Khmer Rouge shouted threateningly, *"not go back, absolutely move forward!"*

The Khmer Rouge militaries pointed rifles on the road to force us keep going. When we were close to Kampong Thom province, we stayed in one pagoda that had no people or monks inside, as we were exhausted and hungry. The next evening, three or four Khmer Rouge militiamen came to speak with my father and told us to stay here. The village chief ordered my family to transplant in the rice field. We pulled out the seedlings very slowly because we had never done this work before, and they threw mud on us. On the fifth day, my father asked the village chief if he could go to find his parents at Kampong Thom province, but the village chief said that to let him go he must ask the upper level. A bit later three or four Khmer Rouge militiamen came to blame my father.

The next day, one uncle whispered to my father, *"the Khmer Rouge plans to bring your family to be murdered, because they allege that you are a capitalist, that you do not want to work here and that you want your family to escape"*. My father felt very scared and that night he took his wife and us children to flee from that place. We kept going until we reached Roka Kaung village. In that village, the Khmer Rouge allowed us to stay under a house of the base people. One of them was my father's nephew.

A short time later, Angkar listed down the new people's names in order to bring them to live in Pursat and Battambang province. We were loaded onto a small motor-driven boat to Prek Tamak area at the east of Phnom Penh. On the boat I heard the sound of children crying loudly, demanding food to eat, while their mothers tried to give them water from the river to feed them and stop their crying. The mothers hugged their children with all of their body because they feared the Khmer Rouge would throw them into the river.

When the boat reached the bank, the Khmer Rouge put us onto trucks and transported us to the railway station. When the train arrived in Pursat, the Khmer Rouge sent us into the jungle area situated in Pour Pir cooperative, Kandieng district, Pursat province. We lived with difficulty over there, because there was no shelter or food, and we had to clear the forest to build shelters by ourselves. My family was separated and lost. My father died in hospital, my older sister and two younger sisters died because of illness, and my youngest brother, only eight years old, died from starvation.

# លោកស្រី យឹម សុវណ្ណ



*លោកស្រី យឹម សុវណ្ណ កើតក្នុងឆ្នាំ១៩៦០ មានស្រុកកំណើតនៅស្រុកស្អាង ខេត្តកណ្តាល។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី១៩ និងថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ហើយទាហានលន់ នល់ បានទំលាក់អាវុធចុះចូលជាមួយទាហានខ្មែរក្រហម។ ពេលនោះ ខ្ញុំមានអារម្មណ៍ឆ្ងល់ និងរន្ធត់ក្នុងចិត្តព្រោះឃើញកងទ័ពខ្មែរក្រហមបានរំលោភបំពានលើប្រជាជន និងកងទ័ពលន់ នល់។ ជាក់ស្តែងនៅចំណុចវត្តព្រះពុទ្ធ នាងគង្ហីងព្រះធរណី ពេលកំពុងដឹកដៃប្អូនរត់រកមើលពូដែលជាទាហានលន់នល់ ខ្ញុំបានឃើញទាហានខ្មែរក្រហម កាត់សក់ខ្លី ពាក់ខោអាវខ្មៅ មួរជើងខោ និងបង់កក្រមា កាន់កាំភ្លើងគ្រប់ដៃ ដើរសម្លុតប្រជាជន។ អ្នកខ្លះត្រូវបានខ្មែរក្រហមវ៉ៃនឹងស្វាយកាំភ្លើង ឯខ្លះទៀតត្រូវបានខ្មែរក្រហមចងស្លាបសេក។

នៅថ្ងៃនោះ ខ្មែរក្រហមបានប្រាប់យើងថា *“ឲ្យចេញតែបីថ្ងៃទេ មិនបាច់យកអីទៅក៏បានដែរ ទៅតែខ្លួនទទេក៏បានដែរ ខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែកងាប់”*។ នៅម៉ោងប្រហែល ៣ល្ងាច ខ្ញុំបានឃើញទាហានខ្មែរក្រហមមានស្ពាយកាំភ្លើង និងស្នូគបាយ បានមកសួរឪពុកខ្ញុំថា *“ចេញមិនចេញ បើមិនចេញប្រយ័ត្នអាមេរិកាំងទម្លាក់គ្រាប់បែកងាប់ ហើយបើមិនចេញនឹងសម្លាប់ចោល”*។ ឮដូច្នោះ ឪពុកខ្ញុំក៏បង្ខំចិត្តរៀបចំអីវ៉ាន់បានត្រឹមតែខោអាវ និងអង្ករបន្តិចបន្តួចចាកចេញដោយវេទនាបំផុត។ ការគំរាមនេះបានធ្វើឲ្យខ្ញុំនឹកឃើញដល់ហេតុការណ៍នៅម្តុំផ្សារអូរឫស្សីពេលដឹកដៃប្អូនត្រឡប់ពីផ្សារអូរឫស្សីមកផ្ទះវិញ បានឃើញពួកទាហានខ្មែរក្រហមគោះទ្វារផ្ទះមួយឲ្យបើកទ្វារ តែមិនមានអ្នកបើកទេ ខ្មែរក្រហមបានយកកាំភ្លើងបាញ់សោរផាំងៗ ហើយទាញយកមនុស្សពីក្នុងផ្ទះបាញ់សម្លាប់ចោលនៅមាត់ទ្វារតែម្តង។ គ្រួសារខ្ញុំបានត្រូវជម្លៀសពីភ្នំពេញឲ្យទៅនៅស្រុកកោះធំ ខេត្តកណ្តាល។ នៅទីនោះ ខ្មែរក្រហមបានហៅអ្នកជម្លៀសពីភ្នំពេញថាជាប្រជាជន១៧មេសា។ អ្នកទាំងនោះត្រូវបានគេចាត់ទុកថាជាខ្មាំង នាយទុន វណ្ណៈសក្តិភូមិ ហើយការហូបក៏មិនគ្រប់គ្រាន់។

រីឯប្រជាជនមូលដ្ឋានវិញ ត្រូវបានគេចាត់ទុកជាអ្នកបដិវត្តន៍មានហូបគ្រប់គ្រាន់ និងមានអង្ករស្តុកទុកខ្លួនឯងទៀតផង។ មិនតែប៉ុណ្ណោះខ្មែរក្រហមបានតម្រូវឲ្យអ្នក១៧មេសាធ្វើការងារធ្ងន់ជាងអ្នកមូលដ្ឋាន។ នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំជាលើកទី២ឲ្យទៅនៅសហករណ៍ក្បាលឈើពុក ឃុំទី៩ ស្រុកកណ្តៀង ខេត្តពោធិសាត់។ នៅទីនោះ ខ្ញុំបានត្រូវគេប្រជុំកសាង រិះគន់ទិតៀនរាល់ពេល ដោយចោទថាខ្ជិលច្រអូស គេចវេសពីការងារ ឈឺជំងឺញាក់ ជំងឺញ័រ ជំងឺសតិអារម្មណ៍។ ក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ឪពុកខ្ញុំ និងអ្នកនៅក្នុងកងជាមួយ២នាក់ទៀត ដោយចោទថាជាខ្មាំងស៊ីរូងផ្ទៃក្នុង។ ខ្ញុំយំ ពេលឃើញឪពុកត្រូវគេចងស្លាបសេក តែឈ្លបទាំងនោះហាមមិនឲ្យខ្ញុំយំទេ វាថានរណាយំអ្នកនោះជាខ្មាំងស៊ីរូងផ្ទៃក្នុង។ ឪពុកខ្ញុំបានសុំអង្វរពួកឈ្លបថា *“ខ្ញុំសុខចិត្តទទួលថាជាខ្មាំងចុះ តែសុំកុំសម្លាប់ប្រពន្ធនិងកូនខ្ញុំអី”*។ បន្ទាប់មកពួកវាបានបណ្តើរគាត់ និងអ្នកកងចល័តពីរនាក់នោះ យកទៅសម្លាប់នៅមន្ទីរ០៧ (វត្តបន្ទាយយួន)។ ពេលបណ្តើរទៅតាមផ្លូវ ពួកវាបានស្រែកប្រកាសថា *“នេះជាខ្មាំងស៊ីរូងផ្ទៃក្នុង ត្រូវកម្ទាត់ចោលឲ្យអស់”*។

# MRS. YIM SOVANN

*Mrs. Yim Sovann was born in 1960 at Saang district, Kandal province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 19 and 22 October 2012.*

On 17 April 1975, the Khmer Rouge soldiers entered Phnom Penh city, and the Lon Nol soldiers dropped their weapons to join with the Khmer Rouge soldiers. At that moment, I felt doubt and shock when I saw how the Khmer Rouge soldiers mistreated the people and Lon Nol soldiers. At Preh Puth Neang Kong Hing pagoda, while holding my sibling's hand as we tried find my uncle who was a Lon Nol soldier, I saw the Khmer Rouge soldiers with short hair, dressed in black uniforms, rolled up trousers with a scarf around their neck, walk to threaten the people – some were beaten by the Khmer Rouge with rifles, while some had their hands tied behind their back.

On that day, the Khmer Rouge told my family, *"leave for only three days, no need to take anything with you, because of the feared American aircraft bombing"*. At about 3 pm, I saw the Khmer Rouge soldiers with rifles threaten my father saying, *"move or not, if not be careful, American will bomb to death, and if still not move you will be killed"*. Hearing this, my father was forced to leave with few belongings (a few clothes and a little husked rice). The threats to my father reminded me the situation at O Russey market, where while I holding my sibling's hand back home, I saw the Khmer Rouge soldier knock on door of one house, but when no one came to open door the Khmer Rouge brought a gun to shoot the lock of the door and dragged the people from inside and shot them dead at the door way.

My family was transferred from Phnom Penh to live in Koh Thom district, Kandal province. Over there, the Khmer Rouge called the people evicted from Phnom Penh the *"17 April people"*. Those people were considered as enemies, capitalists, feudal class, and with insufficient food to eat. In comparison, the *"base people"* were considered as the revolutionary people, with enough food to eat, and had husked rice to stock individually. Not only that, but the Khmer Rouge also forced the 17 April people to work harder than the base people.

At the end of 1975, the Khmer Rouge transferred my family a second time to live in Kbal Chheu Pok cooperative, commune 9, Kandieng district, Pursat province. Over there, I was criticized all the time by the Khmer Rouge as they alleged that I was lazy, escaped from working, and had consciousness illness. In 1978, the Khmer Rouge arrested my father and 2 other people who were in the same mobile unit, with the allegation that those were hidden enemies burrowing from inside. I cried when I saw my father with his hands tied around his back. But the Khmer Rouge militiamen prohibited me from crying, they said those who cried were hidden enemy. My father begged them that *"I accept as enemy, but not kill my wife and children"*. Then, they escorted him and those 2 mobile unit people for execution at Department 07 (Banteay Yuon pagoda). On the way there, they announced loudly that *"this is hidden enemies burrowing from inside, has to smash all"*.

# លោកស្រី ឈិន ណារី



*លោកស្រី ឈិន ណារី កើតក្នុងឆ្នាំ១៩៤៦ និងមានស្រុកកំណើតនៅ ស្រុកស្អាង ខេត្តកណ្តាល។ ប្តីលោកស្រីឈ្មោះ ទៀ ហាវតិក មុខរបរជាអនុប្រធានអាកាសចរណ៍ស៊ីវិលពោធិចិនតុង។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។*

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំបានត្រូវខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ។ ទ័ពខ្មែរក្រហមស្លៀកខោខ្លីស្ពាយកាំភ្លើងបានប្រកាសតាមមីក្រូថា *"អង្គការសុំឲ្យបងប្អូន អញ្ជើញចេញពីទីក្រុងឲ្យអស់ អីវ៉ាន់កម្មសិទ្ធិសមរម្យ១បាវឆ្នូត បើមិនចេញទេ នឹងមានអាមេរិកាំងមកទម្លាក់គ្រាប់លើទីក្រុងភ្នំពេញ។ ស្រុកកំណើតនៅឯណា ទៅទីនោះទៅ។ តែ៣ថ្ងៃទេ ត្រឡប់មកវិញហើយ"*។ គ្រានោះ ខ្ញុំមិនជឿថាខ្មែរក្រហមឲ្យយើងវិលត្រឡប់មកក្រុងវិញទេ ពីព្រោះប្រជាជនទាំងអស់មានទឹកមុខក្រៀមក្រំដូចៗគ្នា។ ក្រោមការកំណត់ទិសធ្វើដំណើរដោយខ្មែរក្រហម គ្រួសារខ្ញុំបានទៅដល់ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល។ នៅទីនោះ គេឲ្យគ្រួសារខ្ញុំស្នាក់នៅផ្ទះអ្នកភូមិ។

ខ្មែរក្រហមបានហៅប្រជាជនប្រជុំនៅក្នុងចំការល្មុត។ ក្នុងអង្គប្រជុំខ្មែរក្រហមបាននិយាយអំពីជ័យជំនះបដិវត្តន៍ដែលឈ្នះចក្រពត្តិ និងផែនការមិនឲ្យមានព្រះសង្ឃនៅតាមវត្ត គឺត្រូវផ្សឹកទៅធ្វើស្រែទាំងអស់។ មួយខែក្រោយមក បងស្រីខ្ញុំ (ដែលរស់នៅស្រុកកំណើតក្នុងភូមិស្វាយជ្រួរ ឃុំកោះខែល ស្រុកស្អាង) បានមកទទួលគ្រួសារខ្ញុំទៅនៅផ្ទះជាមួយ។ នៅភូមិស្វាយជ្រួរ ឈ្លបខ្មែរក្រហម បានដើរធ្វើស្ថិតិតាមផ្ទះ គេបានសួរអំពីជីវភាពគ្រួសាររបស់ខ្ញុំ និងមុខរបរស្វាមីខ្ញុំកាលរស់នៅភ្នំពេញ។ ក្នុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសប្រជាជន១៧មេសានៅស្រុកស្អាងទៅខេត្តពោធិសាត់ និងបាត់ដំបង។ ពេលនោះ ខ្មែរក្រហមមិនបានឲ្យគ្រួសារខ្ញុំឡើងឡានទៅទេ តែបែរជាប្រាប់ខ្ញុំថា អង្គការស្នើសុំប្តីខ្ញុំទៅប្រជុំនៅមន្ទីរស្រុកស្អាង ព្រោះមានជាប់ពាក់ព័ន្ធ។

ក្រោយមកប្តីខ្ញុំបានត្រូវគេចាប់ដាក់មន្ទីរសន្តិសុខ១៥ ដែលជាកន្លែងសម្រាប់ដាក់អ្នកទោសធ្ងន់ៗ រីឯគ្រួសារខ្ញុំត្រូវបានគេបញ្ជូនទៅធ្វើការលត់ដំ ព្រោះគេថាជាគ្រួសារជាប់ពាក់ព័ន្ធ។ ខ្ញុំបានបាត់ដំណឹងប្តីតាំងពីពេលនោះមករហូតដល់ឆ្នាំ១៩៨០ ទើបខ្ញុំបានទទួលដំណឹងតាមរយៈអ្នកស្រាវជ្រាវនៅមន្ទីរស-២១ (គុកទួលស្លែង) ថាប្តីខ្ញុំត្រូវបានខ្មែរក្រហមចាប់ចូលមន្ទីរស-២១ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមបានសម្លាប់គាត់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦ ដោយចោទថាជា ស៊ីអាយអេ អាមេរិកាំង។

# MRS. CHHIN NAVY

*Mrs. Chhin Navy was born in 1946 at Saang district, Kandal province. Her husband Tie Hav Tek was a deputy chief of Pochentong Civil Aeronautics. She is a Civil Party in the first case and second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 18 April 1975, my family was forcibly transferred from Phnom Penh city. The Khmer Rouge soldiers wearing short pants with rifles on shoulder announced through a loudspeaker, *"Angkar wants you all to move from Phnom Penh city, with a sack of your belongings, if not move there will be bombings by American aircrafts on Phnom Penh city. Go to where your homeland is. Leave for only 3 days, then you will be back"*. At that time, I did not believe that the Khmer Rouge would allow us to come back because all the people had sad faces. Under the force of the Khmer Rouge to leave, my family arrived in Talun commune, Saang district, Kandal province. There my family was allowed to stay in a villager's house. The Khmer Rouge called the people to join the meeting at the sapodilla plantation. In the meeting, the Khmer Rouge said the revolutionary victory had defeated the imperialists and was setting a plan to disrobe Buddhist monks from pagodas to work in the rice field.

One month later, my sister (who was living at Svay Chuor village, Koh Khel commune, Saang district) came to receive my family to live with her. At Svay Chuor village, the Khmer Rouge walked to each house and they asked us about the standard of living and my husband's occupation when we used to live in Phnom Penh city. In 1976, the Khmer Rouge transferred the 17 April people in Saang district to live in Pursat province and Battambang province. Meanwhile, the Khmer Rouge did not let my family leave on the truck, but said, *"Angkar proposes your husband joins the meeting at Saang district, because he has involvement"*. Later, I knew that my husband was arrested and detained at Security Center-15, which was a place to put the serious prisoners. My family was sent to re-education, because the Khmer Rouge said we were an involvement family. I lost any information about my husband, until 1980 when I received information from a researcher at S-21 Center (Tuol Sleng prison) that my husband was sent to Tuol Sleng prison on 22 February 1976. The Khmer Rouge killed him on 25 May 1976 with the accusation of CIA American spy.

# លោក សាយ កាណាល់



*លោក សាយ កាណាល់ កើតក្នុងឆ្នាំ១៩៤៣ មានស្រុកកំណើតនៅទីរួមខេត្តកំពង់ចាម។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំ គ្រួសារបងស្រីខ្ញុំ និងប្អូនស្រីខ្ញុំ បានជួបជុំគ្នាដើម្បីចាកចេញពីទីក្រុងភ្នំពេញ។ យើងបានធ្វើដំណើរពីផ្សារអូរឬស្សី តែខ្មែរក្រហមបានកៀងយើងទៅតាមផ្លូវជាតិលេខ១វិញ។ ខ្មែរក្រហមបានប្រាប់ថា *"ឲ្យចេញតែ ៣ថ្ងៃទេ ព្រោះខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែកលើ ហើយមិនបាច់យកអីវ៉ាន់ទៅច្រើនទេ"*។ អស់រយៈពេល១ខែ ទើបគ្រួសារខ្ញុំបានធ្វើដំណើរទៅដល់ខេត្តកំពង់ចាម។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំបានឃើញខ្មែរក្រហមចាប់ប្រជាជនចងស្លាបសេក និងសាកសពទាហានស្លាប់នៅតាមដងផ្លូវដោយសារសង្គ្រាម។ ពេលទៅដល់ភូមិព្រែករំដេង (ជិតទីប្រជុំជនជីហែរ) ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម យើងបានស្នាក់នៅក្នុងផ្ទះឪពុកម្តាយបងថ្លៃរបស់ខ្ញុំ។

នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទៅរស់នៅស្រុកស្ទោងខេត្តកំពង់ធំ ដោយប្រាប់ថា *"ឲ្យទៅធ្វើស្រែនៅកន្លែងថ្មី"*។ នៅទីនោះ ខ្មែរក្រហមបានបំបែកសមាជិកគ្រួសារខ្ញុំឲ្យទៅស្នាក់នៅផ្ទះអ្នកមូលដ្ឋានផ្សេងៗគ្នា ដូចជា គ្រួសារបងស្រីរខ្ញុំបានត្រូវបញ្ជូនឲ្យស្នាក់នៅផ្ទះអ្នកមូលដ្ឋានឈ្មោះពេទ្យ ឪពុកម្តាយ និងប្អូនស្រីខ្ញុំត្រូវបានឲ្យស្នាក់នៅផ្ទះអ្នកមូលដ្ឋានឈ្មោះតាសួន ចំណែកខ្ញុំ និងប្រពន្ធត្រូវបានឲ្យស្នាក់នៅផ្ទះអ្នកមូលដ្ឋានឈ្មោះយ៉ាត។ នៅដើមឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានមកចាប់ *"អ្នក១៧មេសា"* មួយគ្រួសារម្តងៗ (ក្នុងអំឡុងពេល១ខែ ឬកន្លះខែម្តង) ដោយចោទថាធ្វើគិញ ធ្វើទាហាន ឬប្រាប់ថា ឲ្យទៅនៅភូមិថ្មី តែតាមពិតគ្រួសារទាំងនោះត្រូវបានគេបញ្ជូនទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានមកធ្វើប្រវត្តិរូបអ្នកនៅក្នុងភូមិជាញឹកញាប់។ ប្តីបងស្រីខ្ញុំបានប្រាប់ខ្មែរក្រហមតាមត្រង់ថា គាត់ជាគ្រូបង្រៀន ព្រោះគាត់គិតថាខ្មែរក្រហមសម្លាប់តែទាហានលន់ នល់ ប៉ុណ្ណោះ តែផ្ទុយទៅវិញខ្មែរក្រហមបានចោទថាបងថ្លៃខ្ញុំ (ប្តីបងស្រីខ្ញុំ) ជាគ្រូបង្រៀនចាំស៊ីតែប្រាក់ខែ។ ក្រោយមក ពេលកំពុងហូបបាយថ្ងៃត្រង់នៅឯរោងបាយ ស្រាប់តែមានខ្មែរក្រហម២-៣នាក់បានមកនាំគ្រួសារបងស្រីរបស់ខ្ញុំទៅ ដោយប្រាប់ថាអង្គការឲ្យទៅជាន់រហាត់ទឹកនៅភូមិផ្សេង។ ពេលបណ្តើរចេញទៅបានចំងាយប្រហែល ៤០០-៥០០ ម៉ែត្រពីផ្ទះបាយ ខ្មែរក្រហមបានចងបងស្រី និងបងថ្លៃរបស់ខ្ញុំ រួចនាំចេញទៅ ហើយពួកគេទាំងពីរនាក់បានបាត់ដំណឹងតាំងពីពេលនោះមករហូតដល់សព្វថ្ងៃ។

# MR. SAY KANAL

*Mr. Say Kanal was born in 1943 at Kampong Cham province. He is a Civil Party in the second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 17 April 1975, my parents, my older sister's family and my younger sister gathered to leave Phnom Penh city. We left from O Russey market, but the Khmer Rouge insisted that we go on the National Road No.1. The Khmer Rouge told us, *"Move for only three days because an American bomb on the city is feared, no need to bring belongings with"*. It took us one month to reach Kampong Cham province. While traveling, I saw the Khmer Rouge had caught people and tied their hands behind their backs. I also saw the dead bodies of soldiers who had died from war on the road. When we arrived in Prek Romdeng village (nearby Chi Her crowded place), Srey Santhor district, Kampong Cham province, we stayed in the house of my brother-in-law's parents.

At the end of 1975, the Khmer Rouge transferred my family to live in Staung district, Kampong Thom province. They told us to *"go and grow rice at the new place"*. Over there, the Khmer Rouge separated my family to stay in different houses of the base people. My older sister's family was required to stay with the base people Pet, my parents and younger sister were ordered to stay with the base people Ta Suon, while my wife and I were sent to stay with the base people Yat.

In early 1977, the Khmer Rouge arrested the *"17 April people"*, one family at a time over the period of a month. The 17 April people were accused of being spies or soldiers. They were lied to, the Khmer Rouge said they would go to live in the new village, but in fact, those families were sent to be murdered. At the end of 1977, the Khmer Rouge came frequently to the village to make records about people's biographies. My older sister's husband told the Khmer Rouge honestly that he was a teacher because he thought that the Khmer Rouge killed only Lon Nol soldiers, but the Khmer Rouge alleged that her husband was a teacher who worked for a salary. After that, the Khmer Rouge came to my older sister's family and told them that Angkar required them to go to paddle waterwheel at another village. After being escorted about 400 – 500 meters away from the dining hall, the Khmer Rouge tied up my older sister and her husband, and took them away. Both of them disappeared and I do not know where they are until today.

# លោកស្រី តាន់ ស៊ីតា



*លោកស្រី តាន់ ស៊ីតា កើតក្នុងឆ្នាំ១៩៥៨ មានស្រុកកំណើតនៅស្រុកតាខ្មៅ ខេត្តកណ្តាល។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង ០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំឲ្យគ្រួសារខ្ញុំចេញពីទីក្រុង ពួកវាថាចេញតែ៣ថ្ងៃ ដើម្បីបោសសំអាតទ័ពអាមេរិកាំង។ ពេលចាកចេញនោះ គ្រួសារខ្ញុំដែលមានសមាជិក៦នាក់ មានបំណងចង់ទៅស្រុកកំណើតនៅស្រុកតាខ្មៅ ខេត្តកណ្តាល ក៏ប៉ុន្តែពេលទៅដល់ចំណុចក្បាលថ្នល់ ខ្មែរក្រហមបានបង្ខំឲ្យយើងទៅតាមផ្លូវជាតិលេខ១វិញ។ ក្រោមការបង្គាប់បញ្ជារបស់ទ័ពខ្មែរក្រហម យើងបានទៅរហូតដល់វត្តផ្សុំ។ ពួកខ្មែរក្រហមបានឲ្យគ្រួសារខ្ញុំស្នាក់នៅទីនោះប្រហែល ៥ ទៅ ៦ខែ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនទៅកន្លែងផ្សេង ដោយកុហកថា *"ស្រុកកំណើតនៅឯណា ទៅកន្លែងនោះទៅ"*។ យើងបានប្រាប់ខ្មែរក្រហមថា ស្រុកកំណើតនៅខេត្តកណ្តាល។ បន្ទាប់ពីជិះឡានជាច្រើនដំណាក់មក ខ្ញុំមិនដឹងថាខ្មែរក្រហមនាំទៅណានោះទេ។

លុះក្រោយមកទើបដឹងថា គេនាំយើងទៅខេត្តបាត់ដំបងធ្វើស្រែ។ យើងត្រូវបានខ្មែរក្រហមដឹកតាមកប៉ាល់ រួចតាមឡាន និងរទេះភ្លើងទៅដល់សហករណ៍អូគ្រាត តំបន់៤ ភូមិទួលទ្រា ខេត្តបាត់ដំបង។ នៅទីនោះការរស់នៅមានការលំបាកខ្លាំង ពីព្រោះយើងត្រូវសង់ជម្រកដោយខ្លួនឯង និងត្រូវហូបរួម (អង្ករមួយកំប៉ុងសម្រាប់មនុស្ស ៨នាក់ ក្នុងមួយថ្ងៃ)។ ប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺដោយសារខ្វះអាហារ។ បន្ទាប់មកកូនប្រុសខ្ញុំម្នាក់អាយុ១ខួបកន្លះបានស្លាប់ដោយសារតែជំងឺ។ ខ្ញុំបានសុំអង្គការយកសពកូនទៅកប់ ប៉ុន្តែអង្គការប្រាប់ថា *"ទុកហ្នឹងហើយ ចាំអង្គការដោះស្រាយឲ្យ"*។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខ្ញុំទទួលដំណឹងថាឪពុកខ្ញុំស្លាប់ ខ្ញុំបានសុំខ្មែរក្រហមត្រឡប់មកមើលសពឪពុក គេមិនអនុញ្ញាតទេ ហើយប្រាប់ថា *"បើមិត្តនារីទៅវិញ ឪពុករស់ឡើងវិញ មិត្តទៅចុះ បើមិនរស់វិញទេ មិត្តទទួលខុសត្រូវខ្លួនឯង"*។

ប្រហែល ៨-៩ ថ្ងៃក្រោយមក ម្តាយខ្ញុំក៏បានស្លាប់ដោយសារតែជំងឺវិកលចរិត។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានយកខ្ញុំទៅសម្លាប់ ដោយកុហកថាអង្គការឲ្យទៅប្រជុំ។ ខ្មែរក្រហមបានវាយខ្ញុំត្រង់ក្បាលដើម្បីឲ្យស្លាប់ តែមិនស្លាប់។ ដើម្បីមានជីវិតរស់ ខ្ញុំត្រូវធ្វើឆ្កួតរហូតដល់ថ្ងៃរំដោះ។ ក្រោយពីរបបខ្មែរក្រហមបានផុតរលត់ទៅ ខ្ញុំពុំមាននៅសល់សាច់ញាតិអ្វីទៀតទេ ក្រៅតែពីខ្លួនឯងម្នាក់គត់។ របបនោះ បានធ្វើឲ្យខ្ញុំបាត់បង់នូវកូនប្រុសម្នាក់ ឪពុកម្តាយ និងប្អូនប្រុសពីរនាក់ និងបានបន្សល់ទុកនូវស្លាកស្នាមលើរាងកាយ និងភាពឈឺចាប់ផ្លូវចិត្តរហូតដល់សព្វថ្ងៃ។

# MRS. TANN SITA

*Mrs. Tann Sita was born in 1958 at Takhmao district, Kandal province. She is a Civil Party in the second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 17 April 1975, the Khmer Rouge forced my family to leave from the city; they said that we would move for only three days, in order to clean up the American troops. During departure, my family had six members wanting to go to the homeland in Takhmao district, Kandal province, but when we reached the Kbal Thnal site, the Khmer Rouge forced us to travel on national road No.1. Under the control and orders from the Khmer Rouge soldiers, we kept going until we arrived in Phsam pagoda. The Khmer Rouge let us to stay here for about five to six months.

In September 1975, the Khmer Rouge transferred the people to another place, telling them the lie, *"Go to the place where your homeland is"*. We told the Khmer Rouge that my homeland was in Kandal province. After going from place to place, I did not know where the Khmer Rouge was taking us. Later, we found out that they had brought us to grow rice at Battambang province. We boarded a ship, and were loaded on to a truck and a train to O Kreat cooperative, region 4, Tuol Trea village, Battambang province. The living conditions there were very difficult; because we had to build shelter by ourselves and had to eat collectively (one can of husked rice for eight people per day). Some people became ill due to the insufficient supply of food. After that, my son, one and a half years old, died because of illness. I asked Angkar to bury my son's dead body, but Angkar said, *"Leave it here, and let Angkar do it on your behalf"*.

In mid-1978, I received news that my father died. I proposed to the Khmer Rouge that I go back to see him, but they did not allow and said, *"If you go back, your father is rebirth, let you go. But if not rebirth, you had to take responsible by yourself"*.

About eight or nine days after the death of my father, my mother died because she had a mental condition. At the end of 1978, the Khmer Rouge took me to be killed by telling me a lie; they told me that Angkar wanted me to go to the meeting. The Khmer Rouge hit me on the head repeatedly, but I stayed alive. In order to keep my life and to survive, I pretended to be mad until liberation day. After the collapse of the Khmer Rouge regime, I did not have any relatives left and I was alone. The regime caused me to lose my son, parents and two younger brothers. I still have the scars on my body and mental suffering today.

ផ្នែក ៤
Chapter 4

# ការបង្ខំកុមារឲ្យធ្វើការ

## Child Forced Labour



Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោកស្រី សេង ស៊ីវត្ថា



*លោកស្រី សេង ស៊ីវត្ថា អាយុ ៤៧ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវ។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅតូចអាយុទើប៩ឆ្នាំ មានមនុស្សច្រើនកំពុងប្រជ្រៀតគ្នាចេញពីទីក្រុងភ្នំពេញ។ ដោយសារផ្លូវចង្អៀតណែន និងខ្លាចបែកគ្នា យាយខ្ញុំបានចងដៃខ្ញុំជាប់នឹងដៃបងស្រីខ្ញុំ រួចធ្វើដំណើរចេញទៅ។ នៅតាមផ្លូវ ខ្ញុំបានឃើញមនុស្សស្លាប់នៅតាមចិញ្ចើមថ្នល់ មានទាំងមនុស្សចាស់ជរា ជនពិការ អ្នកស្វិតដៃ ស្វិតជើង ជាដើម ត្រូវបានគេដាក់ចោលនៅតាមចិញ្ចើមថ្នល់ មានខ្លះជិតស្លាប់ ខ្លះក៏ស្លាប់បាត់ ខ្លះក៏អង្គុយអត់អាហារ។ ខ្មែរក្រហមបានបង្ខំឲ្យយើងដើររហូតដល់គោលដៅទើបឲ្យយើងឈប់សម្រាក ទោះបីយើងហេវហត់អស់កម្លាំង ស្រេកទឹក ឃ្លានបាយក៏ដោយ ក៏យើងមិនអាចឈប់ដើម្បីហូបបានដែរ។ យើងបានដើរឆ្លងស្ពានច្បារអំពៅទៅរហូតដល់កោះក្របី រួចឆ្ពោះទៅផ្លូវជាតិលេខ៣។ បន្ទាប់មក ខ្មែរក្រហមបានដឹកយើងតាមឡានទៅដល់ភូមិតាម៉េង ស្រុក១០៩ ខេត្តតាកែវ។ ពេលទៅដល់ភូមិ ក្រុមគ្រួសារខ្ញុំត្រូវបានគេបំបែកឲ្យនៅផ្សេងៗគ្នា។ ពួកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅនៅក្នុងកងជីគាំ។

នៅទីនោះ គេបានបង្ខំឲ្យខ្ញុំធ្វើការទាំងយំទាំងថ្ងៃ។ ពេលថ្ងៃឲ្យចូកស្មៅចេក ចូកស្មៅពោត ពេលប្រលប់ឲ្យទៅដកសំណាប។ ម៉ោងបួនភ្លឺឲ្យទៅជញ្ជូនកណ្តាប់ឲ្យចាស់ៗស្ទូង។ លុះក្រោយមក ខ្ញុំត្រូវបានគេបញ្ជូនមកតំបន់១០៥ (ភូមិសិរីដំណាក់ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់)។ នៅទីនេះ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកទឹកស្រោចដំណាំមួយថ្ងៃប្រាំរងវែងៗ។ ហូបបបរវាល់វែក ជួនលាយពោត ជួនលាយដំឡូង ជួនក៏លាយមើមល្ហុង ឬសល្ហុង ជាដើម។ ពេលដេក ខ្ញុំដេកកំសត់ម្នាក់ឯង អត់មានឪពុកម្តាយនៅក្បែរ ដេកលើតុបាយ ដេកលើដី លើស្លឹកត្នោត ជួនក៏ត្រូវអត់អាហារហូបមួយយប់ទាល់ភ្លឺ។ ពេលខ្ញុំអាយុបាន១១ឆ្នាំ ខ្មែរក្រហមបានបង្ខំខ្ញុំឲ្យធ្វើការជាមួយលាមកគឺប្រមូលលាមកមនុស្ស លាមកសត្វ លាយបញ្ចូលគ្នាហើយដាក់នៅក្នុងឃ្លាំងនៅកងអង្គត្រាវ។ ពេលខ្លះយើងទៅរកកើបអាចម៍គោតាមវាលស្រែដោយកំណត់ក្នុងមួយថ្ងៃឲ្យបាន៨០គីឡូ។ ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំចុះរណ្តៅកើបអាចម៍ជ្រូកបញ្ចូលឃ្លាំង។ រណ្តៅនោះមានជម្រៅលិចត្រឹមចង្កេះរបស់ខ្ញុំ។ ខ្លួនប្រាណខ្ញុំកើតរមាស់ដំបៅពេញខ្លួនទាំងអស់ ព្រោះគ្មានសាប៊ូដុះលាងខ្លួន និងខោអាវសម្រាប់ផ្លាស់ប្តូរ គឺមានតែមួយសម្រាប់ពាក់ជាប់នឹងខ្លួន។ ម៉ោងហូបអាហារ ខ្មែរក្រហមឲ្យខ្ញុំឈរហូបនៅក្នុងរណ្តៅអាចម៍ជ្រូកតែម្តង។ របបអាហារមានតែដំឡូងមួយដុំប៉ុនកដៃតែប៉ុណ្ណោះ។ ដោយសារភាពហេវហត់ បានធ្វើឲ្យខ្ញុំងងឹតមុខ ដួលកំពប់ជីដែលកំពុងរែកឡើងពីរណ្តៅនោះអស់រលីង ធ្វើឲ្យអ្នកក្រោយជួរជាមួយគ្នាដើរជាន់ខ្ញុំកំពប់ជីអស់ដែរ។ ឃើញដូច្នេះ ពួកខ្មែរក្រហមបានយកដងរែកវាយខ្ញុំ ដោយសារខ្ញុំព្យាយាមគេច ទើបគេយកខ្សែចងខ្ញុំជាប់នឹងដើមត្រាច ហើយវាយខ្ញុំបន្តទៀត ពេលនោះខ្ញុំស្រែកទ្រហោយំខ្លាំងៗ គេក៏ស្រាយចំណងខ្ញុំ រួចវាយខ្ញុំបន្ថែមទៀត ធ្វើឲ្យត្រូវភ្នែកខាងឆ្វេងខ្ញុំតែម្តង។ ចាប់តាំងពីនោះមក ភ្នែកខាងឆ្វេងខ្ញុំចេះតែបង្កការឈឺចុកចាប់ជាប្រចាំ។ ខ្មែរក្រហមបង្ខំឲ្យខ្ញុំជាកុមារធ្វើការដូចជាមនុស្សធំ ទាំងភ្នែកម្ខាងឈឺ ហើយក៏មិនបានផ្តល់ថ្នាំសម្រាប់ព្យាបាលភ្នែកខ្ញុំដែរ។ ក្រោយថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩ ភ្នែកឆ្វេងរបស់ខ្ញុំបានងងឹតមើលអ្វីលែងឃើញ។ មិនយូប៉ុន្មាន ភ្នែកស្តាំខ្ញុំក៏ចាប់ផ្តើមឈឺទៀត។ ក្នុងឆ្នាំ២០០៨ ភ្នែកខ្ញុំទាំងពីរងងឹតទាំងស្រុង។ របបខ្មែរក្រហមបានបន្សល់ទុកនូវអនុស្សាវរីយ៍យ៉ាងជូរចត់បំផុតសម្រាប់ជីវិតខ្ញុំ គឺភ្នែករបស់ខ្ញុំទាំងពីរត្រូវពិការ ធ្វើឲ្យការរស់នៅរបស់ខ្ញុំជួបទុក្ខលំបាករហូតដល់សព្វថ្ងៃ។

# MRS. SENG SIVUTHA

*Mrs. Seng Sivutha, 47-year-old, was born in Takeo province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 4 June 2013.*

On 17 April 1975, I was only nine years old. There were many people squeezing through the crowd to leave from Phnom Penh city. Due to the street being very crowded, and because we were afraid of being separated from each other, my grandmother tied my hand to my older sister's hand. On the way, I saw dead people along the road, including the elderly, people with disabilities, and so on, who had been left on the side of the road. Some were almost dead, some had already died, and some sat starving. The Khmer Rouge forced us to walk until we reached the destination where we were allowed to rest, though we were exhausted, thirsty, and hungry, we could not stop walking to eat. We walked across Chbar Ampov Bridge to reach Koh Krabei area, and then we moved forward to the National Road No. 3.

The Khmer Rouge loaded us on trucks to Ta Meng village, district 109, Takeo province. When we arrived in the village, my family was separated to live in different units. The Khmer Rouge sent me to live in the Chi Kaom unit. They forced me to work hard day and night. During the daytime, I was assigned to clear grass from the banana and corn fields, and at dusk I had to pull out the rice seedlings. Early in the morning at 4am, I was ordered to carry the rice sheaf for the adults to transplant in the rice field. Later, I was sent to region 105 (Serey Damnak village, Trapaing Thom Khang Cheung commune, Traim Kak district). Over there, the Khmer Rouge forced me to carry water to irrigate vegetables, five long mounds per day.

During this time, I would only eat a ladle of watery porridge, sometimes mixed with corn or potato, and sometimes mixed with the bulb of papaya or the root of papaya tree. When I slept, I slept alone, without my parents nearby. I would sleep on the dining table, on the ground, on palm leaves, and sometimes I would have nothing to eat till the morning. When I was eleven years old, the Khmer Rouge forced me to work with the waste of human excrement and animal dung. I had to mix it up and put it into the storehouse at Angk Trav unit. Sometimes, we went to collect the cow dung at the rice field with the limitation 80 kg per day. The Khmer Rouge forced me to go down the pit to collect the pig dung to put it into the warehouse. That pit was the depth of my waist. My body got itchy because there was no bath soap to wash my body and no clean clothes to change in to. I only had a set of clothes that were already on my body.

At the meal time, the Khmer Rouge would drop meals for me to eat inside the pit. The food portion would only be a small piece of potato. Because I was exhausted and starving, I once fainted and fell down and spilled the fertilizer that I was carrying from the pit. This caused the people behind me to fall down and spill fertilizer as well. Seeing this, the Khmer Rouge hit me with a stick. When I tried to escape they brought rope to tie me to a tree and continued to beat me. I cried loudly. They untied me and beat me more until they hit my left eye. Since then, I get frequent pain in my left eye.

The Khmer Rouge forced me work hard like the adults even when one of my eyes was in pain, and they did not give me any medicine for treatment. After the liberation in 1979, my left eye could not see anything. Not so long after, my right eye became painful as well. In 2008, I became blind. The Khmer Rouge regime is a very bitter remembrance in my life –my eyes were blinded and I continue to live facing many difficulties until today.

# លោក អូន ផល្លី



*លោក អូន ផល្លី អាយុ ៤៨ឆ្នាំ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឃើញទាហានខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ និងឃើញប្រជាជននៅតាមផ្ទះថ្ម គ្រវីទង់ជ័យសអបអរសាទចំពោះកងទ័ពខ្មែរក្រហម។ ពេលនោះ ខ្ញុំនៅផ្ទះជាន់ទី៣ ម្តុំផ្លូវមុនីវង្សក្បែរផ្សារថ្មី។ រំពេចនោះ ពួកខ្មែរក្រហមបានបាញ់ឡើងលើ បង្ខំឲ្យអ្នកដែលនៅជាន់លើៗចុះមកក្រោម។ អ្នកមិនព្រមចុះ ខ្មែរក្រហមបានឡើងទៅភ្ជង់ដល់លើផ្ទះបង្ខំឲ្យចុះ។ ខណៈនោះ គ្រួសារខ្ញុំក៏ត្រូវខ្មែរក្រហមឡើងទៅភ្ជង់ដល់លើផ្ទះ បង្ខំឲ្យចុះមកក្រោម ហើយបង្ខំឲ្យដើរទៅតាមផ្លូវព្រះមុនីវង្សឆ្ពោះទៅផ្លូវជាតិលេខ១។ ការធ្វើដំណើរពេលនោះ គឺមានការលំបាកណាស់ ព្រោះថាខ្ញុំនៅតូចអាយុប្រហែល១០ឆ្នាំ ឪពុកខ្ញុំរែករបស់របរ បងស្រីខ្ញុំពីរនាក់ទូលបង្វិចបន្តិចបន្តួច រូបខ្ញុំក៏កាន់បង្វិចតូចមួយដែរ ចំណែកប្អូនស្រីខ្ញុំពីរនាក់ទៀតក៏នៅតូចនិងត្រូវការឲ្យឪពុកម្តាយពរវា។

អស់រយៈពេល១៥ថ្ងៃ ទើបយើងដើរទៅដល់ភូមិព្រែកញ្ញៅ ខេត្តព្រៃវែង។ នៅទីនោះបានប្រហែល១០ថ្ងៃ មានកម្មាភិបាលខ្មែរក្រហមម្នាក់បានមកហៅឪពុកខ្ញុំថាឲ្យទៅនោះមួយភ្លែត រួចក៏បាត់ដំណឹងគាត់រហូត។ ប្រហែលបួនប្រាំថ្ងៃក្រោយមក យើងបានដំណឹងថាខ្មែរក្រហមយកគាត់ទៅរៀនសូត្រ។ បន្ទាប់ពីនោះមក ម្តាយខ្ញុំបានយកខ្ញុំទៅនៅជាមួយជីដូនខ្ញុំដែលស្ថិតនៅភូមិផ្សេង។ ក្រោយមក ខ្ញុំបានដំណឹងថាគេបានយកម្តាយ និងបងប្អូនស្រីខ្ញុំទាំង៤នាក់ទៅសម្លាប់ចោលហើយ។ ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ពេលឮដំណឹងនេះភ្លាម។ ខ្ញុំចង់រត់ទៅមើលពួកគាត់ តែជីដូនខ្ញុំបានឃាត់ ខ្ញុំបានត្រឹមតែសំឡឹងមើលពីចម្ងាយដោយសម្រក់ទឹកភ្នែកយ៉ាងក្តុកក្តួល។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសប្រជាជាន១៧មេសាចេញពីភូមិ។ ប្រជាជនច្រើនកុះកររួមទាំងខ្ញុំ និងជីដូនព្រមទាំងចៅស្រីគាត់ម្នាក់ទៀតត្រូវបានគេឲ្យឡើងកប៉ាលចេញមកភ្នំពេញ រួចបន្តដំណើរតាមរថភ្លើងទាំងយប់ទៅស្រុកមោងឫស្សីខេត្តបាត់ដំបង គឺជាកន្លែងលត់ដំ និងអត់ឃ្លានជាទីបំផុត។ នៅទីនោះ ជីដូនខ្ញុំនិងចៅស្រីគាត់ម្នាក់នោះ បានស្លាប់ដោយសារអត់អាហារ។ ចាប់ពីពេលនោះមក ខ្ញុំបានក្លាយទៅជាក្មេងកំព្រា គ្មានសល់សាច់ញាតិអ្វីទាំងអស់ ឪពុកម្តាយនិងបងប្អូនក៏ស្លាប់បាត់អស់ រស់នៅឯកោម្នាក់ឯង គ្មានទីពឹង ហើយត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការក្នុងកងកុមារនៅភ្នំត្រជាក់ចិត្ត។ ក្រោយរបបខ្មែរក្រហម ខ្ញុំរស់នៅតែម្នាក់ឯង ខ្ញុំគិតថាខ្លួនឯងជាមនុស្សខុសគេ រស់នៅដោយគ្មានសាច់ញាតិ។ ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ជាមួយនឹងរបបដ៏ឃោរឃៅនេះ គ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ ការឈឺចាប់នេះ បានរំខានអារម្មណ៍ខ្ញុំធ្វើឲ្យខ្ញុំមិនអាចរៀនសូត្របាន ខ្ញុំក៏ស្ម័គ្រចិត្តចូលបម្រើកងទ័ពទាំងនៅក្មេង។ ពេលធ្វើទាហាន ខ្ញុំបានរងរបួស ធ្លាក់ខ្លួនពិការ និងមានជំងឺគ្រុនចាញ់ធ្ងន់ធ្ងរនៅតែស្បែកនិងឆ្អឹង។

# MR. AUN PHALLY

*Mr. Aun Phally, 48 years old, was born in Phnom Penh city. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 27 May 2013.*

On 17 April 1975, I saw the Khmer Rouge soldiers enter Phnom Penh city and I saw the people waving white flags to congratulate the Khmer Rouge soldiers. At that time, I was at home on the third floor located on Monivong Street, nearby Phsar Thmey market. Suddenly, the Khmer Rouge soldiers fired shots into the air, in order to force the people who were living upstairs to go down. To any person who did not move, the Khmer Rouge would point their guns at their home to force them down. At that moment, the Khmer Rouge pointed their guns at my family to force us to go down. We were forced to walk on Monivong Street to the National Road 1. The journey at that time was quite difficult, as I was still young around 10 years old, my father carried little belongings, two older sisters carried small packages on their heads, and I also carried a small package. My two younger sisters were too small and needed my parents to carry them. After fifteen days, we walked to reach Prek Pnov village, Prey Veng province. After living there for about ten days, one Khmer Rouge cadre called my father to go for a while and then we lost his information. About four or five days later, we heard that the Khmer Rouge had taken him for re-education.

After that, my mother brought me to live with my grandmother who was living in another village. I later heard that my mother and four sisters were taken for execution. I felt a lot of pain when I heard this news. I wanted go to see them, but my grandmother banned me from going. I could do nothing but glance from a distance while my tears dropped painfully and mournfully.

Eventually the Khmer Rouge transferred the 17 April people from this village. Thousands people, including my grandmother, her granddaughter and I, were boarded on a ship to Phnom Penh city, and were then loaded on train during night to Maung Russey district, Battambang province, which was a place for re-education and starvation. There, my grandmother and her granddaughter died from starvation. I then became an orphan, with no relatives remaining. My parents and siblings have already died, and I was alive and lonely. Not only that, but I was forced by the Khmer Rouge to work in the children's unit at Tracheak Chit Mountain.

After the Khmer Rouge regime, I lived alone, and I felt that I was not like the others because I was living without any relatives. I felt a lot of suffering from this brutal regime that I could not find anything to compare it to. This pain disturbed my feelings, I was unable to study and that is why I became a soldier in my young age. While serving as soldier, I was injured, became disabled, and got serious malaria, which caused my body to become very skinny.

# លោកស្រី ចាន់ សុជាតិ



*លោកស្រី ចាន់ សុជាតិ មានអាយុ ៥៦ឆ្នាំ មានស្រុកកំណើតនៅ សង្កាត់លេខ៥ ក្រុងភ្នំពេញ។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២ ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅវេលាម៉ោងប្រហែលប្រាំបួនព្រឹក គ្រួសារខ្ញុំកំពុងរៀបចំដាំបាយ ស្រាប់តែមានយោធាខ្មែរក្រហមស្ពាយកាំភ្លើងមកដេញថា *"ប្រញាប់ឡើង ចេញឲ្យរហ័សព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក"*។ ពួសម្ដីនេះ គ្រួសារខ្ញុំ (ឪពុកម្តាយ និងបងប្អូនបង្កើត ១៣នាក់) ភិតភ័យខ្លាំងណាស់ ក៏យកអីវ៉ាន់ចាកចេញ មានតែកង់មួយ ម៉ូតូមួយដឹកអីវ៉ាន់បានបន្តិចបន្តួច បាយដែលដាំឆ្អិនរួចមួយឆ្នាំង, បំពង់ទឹកក្តៅ និងទឹកដោះគោសម្រាប់ប្អូនតូចៗ ព្រោះគ្រួសារខ្ញុំមានក្មេងតូចៗនៅបៅរហូតដល់ទៅបួននាក់។ តាមផ្លូវមុនីវង្ស ខ្ញុំតក់ស្លុតណាស់ជាមួយនឹងហ្វូងមនុស្ស ខ្លះរុញរទេះមានអ្នកឈឺព្យួរសេរ៉ូម ខ្លះដេកស្លាប់តាមផ្លូវ ខ្លះស្រែកយំហៅរកកូនចៅបែកគ្នា។ គ្រួសារខ្ញុំបានធ្វើដំណើរឆ្លងស្ពានមុនីវង្សមកស្នាក់នៅវត្តនិរោធអស់រយៈពេលបីថ្ងៃ។ បន្ទាប់មក ខ្មែរក្រហមបានបន្តដេញយើងឲ្យធ្វើដំណើរទៅមុខទៀត។ យើងក៏បានបន្តដំណើរមកស្នាក់នៅស្រុកកៀនស្វាយរយៈពេលប្រាំមួយខែ។ នៅទីនេះ យើងទទួលនូវទុក្ខវេទនាខ្លាំង។ ដោយសារការមិនមានអាហារហូបចុកគ្រប់គ្រាន់ ធ្វើឲ្យក្រុមគ្រួសារខ្ញុំដែលមានក្មេងតូចៗស្គមរីងរៃ រីឯប្អូនស្រីខ្ញុំដែលនៅបៅទឹកដោះគោបានប្តូរមកបៅទឹកបបរលាយស្ករជំនួសវិញ បណ្តាលឲ្យវាកើតជំងឺរាករូសរហូតដល់ស្លាប់។ យើងមានលុយកាក់បន្តិចបន្តួចខ្លះដែរ តែគេឈប់ចាយហើយ។

៦ខែក្រោយមក ខ្មែរក្រហមបានប្រកាសឲ្យអ្នកដែលចេញពីភ្នំពេញចូលទៅនៅភ្នំពេញវិញ។ ឪពុកខ្ញុំគឺជាវិស្វករ គាត់ត្រេកអរណាស់ ព្រោះគាត់គិតថាខ្មែរក្រហមត្រូវការអ្នកចេះដឹងដើម្បីយកទៅរៀបចំប្រទេស ហើយអាចធ្វើឲ្យស្ថានភាពគ្រួសារមានសភាពដូចសារដើមវិញ។ ថ្ងៃឡើងកប៉ាល់ ម៉ោងប្រាំល្ងាច មានមនុស្សរាប់រយគ្រួសារបានឡើងជិះកប៉ាល់ណែនណាន់តាន់តាប់។ ពេលកប៉ាល់មកដល់មុខវាំង មនុស្សត្រេកអរពេញកប៉ាល់ជាមួយនឹងការមកដល់ភ្នំពេញ ភ្លាមនោះមានបុរសម្នាក់អាយុប្រហែល៣០ឆ្នាំ បានស្រែកថា *"ជយោ! យើងមកដល់ភ្នំពេញហើយ"*។ បន្តិចក្រោយមក ខ្មែរក្រហមបានហៅបុរសម្នាក់នោះចេញមកក្រៅ ហើយបាញ់ផាំងៗពីរគ្រាប់ធ្លាក់ទៅក្នុងទន្លេ ឃើញសភាពការណ៍បែបនេះមនុស្សនៅក្នុងកប៉ាល់ស្ងាត់ឈឹងសូម្បីតែកូនក្មេងក៏អត់ហ៊ានយំដែរ។ កប៉ាល់បាននាំយើងទៅដល់ខេត្តកំពង់ឆ្នាំង រួចបន្តដំណើរតាមឡាន និងរថភ្លើងរហូតដល់ភូមិអូរក្រៀត ស្រុកមោងឫស្សី បន្ទាប់មកខ្មែរក្រហមឲ្យយើងធ្វើដំណើរដោយថ្មើរជើងទៅរស់នៅភូមិព្រៃទទឹង ឆ្កែខាំប្រើស ដែលជាតំបន់ព្រៃមិនមានផ្ទះសម្បែងអ្វីទាំងអស់។ ការរស់នៅទីនោះ គឺយើងត្រូវកាប់ឆ្ការព្រៃ និងសង់រោងស្នាក់នៅដោយខ្លួនឯង មួយរយៈក្រោយមកសមាជិកគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅកងចល័ត។ ខ្ញុំ និងបងស្រីត្រូវបានបញ្ជូនឲ្យទៅនៅកងយុវនារីអន្លង់គោក។ នៅទីនោះ ពួកខ្មែរក្រហមបានបង្ខំឲ្យយើងលើកប្រឡាយក្នុងទឹក បើមិនគ្រប់ផែនការទេ គេថាយើងជាខ្មាំង ជាសក្តិភូមិ គេប្រមាថវៃក្បាលចោលនឹងត្បូងចប។ សមាជិកគ្រួសារខ្ញុំបានស្លាប់ជាបន្តបន្ទាប់ដោយសារការហូបមិនគ្រប់គ្រាន់ និងការបង្ខំឲ្យធ្វើការធ្ងន់ ធ្វើឲ្យខ្ញុំរស់នៅតែម្នាក់ឯក្នុងភាពឯកកោ។ ក្នុងរបបខ្មែរក្រហម អ្វីដែលខ្ញុំមិនអាចបំភ្លេចបាន គឺភាពអត់ឃ្លាន និងការបង្អត់អាហារ ដែលធ្វើឲ្យសមាជិកគ្រួសារខ្ញុំ និងប្រជាជនជាច្រើនបានស្លាប់។ នេះហើយ គឺជាសោកនាដកម្មមួយដែលខ្ញុំមិនអាចបំភ្លេចបានអត់មួយជីវិត។

# MRS. CHAN SOCHEAT

*Mrs. Chan Socheat, 56 years old, was born in Sangkat 5, Phnom Penh city. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 29 May 2013.*

On the morning of 17 April 1975, my family was preparing to cook when suddenly a Khmer Rouge militiaman with rifle came and said, *"Hurry up, move urgently because American will come to bomb over here"*. When hearing this, my family (parents and thirteen siblings) was scared and rushed to move with small belongings such as one bicycle, one motorbike with a few things on it such as cooked rice, a hot water container, milk for the little children because my family had four little children that were still breastfeeding. On Monivong Bridge, I was shocked to see herds of people on the street, some pulling carts with injured people inside. Some people died on the road and some people cried out loudly to find their offspring who have become separated.

My family walked across Monivong Bridge to stay at Niroth pagoda for three days and then the Khmer Rouge kept moving us forward. My family went to stay in Kien Svay district for six months. While living there, we were miserable. There was insufficient food to eat which caused us, especially the little children, to become skinny. We had to change the food for my little sister, who was still breastfeeding, to watery porridge with sugar instead, she contracted dysentery that caused her death. We had some money with us, but we were not able to use it during the Khmer Rouge Regime.

Six months later, Angkar announced the city dwellers were to return to live in the Phnom Penh city. My father, who was an engineer, felt very happy because he thought that the Khmer Rouge needed the educated people to build up the country, and it could allow our family situation to become normal. On the day we were to take the ship, there were thousands people boarding the ship. When ship reached the front of the Royal Palace, the people on the ship were very enthusiastic at their arrival in Phnom Penh. Suddenly, a man, around 30 years old, shouted *"we arrive in Phnom Penh!"* A bit later, the Khmer Rouge called that man to walk out and then he was shot two times and he fell down into the river. After seeing this, the people on the ship kept quiet, even the little children dared not to cry.

The ship brought us to Kampong Chhnang province and then we were taken to O Kriet village, Maung Russey district by a truck and a train. The Khmer Rouge then made us walk to live in Prey Tortoeng Chhke Khaim Breus village, which was a forest area. While living there, we had to clear the forest to make shelter by ourselves. A short time later, my family members were separated by the Khmer Rouge to work in the mobile unit. My sister and I were sent to live in the young girls mobile unit at Anlong Kork area. Over there, the Khmer Rouge forced us to build a canal. If the canal was not completed to their plan, they would allege that we were enemy, Feudalist, and threatened to kill us by hitting us with hoe blade. My family died from working hard and by starvation, leaving me alone.

During the Khmer Rouge regime, what I never forgot was the starvation and the food deprivation that caused my family members and other people's death. This is a tragedy that I could not forget in my whole life.

# លោក យិន វំដួល



*លោក យិន វំដួល អាយុ ៤៨ឆ្នាំ មានស្រុកកំណើតនៅរាជធានីភ្នំពេញ។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។*

ពេលទ័ពខ្មែរក្រហមចូលដល់ក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅជាកុមារក្នុងវ័យ១០ឆ្នាំ ខ្ញុំមិនដឹងអ្វីទាំងអស់ ដឹងតែពីសប្បាយពេលឃើញកងទ័ពខ្មែរក្រហមច្រើន។ ខ្ញុំបានចូលរួមអបអរសាទរចំពោះកងទ័ពខ្មែរក្រហម ហើយបានឃើញប្រជាជនលើកទង់ស និងនិយាយគ្នាថា *"យើងមានសន្តិភាពហើយ"*។ ក្រោយពេលត្រឡប់មកផ្ទះវិញ បានឮដំណឹងអកុសលមួយពីម្តាយខ្ញុំប្រាប់ថា ឪពុកខ្ញុំត្រូវបានខ្មែរក្រហមចាប់បាត់ទៅហើយ។ ដំណឹងនេះធ្វើឲ្យម្តាយខ្ញុំសន្លប់បាត់បង់ស្មារតី និងមានការឈឺចាប់សោកសង្រេងនៅក្នុងគ្រួសារទាំងមូល ដោយសារតែការបាត់បង់អ្នកមានគុណ និងជាអ្នកទ្រទ្រង់គ្រួសារ។

ប្រហែលម៉ោង ១១.៣០នាទីថ្ងៃត្រង់ ខ្ញុំបានឮស្នូរកាំភ្លើងបាញ់នៅតាមដងផ្លូវក្បែរសាលារៀនទួលស្វាយព្រៃ ហើយខ្ញុំក៏បានឃើញកងទ័ពអាវខ្មៅ ម្ជូរជើងខោ មានខ្លះទៀតចងកន្សែងក្រហម និងស្ពាយអាកាបាញ់ឡើងលើគំរាមដេញប្រជាជនចេញពីក្រុងភ្នំពេញ ដោយប្រាប់ថាខ្លាចមានកងទ័ពអាមេរិកាំងមកទម្លាក់គ្រាប់បែកក្នុងក្រុងភ្នំពេញ ហើយចេញយ៉ាងយូរបំផុត២ទៅ៣ថ្ងៃប៉ុណ្ណោះ ដើម្បីឲ្យអង្គការយើងរៀបចំបោសសំអាតពួកចក្រពត្តិអាមេរិកាំង លន់ នល់ សិរិមតៈ។ បន្តិចក្រោយមក មានខ្មែរក្រហមប្រហែល៥ទៅ១០នាក់បានបាញ់ផ្ទប់ចូលមុខផ្ទះខ្ញុំ។ ភ្លាមៗនោះ គ្រួសារខ្ញុំមិនបានចេញទេ យើងទាំងអស់គ្នានៅសម្ងំក្នុងផ្ទះរងចាំមើលស្ថានការ។ យប់ឡើង ដោយសារគ្មានភ្លើងអគ្គិសនី ម្តាយខ្ញុំបានអុជចង្កៀងបំភ្លឺឡើង ពេលឃើញភ្លើងចង្កៀង ខ្មែរក្រហមស្រែកសួរថា *"ហេតុអ្វីបានជាអ្នកឯងមិនចេញ?"* ហើយក៏បានបាញ់កាំភ្លើងបុកចូលផ្ទះ បង្ខំឲ្យយើងចាកចេញ។ នៅយប់នោះប្រហែលម៉ោង៩ គ្រួសារខ្ញុំបានបង្ខំចិត្តចេញពីផ្ទះទៅតាមផ្លូវម៉ៅសេទុង។ ទិដ្ឋភាពតាមផ្លូវព្រឹកឡើង ប្រហែលម៉ោង៦ ខ្ញុំបានឃើញខ្មែរក្រហមចាប់ទាហានលន់ នល់ និងយុវជនមួយចំនួនដែលត្រូវបានសង្ស័យថាជាទាហានលន់ នល់ ចងស្លាបសេក រួចបណ្តើរចេញទៅ។ ខ្ញុំមិនដឹងថាអ្នកទាំងនោះមានជោគវាសនាយ៉ាងដូចម្តេចទេ ពេលដែលគេយកទៅនោះ។ ពេលថ្ងៃកាន់តែមានពន្លឺច្បាស់ ខ្ញុំបានឃើញសោដនាកម្មជាច្រើន ប្រជាជនចេញពីក្រុងភ្នំពេញទាំងទឹកមុខសោកសៅក្រៀមក្រំជាមួយ នឹងសម្រែកក្មេងតូចៗយំ និងអ្នករបួសដោយសារគ្រាប់ត្រូវបានដាក់លើរថយន្ត រ៉ឺម៉កសីក្លូ ដឹកចេញក្នុងសភាពគ្មានចំណីអាហារ និងថ្នាំព្យាបាល។ ខ្ញុំក៏បានឃើញសាកសពក្នុងសភាពហើមរលួយនៅតាមដងផ្លូវ។ គ្រានោះ គ្មាននរណាម្នាក់អាចរួចផុតពីការគំរាមកំហែង និងបាញ់សម្លាប់របស់ខ្មែរក្រហមឡើយ ប្រសិនបើអ្នកទាំងនោះមិនព្រមអនុវត្តតាមបទបញ្ជារបស់គេ ទោះជាក្មេងដែលពុំទាន់ដឹងអី ក៏ខ្មែរក្រហមហានលើកដៃសម្លាប់ដើម្បីសម្រេចផែនការរបស់អង្គការថ្នាក់លើនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អស់រយៈពេលបីថ្ងៃ ទើបគ្រួសារខ្ញុំបានទៅដល់ផ្ទះជីតាខ្ញុំនៅព្រែកឯង។

ពីរបីថ្ងៃក្រោយមក យើងក៏បង្ខំចិត្តចេញដំណើរទៅស្រុកកំណើតម្តាយរបស់ខ្ញុំនៅឃុំកោះឧកញ៉ាតី ព្រោះថានៅទីនេះគ្មានស្បៀងអាហារ និងមានមនុស្សស្លាប់ច្រើននៅតាមដងទន្លេនិងតាមផ្លូវ។ មកដល់កោះឧកញ៉ាតី ខ្មែរក្រហមបានបញ្ជូនយើងទៅនៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយសារគេបានដឹងពីសាវតាឪពុកខ្ញុំជាសាស្ត្រចារ្យច្បាប់នៅសាលាច្បាប់ និងជានាយទាហានជាន់ខ្ពស់ក្នុងសម័យសាធារណរដ្ឋខ្មែរ។ មួយរយៈក្រោយមកទៀត ខ្មែរក្រហមបានបន្តជម្លៀសគ្រួសារខ្ញុំឲ្យទៅនៅឃុំមេទឹក ស្រុកបាកាន ខេត្តពោធិសាត់ ដោយចោទថាគ្រួសារខ្ញុំជាអ្នក១៧មេសា ដែលជាពួកវណ្ណៈសក្តិភូមិ ឬមូលធននិយម ចក្រពត្តិនិយមដែលប្រឆាំងនឹងអង្គការ។ នៅទីនោះ ខ្ញុំត្រូវបានគេបំបែកពីម្តាយឲ្យទៅនៅជំរំកុមារ និងបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ដោយមួយក្រុមត្រូវកាប់ប្រឡាយឲ្យបាន ទទឹង៥ម៉ែត្រ បាតក្រោម២ម៉ែត្រ និងផ្ទៃលើជំរៅ៤ម៉ែត្រ ក្នុងមួយថ្ងៃ។ ខ្មែរក្រហមបានទាត់ធាក់ រួចវ៉ៃខ្ញុំជាមួយដំបង និងខ្សែតី បង្កឲ្យមានស្លាកស្នាមបន្សល់ ទុកដល់សព្វថ្ងៃ ក៏ព្រោះតែខ្ញុំបានលួចដំឡូង អំពៅ មកបំបាត់ការស្រេកឃ្លានរបស់

(តទៅទំព័រទី៦៨)

# MR. YIN ROMDUOL

*Mr. Yin Romduol, 47 years old, was born in Phnom Penh city. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 30 May 2013.*

When the Khmer Rouge entered Phnom Penh city on 17 April 1975, I was young at the age of 10. I knew nothing, besides enjoying the march of the Khmer Rouge soldiers arriving. I went to congratulate the Khmer Rouge soldiers and saw the people raising the white flag saying, *"our country is in peace"*. After going back home, we heard from my mother that the Khmer Rouge had arrested my father. The bad news made my mother lose consciousness, and the whole family suffered mournfully because we had lost a loved person and family supporter. That day, my father disappeared forever.

At about 11:30 am on April 17, I heard the sound of gunfire on the road nearby Tuol Svay Prey School. Then, I saw the soldiers dressed in black uniforms, rolling up their trousers, while some of them wore red scarves, and held AK rifles that fired into the air to threaten the people to move out of Phnom Penh city. They also announced that American air forces would bomb Phnom Penh city, and that we have to leave for only two or three days to allow Angkar to clean out the American imperialists and Lon Nol officials. A bit later, I saw five to ten Khmer Rouge soldiers shooting at the front of my house. My family had not yet moved; we remained calm inside the house to keep watching the situation. That night, because there was no electricity, my mother lit a lamp. When they saw the brightness from the lamp, the Khmer Rouge shouted, *"Why do you not move out?"* then the Khmer Rouge shot at the wall of the house to threaten us to leave.

That night at 9pm, my family and I left forcibly from home through Mao Tse-Tung Boulevard. On the road early next morning, around 6 am, I saw the Khmer Rouge arresting Lon Nol soldiers and youths who they suspected to be Lon Nol soldiers. They tied their hands behind their backs and escorted them away, and I did not know what their fate was going to be. When the daylight got brighter, I saw many tragedies happening. The faces of the people moving out of Phnom Penh city were sad and regretful, small children were crying, and people who had been injured by explosions were loaded on cars and cyclos without having food supplies or medicine. I also saw swollen, decomposing dead bodies lying at the side of the road. At that time, nobody could escape from the threats and killings of the Khmer Rouge. If people refused to follow their orders, Khmer Rouge soldiers would kill them in the name of the higher plan of the Democratic Kampuchea Regime (Angkar), even if they were small children who knew nothing.

After traveling for three days, my family arrived at my grandfather's house at Prek Eng area. A few days later, we were forced to leave again for the homeland of my mother at Koh Oknhatei commune, because there were no food supplies at Prek Eng and there were dead bodies lying beside the river's bank and on the road. Upon arrival in Koh Oknhatei commune, the Khmer Rouge sent us to live in Vihear Suor commune, Khsach Kandal district, Kandal province, as they knew my father's biography, who had been a law professor at the Faculty of Law and a senior soldier during the Khmer Republic Regime.

A short time later, the Khmer Rouge alleged that my family was 17 April people, which means we were considered capitalist, feudalist and imperialist people acting against Angkar. They transferred my family to live in Metoek commune, Bakarn district, Pursat province. Over there, I was separated from my mother to live in the children's camp, where they forced me to

(Continue to page 69)

ខ្លួន។ គ្រាមួយនោះ ខ្ញុំបានលួច សំណាបយកមកហូប មេភូមិមកទាន់ ហើយបានចាប់ខ្ញុំវ៉ៃទាត់ធាក់ រួចប្រគល់ទៅឲ្យកងឈ្លប។ ដោយសារតែ ម្ដាយខ្ញុំការពារខ្ញុំ កងឈ្លបបានចាប់ខ្ញុំ និងម្ដាយទៅដាក់គុកនៅឃុំមេទឹក។ នៅក្នុងគុក ខ្មែរក្រហមបានធ្វើទារុណកម្មវ៉ៃសួរចម្លើយខ្ញុំរហូតដល់សន្លប់១ទៅ២ដងក្នុងមួយថ្ងៃ (តើខ្ញុំមានកំហុសអ្វីទៅ បានជាពួកគេធ្វើទារុណកម្មចំពោះកុមារដូចជារូបខ្ញុំយ៉ាងដូច្នេះ?)។ បន្ទាប់មក គេបានបង្ខំឲ្យខ្ញុំជាកុមារទៅធ្វើការងារធ្ងន់ៗដូចជា កាប់ដី ជីកប្រឡាយ ដកស្ទូង។ ថ្ងៃមួយ ពួកខ្មែរក្រហមបានកោះប្រជុំថា *"ប្រសិនជាគ្រួសារណាមួយលួចរត់ចេញពីគុក គេនឹងកំទេចគ្រួសារនោះចោល"*។ រស់នៅគុកបានប្រហែល១ខែ ខ្ញុំបានពិភាក្សាជាម្ដាយខ្ញុំដើម្បីរត់ចេញពីទីនេះ ខ្ញុំបានសួរម្ដាយខ្ញុំថា *"ម៉ាក់ អនុញ្ញាតឲ្យកូនទៅទេ?"* គាត់បាននិយាយ *"ត្រូវតែទៅកូន បើសិនជាកូនទៅ កូនអាចមានសំណាងនឹងរស់ បើកូននៅ កូនពិតជាស្លាប់"*។ នៅម៉ោង៧ទៅ៨យប់ មានភ្លៀងធ្លាក់យ៉ាងខ្លាំងលាយឡំនឹងសំឡេងផ្គររន្ទះ ហើយមេឃក៏ងងឹតខ្លាំង ខណៈនោះកងឈ្លបដែលយាមគុកបានរត់រកកន្លែងដើម្បីជ្រកភ្លៀង។ ខ្ញុំក៏សម្រេចចិត្តរត់តាមវិធីណាកុំឲ្យកងឈ្លបទាំងនោះមើលឃើញ។ ខ្ញុំបានលូនកាត់បន្លាលួសដែលហ៊ុំព័ទ្ធតំបន់នេះ ធ្វើឲ្យមុតត្រូវខ្នងបន្សល់ទុកស្លាកស្នាមរហូតដល់សព្វថ្ងៃ។ បន្ទាប់ពីបានឆ្លងផុតបន្លាលួសហើយនោះ ខ្ញុំបានរត់ដោយមិនងាកក្រោយទេ គឺខំសម្រុកយ៉ាងម៉េចឲ្យទៅដល់ភូមិអូរព្រាលដែលជាកន្លែងជីដូន និងម្ដាយមីងខ្ញុំរស់នៅ។ ពេលបានជួបអ្នកទាំងពីរនៅភូមិ ខ្ញុំបានប្រាប់ម្ដាយមីងខ្ញុំពីរឿងដែលខ្ញុំបានជួបប្រទះនៅក្នុងគុក ហើយខ្ញុំក៏បានប្រាប់គាត់ទៀតថា *"មីង ម៉ាក់ឲ្យទៅយកអីវ៉ាន់បន្តិចបន្តួចដែលនៅជាប់នឹងចង្កេះរបស់គាត់"*។ ព្រឹកឡើងម្ដាយមីងខ្ញុំបានទៅសួរនៅគុកដែលឃុំម្ដាយខ្ញុំ។ ពេលនោះ កងឈ្លបបានស្រែកសន្ធាប់ថា *"មិត្តឯងមកធ្វើអី បងមិត្តឯងត្រូវបានអង្គការកំទេចចោលបាត់ហើយ"* គេបានសួរទៀតថា *"មិត្តនារីឯងមកធ្វើអីនៅទីនេះ? ចង់ងាប់ដូចបងមិត្តនារីឯងដែរឬ?"*។ ខ្ញុំឈឺចាប់ជាទីបំផុត ពេលដឹងថាម្ដាយខ្ញុំស្លាប់។

work hard in a group. My group was required to complete digging a canal 5x2 meters wide and four meters deep per day.

The Khmer Rouge kicked me and hit me with a stick and a whip because I stole potato and sugarcane to fill my stomach. The scars on my body remain until today. One time, I stole the seedlings of rice plants to eat and the village chief came in, hit and kicked me and then handed me over to the Khmer Rouge militiamen. Because my mother protected me, the Khmer Rouge militiamen arrested my mother and me to be detained in prison at the Metoek commune. When I arrived at the prison, I was interrogated and beaten until I fainted. I did not know what kind of mistake I had made, making them torture a child like me. In the morning, I was tortured during questioning once again. After that they forced me, a young child, to work hard hoeing land, digging canals and transplanting in the rice field.

One day, the Khmer Rouge convened a meeting, saying, *"If any family wants to escape from this prison, we will smash that family"*. After living in the prison for about one month, I talked with mother to find a way to flee from this place. I asked my mother, *"You allow me to go or not?"* My mother answered, *"You have to go, you will have a chance to survive if you go, and you will die if you stay here"*. One night around 8 or 9, I managed to flee from the prison, because the Khmer Rouge militiamen who guarded the prison had just taken shelter from the rain. The sound of rain dropping heavily mixed with the sound of thunder and the sky was very dark. I ran along a path where the militiamen could not see me. When I crept under the barbed wire that surrounded the area, I got injured on my back, which caused a scar that I have until today. After passing the barbed wire, I ran without looking back. I tried to reach O Preal village, which was a place where my grandmother was living. When I met my grandmother and aunty, I told my aunty about what had happened in prison, and told her, *"Aunty, mother wants you to take a small belonging from her waist"*.

The next morning, my aunty went to the prison where my mother was detained. When she arrived there, the Khmer Rouge militiamen screamed at her *"What are you doing here, your older sister was already smashed by Angkar."* They added, *"Why do you come over here? Do you want to be killed like your sister or not?"* I was suffering so much when I learned that my mother had passed away.

ផ្នែក ៥
Chapter 5

# ការដាក់គុក និងធ្វើទារុណកម្ម

Imprisonment and Torture



Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោកស្រី ឡាយ បូនី



*លោកស្រី ឡាយ បូនី កើតក្នុងឆ្នាំ ១៩៥០ មានស្រុកកំណើតនៅ សង្កាត់លេខ៤ ក្រុងភ្នំពេញ។ លោកស្រី គឺជាដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៣ និងទី២៤ ខែតុលា ឆ្នាំ ២០១២។*

ពេលខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេបានធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តាមរយៈការប្រកាសឲ្យប្រជាជនប្រញាប់ចាកចេញពីទីក្រុងជាបន្ទាន់ ព្រោះខ្លាចអាមេរិកាំងមកទម្លាក់គ្រាប់បែកលើក្រុងភ្នំពេញ។ នៅថ្ងៃជម្លៀសនោះ ខ្ញុំមានការលំបាកខ្លាំងណាស់ ដោយសារខ្ញុំនៅសរសៃខ្ចី (ព្រោះទើបសម្រាលកូនបាន២០ថ្ងៃ តែកូននោះបានស្លាប់ពេលកើតមក) និងមានកូនតូចពីរនាក់ទៀត (មួយអាយុបីឆ្នាំ និងមួយទៀតអាយុ៥ឆ្នាំ) ហើយត្រូវធ្វើដំណើរក្រោមកំដៅថ្ងៃក្ដៅហែង។ ខ្ញុំចាកចេញដោយមិនមានយកអ្វីច្រើនទៅជាមួយទេ ហើយគ្រាន់តែចេញផុតពីផ្ទះ ឮថាគេលែងចាយលុយហើយ ពេលនោះខ្ញុំអត់មានសល់អង្ករមួយគ្រាប់សោះ ក្រៅពីបាយមួយឆ្នាំងដែលបានដាំតាំងពីព្រលឹម។ ទិដ្ឋភាពនៅលើផ្លូវមានសភាពស្ទះគ្រប់កន្លែង ព្រោះថាកន្លែងណាក៏ត្រូវចេញនៅថ្ងៃនោះដែរ មានទាំងឡាន ម៉ូតូកង់ មនុស្ស រទេះរុញកកកុញពេញផ្លូវ ធ្វើឲ្យការដំណើរបានយឺតៗបំផុត (ត្រឹមផ្ទះខ្ញុំម្ដុំពេជ្រទៅដល់សាលាច្បាប់ត្រូវចំណាយពេលមួយព្រឹកធំ)។

មុននឹងចាកចេញពីផ្ទះ ទាហានខ្មែរក្រហមពីរបីនាក់ (ម្នាក់ៗសុទ្ធតែមានស្ពាយកាំភ្លើងលើស្មា) បានមកដល់ផ្ទះ និយាយសំដីម៉ាត់ៗ ដោយឆ្មាររែផ្ការជើងថា *"ត្រូវតែរៀបចំអីវ៉ាន់ចេញនៅពេលឥឡូវនេះ ដាច់ខាតត្រូវតែចេញ"*។ ក្រោយពីការជម្លៀសចេញពីភ្នំពេញ គ្រួសារខ្ញុំបានធ្វើដំណើរទៅរស់នៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ នៅទីនោះ កូនស្រីខ្ញុំដែលមានជំងឺរ៉ាំរ៉ៃ (តាំងពីទើបតែចេញពីភ្នំពេញមក) បានស្លាប់ ក៏ព្រោះតែស្ថានភាពជំងឺកាន់តែធ្ងន់ទៅៗ និងគ្មានថ្នាំព្យាបាល។ មិនតែប៉ុណ្ណោះ គ្រួសារខ្ញុំបានរស់នៅលាក់ប្រវត្តិរបស់ខ្លួន ក៏ព្រោះតែប្ដីខ្ញុំគឺជាទាហានស័ក្តិ៣សម័យលន់ នល់ ហើយក៏ត្រូវបានគេចាត់ទុកថាជាគ្រួសារ *"អ្នកចំណូលថ្មី ឬអ្នក១៧មេសា"* ផងដែរ។ ដើមឆ្នាំ១៩៧៦ គ្រួសារអ្នកចំណូលថ្មីទាំងអស់ត្រូវបានពួកខ្មែរក្រហមជម្លៀសបន្តទៅនៅខេត្តពោធិសាត់ និងបាត់ដំបង។ ខណៈនោះ គ្រួសារខ្ញុំបានត្រូវគេបញ្ជូនឲ្យទៅរស់នៅសហករណ៍កោះជុំ ស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅទីនោះ គេចែកដីឲ្យយើងសង់ផ្ទះ ហើយគ្រួសារខ្ញុំមានសមាជិក១២នាក់ ត្រូវបំបែកជាបីគ្រួសារ (គ្រួសារបងប្រុសនិងប្រពន្ធ គ្រួសារខ្ញុំប្ដីនិងកូនមួយ និងគ្រួសារម្ដាយខ្ញុំ និងប្អូនខ្ញុំបួននាក់)។ បន្ទាប់មក គេឲ្យខ្ញុំធ្វើការនៅកងចំការ ដោយតម្រូវឲ្យរែកទឹក១០០អំរែកក្នុង១ថ្ងៃ។ មួយរយៈក្រោយមក កូនប្រុសខ្ញុំឈឺរាគមិនមានថ្នាំព្យាបាល ហើយក៏បានស្លាប់នៅមន្ទីរពេទ្យស្រុកកណ្ដៀង។ ចំណែកប្អូនស្រីពៅរបស់ខ្ញុំក៏បានស្លាប់ដោយសារជំងឺហើម។

ក្រោយមក ខ្មែរក្រហមបានយកខ្ញុំនិងប្ដីទៅដាក់នៅមន្ទីរកសាងខ្លួនថ្កោល។ ពេលទៅដល់ទីនោះភ្លាម យោធាប្អូនប្រាំនាក់បានចេញមកទាត់ធាក់ប្ដីខ្ញុំ រ៉ៃបែកឈាម ហើយសួរថា *"កាំភ្លើងខ្លីឯងលាក់នៅឯណា"*។ បន្ទាប់មកគេបានយកប្ដីខ្ញុំទៅដាក់ក្នុងគុកងងឹត រីឯខ្ញុំទៅដាក់ក្នុងគុកមួយដែលមានមនុស្សណែន។ ខ្ញុំដេកទាំងអង្គុយនៅក្នុងគុកនោះ។ នៅគុក ខ្ញុំបានឃើញយោធាក្មេងម្នាក់ដែលត្រូវជាកូនមេគុក ស្ពាយកាំភ្លើងអូសដី បានយកអ្នកទោសស្រីម្នាក់ចេញទៅដោយចោទថាលួចស៊ីត្រីអាំង បន្ទាប់មកវាបានយកជំពុះទង់ចាក់អ្នកទោសស្រីនោះចំចុងដង្ហើមទាញចុះមកដល់ពោះ ធ្លាយពោះវៀនទ្រុល។ ខ្ញុំខំខ្ទប់មាត់អត់ហ៊ានស្រែកទេ ព្រោះខ្លាចគេយកទាំងខ្ញុំទៅទៀត។ រាល់បីថ្ងៃម្ដង ខ្មែរក្រហមតែងតែមកយកមនុស្សទាំងខ្សែៗចេញទៅភាគ(សម្លាប់)។ ដំបូង ខ្ញុំមិនដឹងថាពាក្យដែលខ្មែរក្រហមនិយាយថា *"យកទៅភាគ"* គឺយកទៅណានោះទេ ក្រោយមកទើបខ្ញុំដឹងថា *"យកទៅភាគគឺយកទៅសម្លាប់ចោល"*។ ប្រហែល១ខែក្រោយមក ប្ដីខ្ញុំក៏ត្រូវគេយកទៅភាគ (សម្លាប់)ដែរ។ ចុងឆ្នាំ១៩៧៧ គេបានបញ្ជូនខ្ញុំទៅមន្ទីរកសាងខ្លួនបឹងគល់ ឃុំបឹងខ្នារ ស្រុកបាកាន។ នៅទីនោះ គេបង្ខំឲ្យខ្ញុំធ្វើការទាំងថ្ងៃទាំងយប់ ដោយឲ្យហូបបបររាវល់វែក។ ១ខែក្រោយមក គេបានបញ្ជូនខ្ញុំទៅមន្ទីរកសាងខ្លួនត្រាចក្រោល ឃុំបឹងខ្នារ ស្រុកបាកាន។ ការងារនៅទីនេះរឹតតែពិបាក គឺគេចាត់ឲ្យខ្ញុំទៅទប់ទំនប់ទឹក។ គេឲ្យពួកយើងចុះក្នុងទំនប់ដើម្បីទប់ដីមាត់ទំនប់ ខណៈដែលអ្នកខ្លះទៀតត្រូវមុជក្នុងទឹកដើម្បីយកដីពីបាតទំនប់មកដាក់នៅត្រង់មាត់ទំនប់នោះ។ នៅមន្ទីរនេះ គឺជាកន្លែងមហាវិនាសកម្មបំផុត ព្រោះមានមនុស្សច្រើនណាស់ត្រូវបានគេសម្លាប់ ព្រោះតែលួចរត់ ហើយចំពោះអ្នកដែលគ្មានកម្លាំង មិនអាចទៅធ្វើការបាន ត្រូវគេទុកឲ្យដេកស្លាប់ក្នុងរោងដំបូលស័ង្កសីជាមួយនឹងកំដៅថ្ងៃក្ដៅហែង។ ខ្ញុំបានជាប់នៅទីនេះរហូតដល់កងទ័ពរណសិរ្សមករំដោះក្នុងខែឧសភា ឆ្នាំ១៩៧៩។

# MRS. LAY BONY

*Mrs. Lay Bony was born in 1950 in Phnom Penh city. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 23rd and 24th October 2012.*

When the Khmer Rouge took control of Phnom Penh city on 17 April 1975, they began transferring the people under their announcement that the people needed to hurry and leave the city, due to the fear that American aircrafts would bomb Phnom Penh city. On the eviction day, it was very difficult for me to move in the hot weather under the sun, because I had given birth 20 days ago, and the newborn died immediately after it was born. Also, I had two small children (three years old and five years old) to look after. My family left our home with only a small package. Later, I heard that money was no longer used and I did not take husked rice with me; I had only taken a pot of cooked rice I had made earlier that morning. The road was very crowded with cars, motorbikes, pulling carts and a herd of people, which caused us to walk very slowly. Before leaving home, two or three Khmer Rouge soldiers with rifles on their shoulder had come into my home and said strongly with their expressing gestures, *"you all have to prepare the package to move immediately and absolutely"*.

After being evicted from Phnom Penh city, my family was allowed to live in Khsach Kandal district, Kandal province. Over there, my daughter, who became ill while we were moved from Phnom Penh, died because her illness had become worse and there was no medicine for treatment. My family lived by hiding our background because my husband had been a captain during the Lon Nol regime, and we were considered as *"the newcomers"* or *"17 April people"*.

A short time later, all newcomer families were forcibly transferred to live in the Pursat and Battambang provinces. During that time, my family was sent to live in Koh Chum Co-operative, Bakarn district, Pursat province. The Khmer Rouge offered us land to build shelter there and my family, 12 members in total, was divided up into three small families (my brother's family including him and his wife; my own family including myself, my husband, and our son; and my mother's family including my mother and my four siblings). I was sent to work in the plantation unit, where the Khmer Rouge required me to carry 100 yokes[17] of water per day. A while later, my son got dysentery and died, because there was no medicine for treatment available at Kandieng district's hospital. Meanwhile, my youngest sister died from the 'swelling-up' disease.[18]

Later on, the Khmer Rouge sent me and my husband to Thkol reeducation center. Immediately after our arrival, four or five Khmer Rouge militiamen appeared, kicked and hit my husband until he was bleeding and asked *"Where you hide your pestle?"* Then, they locked up my husband in a dark cell, while I was detained in a narrow and crowded cell. I could not lay down there and had to sleep while sitting. One day in prison, I watched a young Khmer Rouge militiaman taking a female prisoner from the cell with the accusation of stealing dried fish to eat. He was the prison chief's son and dragged a rifle along the ground while walking. He stabbed the lady with his bayonet into the center of her chest and pulled the knife down to her belly until she was dead. I tried to close my mouth with my hand, because I dared not to scream out of fear that they would kill me as well. Every three days, the Khmer Rouge took people in lines to the Zone, which meant that they were to be killed. At first, I did not know the meaning when I heard the Khmer Rouge say *"take to the Zone"*, but later on I learned that this meant *"take to be killed"*. About one month later, my husband was brought to the Zone as well.

At the end of 1977, the Khmer Rouge sent me to Boeung Kol reeducation center in Boeung Khnar commune, Bakarn district. Over there, they forced me to work day and night, and only offered a ladle of watery porridge to eat. A month later, I was moved again to Trach Kraul reeducation center in Boeung Khnar commune, Bakarn district. Working conditions there were even more difficult, because I had to work in a dam filled with water. They ordered some of us, including me, to stand at the edge of the dam and block the soil from flowing in, while some others had to dive into the water to bring up the soil from the bottom of the dam and put it on the edge of the dam. Trach Kraul center was extremely tragic, because numerous people were killed after trying to escape, while other people got exhausted and weak from hunger and were unable to work. Those people were lying down to die in a hall with a zinc roof, under the heat of the sun in the hot season. I was kept working in Trach Kraul until the United Front troops came to liberate in May 1979.

17 bamboo pole with two water containers attached
18 Edema caused by malnutrition

# លោក ស៊ុំ រិទ្ធី



*លោក ស៊ុំ រិទ្ធី កើតក្នុងឆ្នាំ១៩៥៣ មានស្រុកកំណើតនៅស្រុកកងមាស ខេត្តកំពង់ចាម។ លោកគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។*

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកោះហៅមន្ត្រីរាជការនៅខេត្តសៀមរាបឲ្យទៅប្រជុំនៅសាលាខេត្តសៀមរាប។ នៅក្នុងកិច្ចប្រជុំនោះ ខ្មែរក្រហមបានប្រកាសតម្រូវឲ្យមន្ត្រីរាជការទៅទទួលការអប់រំចំនួន៣ថ្ងៃដើម្បីទទួលសម្តេចនរោត្តមសីហនុ ដោយមិនចាំបាច់យកអីវ៉ាន់ទៅជាមួយទេ។ ភាពច្របូកច្របល់នៅក្នុងក្រុងកាន់តែខ្លាំងឡើងៗ តាមពិតខ្មែរក្រហមបានយកមន្ត្រីរាជការទាំងនោះទៅសម្លាប់ចោល ក្រោយមកខ្ញុំបានឃើញសាកសពជាច្រើននៅក្នុងត្រង់សេបារាយទឹកថ្លា និងចំរាក់ភ្នំបាក់ខែង។ នៅថ្ងៃទី១៨ ខែមេសា ខ្មែរក្រហមបានប្រកាសតាមមីក្រូឲ្យប្រជាជនចាកចេញពីក្រុងសៀមរាបក្នុងរយៈពេល៣ថ្ងៃ ដោយមិនចាំបាច់យកអីវ៉ាន់ទៅជាមួយទេ ដើម្បីអង្គការសំអាតខ្មាំងចេញពីទីក្រុង និងខ្លាចអាមេរិកកាំងទម្លាក់គ្រាប់បែក។ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរទៅទិសខាងលិចក្រោមការភ្ជង់កាំភ្លើងពីទាហានខ្មែរក្រហម។ យើងបានធ្វើដំណើរតាមការបង្ហាញផ្លូវ និងការបញ្ជារបស់ទាហានខ្មែរក្រហម។ ខណៈនោះ ខ្ញុំបានឃើញខ្មែរក្រហមយកស្ពាយកាំភ្លើងវាយអ្នកដែលជំទាស់នឹងបញ្ជារបស់គេ និងគំរាមបាញ់សម្លាប់។ គ្រួសារខ្ញុំត្រូវបានគេឲ្យរស់នៅភូមិខ្នាត ឃុំសៀមរាប។ អ្នកដែលត្រូវគេជម្លៀសទៅរស់នៅភូមិនោះ ត្រូវបានខ្មែរក្រហមចាត់ទុកជា *“ប្រជាជន១៧មេសា”* ហើយត្រូវស្ថិតក្រោមការឃ្លាំមើលរបស់អ្នកមូលដ្ឋាន ព្រោះខ្មែរក្រហមបានគិតថា ប្រជាជន១៧មេសា គឺជាខ្មាំង និងជាទាហានលន់នល់។ ពួកខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើការដោយគ្មានពេលសម្រាក និងអាហារហូបចុកមិនគ្រប់គ្រាន់។

នៅខែមករា ឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានចាប់មនុស្សប្រុសនៅក្នុងភូមិខ្នាតទាំងអស់ទៅដាក់មន្ទីរសន្តិសុខភូមិភាគឧត្តរដែលជាគុករបស់បារាំងពីដើម ដែលមានខ្ញុំ និងបងថ្លៃប្រុសខ្ញុំផងដែរ។ នៅក្នុងមន្ទីរឃុំឃាំង ខ្ញុំបានត្រូវគេដាក់ខ្នោះដៃខ្នោះជើងឲ្យអង្គុយនៅមួយកន្លែង សម្រាតខោអាវទុកតែខោខ្លីដ៏កខ្វក់មួយតែប៉ុណ្ណោះ។ ខ្ញុំត្រូវបានគេសួរដូចជាខ្មាំង និងចោទថាជាភ្នាក់ងារស៊ីអាយអេ តែខ្ញុំបានឆ្លើយប្រាប់ទាហានខ្មែរក្រហមថា *“ខ្ញុំមិនមែនជាទាហានលន់ នល់ និងមិនមែនជាស៊ីអាយអេទេ ខ្ញុំជាជាងម៉ូតូ”*។ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេលមួយខែ ខ្មែរក្រហមបានយកខ្ញុំឲ្យទៅជួសជុលម៉ូតូនៅក្រោមសាលាដំបូង ហើយយកមកដាក់ឃុំវិញនៅពេលយប់។ ថ្ងៃមួយក្នុងពេលកំពុងធ្វើការនៅក្នុងមន្ទីរឃុំឃាំង ខ្មែរក្រហមបានចាប់ក្មេងប្រុសម្នាក់អាយុ១០ឆ្នាំ ដោយចោទប្រកាន់ថា ក្មេងនេះលួចរត់ ហើយបានបញ្ជាឲ្យខ្ញុំយកឈើប្អូនជ្រុងវាយឲ្យខ្លាំងទៅលើក្មេងប្រុសនោះ តែខ្ញុំមិនបានវាយក្មេងនោះឲ្យខ្លាំងតាមបញ្ជារបស់គេទេ ស្រាប់តែមេខ្មែរក្រហមបានយកកំណាត់ឈើប្អូនជ្រុងវាយត្រង់ចង្កេះខ្ញុំវិញ។ មានគ្រាមួយទៀត ខ្មែរក្រហមបានយកកំណាត់ឈើប្អូនជ្រុងវាយខ្ញុំម្តងទៀត ដោយសារតែខ្ញុំបានរើសគ្រាប់ខ្នុរចំនួន១០គ្រាប់ (ដែលខ្មែរក្រហមបានស៊ីចោលលើគ្រែ) ដោយគ្មានការអនុញ្ញាតពីខ្មែរក្រហម។ នៅដើមឆ្នាំ១៩៧៨ ខ្ញុំត្រូវបានគេដាក់ខ្នោះបម្រុងយកទៅសួរចម្លើយនៅវត្តធម្មយុត្តិ គ្រានោះគិតថា ផ្លូវមានពីរ ឆ្លើយត្រង់ក៏ស្លាប់ មិនត្រង់ក៏ស្លាប់ តែសំណាងល្អខ្ញុំត្រូវបានគេដោះលែងវិញ។

## ស្ថានភាពអ្នកជាប់ឃុំនៅក្នុងមន្ទីរភូមិភាគឧត្តរ (ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩)

នៅមន្ទីរភូមិភាគឧត្តរមានអ្នកទោសសរុបប្រហែល ១០០០នាក់ ដែលក្នុងនោះមានប្រជាជន យោធា និងកម្មាភិបាលខ្មែរក្រហម។ អ្នកដែលជាប់ឃុំត្រូវបានគេដាក់ខ្នោះ និងឃុំនៅក្នុងបន្ទប់ជាមួយអ្នកទោសឯទៀត។ បន្ទប់នៅក្នុងមន្ទីរឃុំឃាំងមានលក្ខណៈគួរឲ្យខ្លើមរអើម មានអ្នកដែលជាប់ឃុំ (អ្នកទោស) ជាច្រើនត្រូវបានគេសម្លាប់ និងស្លាប់ដោយសារអត់អាហារជារៀងរាល់ថ្ងៃ។ អាហារគ្មានជាតិអំបិលគ្រប់គ្រាន់បានធ្វើឲ្យកើតមានជំងឺ ទឹកត្រូវបានគេឲ្យផឹកតែម្តងប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយពេលខ្លះមិនឲ្យក៏មានដែរ អ្នកទោសមិនត្រូវបានគេអនុញ្ញាតឲ្យងូតទឹកទេ។ អ្នកទោសត្រូវបានគេដាក់ខ្នោះទាំងយប់ទាំងថ្ងៃ ហើយបញ្ចេញឲ្យទៅធ្វើការនៅពេលថ្ងៃ។ អ្នកទោសដែលត្រូវបានគេហៅឈ្មោះនៅពេលល្ងាច នឹងត្រូវបណ្តើរចេញទៅឡើងឡាននៅវត្តធម្មយុត្តិ ហើយដឹកចេញទៅបាត់ ហើយគេក៏មិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញទេ។ អ្នកទោសត្រូវបានគេដោះខ្នោះជើង និងដាក់ខ្នោះដៃ ហើយបណ្តើរយកទៅសួរចម្លើយនៅក្នុងវត្តធម្មយុត្តិ ម្តង៨នាក់ គឺនៅពេលព្រឹកម្តង ពេលល្ងាចម្តង។

# MR. SOUM RITHY

*Mr. Soum Rithy was born in 1953 at Kang Meas district, Kampong Cham province. He is a Civil Party in the second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 18 April 1975, the Khmer Rouge convoked the civil servants from Siem Reap province to join a meeting at the Siem Reap Provincial Office. In the meeting, the Khmer Rouge announced that they required those civil servants to receive education for three days in order to welcome the King Sihanouk, and that there was no need to bring their belongings. The disordered situation in the city increased, and in fact the Khmer Rouge had brought those civil servants to be killed and I later on saw the dead bodies inside Baray Toek Thla trench and Bar Kheng Mountain. On the same day (18 April 1975), the Khmer Rouge also announced that the people must leave Siem Reap city for three days and that there was no need to bring their belongings with them, in order for Angkar to clean up the enemies from the city and due to being afraid of the Americans bombing the city.

My family traveled in the west direction with the pointing gun of the Khmer Rouge soldiers. At that moment, I saw that the Khmer Rouge soldiers hit the people who opposed their order with rifle butts and threatened to kill those people. My family was sent to live in Khnat village, Siem Reap commune. The people who were evicted to live in that village were considered as *"17 April people"* and were kept track of by the base people because the Khmer Rouge thought that the 17 April people were the enemies and Lon Nol soldiers. The Khmer Rouge forced us to work without time to rest and adequate food to eat.

In January 1977, the Khmer Rouge seized all the men in Khnat village and put them in the North Zone security center that was a former prison from the French colonial era. My brother-in-law and I were among those men. In the detention center, I was shackled and sat on the ground, forced to take off my clothes and wore only dirty short pants. I was questioned as an enemy and charged with being a CIA spy, but I told the Khmer Rouge that *"I am not a Lon Nol soldier, nor a CIA spy, I am a motorbike repairer"*. After being detained for a month, the Khmer Rouge sent me to repair motorbikes under the provincial hall and I was brought back to the cell at nighttime. One day, while working inside the detention center, the Khmer Rouge arrested a 10-year-old boy with an allegation that this boy had tried to flee and ordered me to hit him strongly with a wooden stick. When I did not follow their order to hit that boy strongly, suddenly a chief of the Khmer Rouge brought that wooden stick to hit my waist. The Khmer Rouge hit me again with a wooden stick when I picked up ten nuts of jackfruit to eat (that had been left by the Khmer Rouge on the bed) without asking permission from them. In early 1978, I was shackled and ready to be sent for questioning at Thormayut pagoda. At that moment, I thought of the two options I had: speak honestly and die, or tell a lie and die. But luckily, I was released.

**The situation of the people detained in the North Zone security center (from 1977 to 1979)**

In North Zone security center, there were approximately 1,000 prisoners, who were civilians, military, and Khmer Rouge cadres. The detainees were shackled and detained in a cell with other prisoners. The cells in the detention center were very dirty and nauseous. Every day, prisoners were being taken for execution or died from starvation. The food was inadequate, causing detainees to become ill and water was only allowed to be drunk one time per day while sometimes it was not offered to drink. The prisoners were also not allowed to take a bath. The prisoners were shackled both daytime and nighttime, and were also sent out to work in the daytime. The prisoners who were called out by their names would be escorted to be loaded onto a truck at Thormayut pagoda and transported away. We never saw those prisoners come back. The prisoners had unshackled hands but were chained around their legs, and were escorted to be questioned at Thormayut pagoda, 8 prisoners at a time – once in the morning and another time in the evening.

# លោក ណុប អឿន



*លោក ណុប អឿន កើតក្នុងឆ្នាំ១៩៤៨ មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ភូមិដែលខ្ញុំរស់នៅ គឺភូមិដំណាក់អំពិល ឃុំការពារ ស្រុកឈូក ខេត្តកំពត។ ខណៈនោះ ខ្មែរក្រហមមិនបានជម្លៀសប្រជាជនចេញពីភូមិទេ។ ខ្ញុំបានរស់នៅធ្វើជាអ្នកមូលដ្ឋាននៅក្នុងភូមិដំណាក់អំពិល ហើយត្រូវបានគេចាត់តាំងឲ្យធ្វើជាមេក្រុមដឹកនាំប្រជាជនធ្វើស្រែ និងលើកទំនប់។ ពេលនោះ មិនទាន់មានការដាក់ឲ្យហូបរួមទេ គេឲ្យយើងហូបបាយតាមផ្ទះរៀងៗខ្លួន។

នៅចុងឆ្នាំ១៩៧៦ អង្គការខ្មែរក្រហមបានយកឡានមកដឹកខ្ញុំ និងប្រជាជនឯទៀតទៅស្រុក១៣០ ខេត្តកំពង់ធំ ដោយប្រាប់ថាទៅធ្វើការនៅទីនោះ។ ពេលមកដល់ស្រុក១៣០ភ្លាម ខ្មែរក្រហមបានសួរខ្ញុំថា *"តើឯងក្បត់អង្គការតាំងពី ខែណា ឆ្នាំណា ?"* ខ្ញុំបានឆ្លើយថា *"ខ្ញុំមិនដឹងរឿងក្បត់អីនោះទេ"* ស្រាប់តែខ្មែរក្រហម បានស្ទុះមកវាយទាត់ធាក់ខ្ញុំបណ្តាលឲ្យបាក់ឆ្អឹងជំនីខាងឆ្វេង រួចអូសខ្ញុំទៅដាក់ក្នុងបន្ទប់ឃុំ។ ខ្មែរក្រហមបានដាក់ខ្នោះជើងខ្ញុំនឹងរបាដែក ជាមួយអ្នកទោសឯទៀត។ ពួកវាបានយកខ្ញុំទៅធ្វើទារុណកម្មនិងសួរចម្លើយរាល់មួយសប្តាហ៍ម្តងៗ។ ពេលខ្លះ គេវាយទាត់ធាក់រហូតដល់ខ្ញុំសន្លប់ រួចអូសខ្ញុំទៅដាក់បន្ទប់ឃុំវិញ។ បីខែក្រោយមក ពួកវាបានបញ្ចេញខ្ញុំពីបន្ទប់ឃុំឲ្យទៅធ្វើការជាមួយនឹងអ្នកទោសដទៃទៀតពេលថ្ងៃ និងយកទៅដាក់បន្ទប់ឃុំវិញនៅពេលយប់។ ពួកវាបាន បង្ខំឲ្យខ្ញុំជាន់ដីឲ្យមួយម៉ែត្រគីបក្នុងមួយថ្ងៃសំរាប់ធ្វើឥដ្ឋនិងក្បឿង និងផ្តល់បបររាវបន្តិចបន្តួចលាយនឹងត្រកួនឲ្យហូបតែប៉ុណ្ណោះ។ អំឡុងពេលធ្វើការងារ មានឈ្លបឈរយាមព្រោះខ្លាចយើងរត់។ ពេលនោះ អ្នកដែលជាប់គុកជាមួយខ្ញុំចេះតែបាត់ខ្លួនជាបន្តបន្ទាប់។ ខ្ញុំបានធ្លាក់ខ្លួនឈឺគ្រាំគ្រា ហើយចេះតែគិតថាមិនដឹងថ្ងៃណានឹងត្រូវបាត់ខ្លួនដូចអ្នកទោសមុនៗទេ។ ខ្ញុំត្រូវគេបង្ខំឲ្យធ្វើការទាំងឈឺ ដោយពុំមានថ្នាំព្យាបាល និងហូបចុកមិនគ្រប់គ្រាន់ឡើយ។ ខ្ញុំបានជាប់គុកនៅទីនេះរហូតដល់ថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩។

ក្រោយរបបខ្មែរក្រហម ខ្ញុំបានបាត់បង់ផ្ទះសំបែង និងសាច់ញាតិ ដូចជា ឪពុកមា២នាក់ជាទាហានត្រូវបានបាត់ខ្លួនទាំងគ្រួសារ បងប្រុសជីដូនមួយជាទាហានជើងទឹកនៅកំពង់សោមត្រូវបានយកទៅសម្លាប់ និងប្អូនប្រុសបង្កើតពីរនាក់ធ្វើការនៅកងចល័តបានបាត់ខ្លួន។

# MR. NOB OEUN

*Mr. Nob Oeun was born in 1948 at Chhouk district, Kampot province. He is a Civil Party in Case 002 in the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 17 April 1975, the Khmer Rouge entered my village in Damnak Ampil, Kar Pear commune, Chhouk district, Kampot province. The Khmer Rouge did not transfer the people from my village. I lived as one of the base people in Damnak Ampil village and was later assigned to be the team chief to lead the people to work in the rice fields and dig a canal. At that time, we did not yet have collective eating and the Khmer Rouge allowed us to eat at home individually. At the end of 1976, the Khmer Rouge took trucks to transport myself, and others, to District 103, Kampong Thom province. They told us we were going to work over there. When we arrived in District 103, the Khmer Rouge immediately questioned me, saying, *"You betray Angkar on what month and year?"* I replied, *"I never knew about the betrayal"*. Suddenly, they rushed to kick and hit me, breaking my left rib, and then dragged me to a cell. The Khmer Rouge shackled me with an iron bar attached to other prisoners. They took me for questioning and tortured me once a week. Sometimes, they kicked me until I fainted, then just dragged me back to the cell.

Three months later, they sent me out of my cell during the day to work with other prisoners and brought me back to the cell at night. They forced me to paddle mud, one square meter per day, for making bricks and roofing tiles. I was only offered a little bit of watery porridge mixed with water convolvulus to eat. While we were working, the Khmer Rouge militiamen guarded us because they feared that we would try to escape. At that time, the people who were detained with me kept disappearing. I became very sick and frequently wondered on which day would be my turn to disappear as the previous prisoners had. I was forced to work, while being seriously ill, without medicine for treatment and with insufficient food to eat. I was kept as a prisoner until the liberation day on 7 January 1979.

During the Khmer Rouge regime, I lost my home and I lost my family – two of my uncles who were soldiers disappeared, my brother cousin who was in the Navy at Kampong Som province was killed, and two of my brothers who worked in the mobile unit also disappeared.

# លោក ជុំ ម៉ី



*លោក ជុំ ម៉ី កើតក្នុងឆ្នាំ១៩៣៣ មានស្រុកកំណើតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង។ លោកគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។*

មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំធ្វើការនៅក្នុងមន្ទីរកិច្ចការសាធារណៈនៃខេត្តកំពង់ស្ពឺ ។ដោយសារសង្គ្រាម ខ្ញុំបាននាំគ្រួសារភៀសខ្លួនមករស់នៅផ្ទះបងថ្លៃនៅទួលគោក និងក្រោយមកទៀតបាននាំគ្រួសារភៀសខ្លួនទៅនៅផ្ទះលោកវេជ្ជបណ្ឌិត ឡុក លាន នៅក្បែរផ្សារដេប៉ូ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៨ព្រឹក ខ្ញុំបានជិះម៉ូតូទៅយកប្អូនប្រុសនៅវិទ្យាល័យសន្ធរម៉ុក។ ប្រហែលជាម៉ោង៥ល្ងាច ខ្មែរក្រហមបានមកដល់ផ្ទះលោកវេជ្ជបណ្ឌិត ឡុក លាន ហើយបានប្រាប់ឲ្យអ្នកនៅក្នុងផ្ទះទាំងអស់រៀបចំអីវ៉ាន់បន្តិចបន្តួចចាកចេញពីទីក្រុងភ្នំពេញតែបីថ្ងៃទេ ព្រោះថាអាមេរិកាំងនឹងមកទំលាក់គ្រាប់បែកលើក្រុងភ្នំពេញ។ ខ្ញុំបានឃើញខ្មែរក្រហមបានបាញ់សម្លាប់អ្នកដែលមិនព្រមចេញនៅនឹងកន្លែង។ ដូច្នេះគ្រួសារខ្ញុំ និងគ្រួសារលោកវេជ្ជបណ្ឌិតបានចាកចេញពីផ្ទះនៅវេលាម៉ោង៩យប់ ទៅសំរាកនៅមាត់ទន្លេសាប ព្រែកព្នៅ។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំបានឃើញសាកសពប្រជាជនស៊ីវិល និងទាហានយ៉ាងច្រើន។

នៅថ្ងៃបន្ទាប់ តាមផ្លូវទៅកាន់ព្រែកក្តាម ខ្ញុំបានឃើញទាហានខ្មែរក្រហមក្មេងៗអាយុពី១៣ទៅ១៤ឆ្នាំ មានកាន់កាំភ្លើងអាកា៤៧ ដើររកសម្លាប់ឪពុកម្តាយរបស់ពួកគេ ព្រោះថាក្មេងទាំងនោះចាត់ទុកឪពុកម្តាយរបស់គេជាខ្មាំង។ ពេលធ្វើដំណើរដល់ព្រែកក្តាម កូនប្រុសខ្ញុំអាយុ ១ឆ្នាំកន្លះ បានកើតជំងឺរាគ និងបានស្លាប់នៅទីនោះដោយសារមិនមានថ្នាំសង្កូវ។ បន្ទាប់ពីកប់សពកូនរួចហើយ គ្រួសារខ្ញុំបានបន្តដំណើរទៅមុខរហូតដល់មូលដ្ឋានទាហានខ្មែរក្រហមនៅភ្នំជើងឆ្នុកខេត្តកណ្តាល។ ខ្មែរក្រហមបានឲ្យយើងស្នាក់នៅក្រោយវត្តក្បែរនោះ។ ព្រឹកថ្ងៃបន្ទាប់ វេលាម៉ោង១០ ខ្មែរក្រហមបានប្រកាសតាមមីក្រូស្វែងរកជាងជួសជុលម៉ាស៊ីនឲ្យត្រឡប់ទៅក្រុងភ្នំពេញដើម្បីបំរើអង្គការ។ ឮការប្រកាសដូចនេះ ខ្ញុំបានប្រាប់ខ្មែរក្រហមថា ខ្ញុំជាជាងជួសជុលម៉ាស៊ីន ដូច្នេះខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យមកធ្វើការនៅទីក្រុងភ្នំពេញ។ ពេលចេញមកភ្នំពេញវិញ ខ្មែរក្រហមបានឲ្យខ្ញុំនិងជាងជួសជុល៦នាក់ទៀតឡើងជិះទូកនៅទន្លេសាប ហើយមិនអនុញ្ញាតឲ្យនាំយកក្រុមគ្រួសារទៅជាមួយទេ ដោយបានប្រាប់ថា *“អង្គការនឹងមើលថៃគ្រួសារឲ្យ”*។ នៅភ្នំពេញ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅផែឫស្សីកែវក្រោយមកធ្វើការនៅអូរឫស្សី ហើយក៏បានជួបប្រពន្ធនិងកូនស្រី២នាក់នៅទីនោះ។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ ខ្ញុំ និងមនុស្សបីនាក់ទៀតបានត្រូវខ្មែរក្រហមដឹកយកទៅមន្ទីរស-២១ (គុកទួលស្លែង)។ ខ្ញុំបានសុំខ្មែរក្រហមឲ្យនាំទៅជួបប្រពន្ធ ស្រាប់តែខ្មែរក្រហមទាត់ខ្ញុំមួយជើងធ្លាក់ដីហើយបានបោចសក់ឡើង និងនិយាយថា *“ឯងហ៊ានទារឲ្យនាំទៅជួបប្រពន្ធឯងផង ចង្រៃវាយក អង្គការត្រូវលុបបំបាត់គ្រួសារទាំងអស់”*។ នៅក្នុងគុកខ្ញុំត្រូវបានគេសំរាតខោអាវឲ្យនៅតែខោខ្លីមួយប៉ុណ្ណោះ បិទមុខ និងយកទៅដាក់ក្នុងបន្ទប់មួយតែម្នាក់ឯង ដាក់ខ្នោះដៃជើង និងរងទណ្ឌកម្មសួរចម្លើយដោយការវាយនឹងកំណាត់ឈើ ឆក់ខ្សែភ្លើង និងដកក្រចក មិនតែប៉ុណ្ណោះខ្មែរក្រហមបានចោទខ្ញុំថាជាស៊ីអាយអេ/កាហ្សេប៉េ។ ដើម្បីមានជីវិតរស់ ខ្ញុំបានប្រឌិតចម្លើយសារភាពថា *“ខ្ញុំជាស៊ីអាយអេ”*។ ខ្មែរក្រហមបានយកកំណត់ហេតុឲ្យខ្ញុំចុះហត្ថលេខា ដោយមិនអាចតវ៉ាបាន។

# MR. CHUM MEY

*Mr. Chum Mey was born in 1933 at Preah Sdech district, Prey Veng province. He is a Civil Party in the first case and second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

Before 17 April 1975, I worked in the Department of Public Affairs of Kampong Speu province. During the war I had brought my family to live in my relative-in-law's house at Tuol Kork area, Phnom Penh city. We then moved to live in Dr. Lok Lean's house, which was located nearby Phsar Depo market. In the morning of 17 April 1975, I rode on motorbike to pick up my younger brother at Santhor Muk High School. In the evening at around 5pm, the Khmer Rouge came in Dr. Lok Lean's house and told all the people inside the house to hurry and prepare their belongings to leave from Phnom Penh city for three days because American aircrafts would bomb Phnom Penh city. I saw the Khmer Rouge shot dead the people who refused to move. My family and Dr. Lok Lean's family left from home and at 9 pm stopped to take rest at the bank of Tonle Sap River, Prek Phnov area. Along the way, I saw many dead bodies of civilians and soldiers. On the way to Prek Kdam area the next day, I saw young Khmer Rouge soldiers, around 13 to 14 years old, holding AK 47 rifles and looking for their parents to execute because those young Khmer Rouge soldiers considered their parents as enemies.

When I arrived in Prek Kdam, my son (one year old and a half) got diarrhea and died there because there was no medicine for treatment. After burying the dead body of my son, my family continued the journey until we reached the Khmer Rouge soldier's base at Cheung Chhnok Mountain in Kandal province. The Khmer Rouge allowed us to stay behind a pagoda nearby. At 10am the next morning, the Khmer Rouge announced through loudspeakers they wished to recruit a machine repairer to go back to work in Phnom Penh city for Angkar. Hearing their announcement, I told the Khmer Rouge that I was a machine repairer, so the Khmer Rouge sent me back to work in Phnom Penh city. On the journey back to Phnom Penh, the Khmer Rouge got me and six other machine repairers to board at Tonle Sap River and did not allow us to bring our families along by saying that, *"Angkar will take care of your family on your behalf"*.

In Phnom Penh city, Angkar sent me to work at Russey Keo port and then transferred to work at O Russey area, and I also met my wife and two daughters over there. On 28 October 1978, the Khmer Rouge took three other people and me to the Department S-21 (Tuol Sleng prison). I asked the Khmer Rouge to bring me to meet my wife, when suddenly the Khmer Rouge kicked me. I fell down to the ground and the Khmer Rouge grabbed my hair up, and said, *"Oh Shit! You dare demand to meet your wife, Angkar needs to eliminate the family relationship"*. In the prison, I was undressed and left wearing only short pants, blindfolded. I was then detained alone in a cell, with my hands and legs shackled. I was tortured for questioning, by being hit with a wooden stick, electric shock and pulling out nails. Not only that, but the Khmer Rouge alleged that I was CIA/KGB spy. In order to survive, I confessed fictionally that *"I am CIA spy"*. After that, the Khmer Rouge took the note for me to sign without making any argument.

ផ្នែក ៦
Chapter 6

# អាពាហ៍ពិពាហ៍ដោយបង្ខំ

## Forced Marriage


Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោក អ៊ុម ប៊ុនឈឿន



*លោក អ៊ុម ប៊ុនឈឿន កើតក្នុងឆ្នាំ១៩៥៥ មានស្រុកកំណើតនៅស្រុកសង្កែ ខេត្តបាត់ដំបង។ លោកគឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។*

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំ និងប្រជាជនចេញពីទីក្រុងបាត់ដំបងឲ្យទៅរស់នៅក្នុងព្រៃ។ នៅទីនោះ ពួកយើងត្រូវរកឈើ និងស្បូវធ្វើទីជម្រកដោយខ្លួនឯង។ បន្ទាប់មកគេបានបែងចែកកំលាំងជាបីក្រុម គឺក្រុមមនុស្សចាស់ជាកំលាំងសម្រាប់ធ្វើស្រែ ក្រុមយុវជន (អ្នកនៅលីវ) ជាកំលាំងលើកទំនប់ជីកប្រឡាយ និងក្រុមកុមារ។ ខ្ញុំត្រូវបានគេឲ្យនៅធ្វើការក្នុងកងយុវជន។ ខ្មែរក្រហមបានបង្ខំឲ្យពួកយើងធ្វើការទៅតាមផែនការរបស់វា គឺមួយក្រុមដែលមានគ្នា៣០នាក់ត្រូវជីកឲ្យបាន បាត៤ម៉ែត្រ កំពស់២ម៉ែត្រ និងបណ្តោយ២៥ម៉ែត្រ បើធ្វើមិនបានគេនឹងកាត់របបអាហារ ឬត្រូវយកទៅសម្លាប់។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់យុវជន១០នាក់ដែលមានខ្ញុំនៅក្នុងនោះដែរ ឲ្យទៅកាប់ដីនៅទីទួលសំណរ ភូមិថ្មី ឃុំហុក ស្រុក៤២ តំបន់៤ ភូមិភាគពាយព្យ។ នៅទីនោះ គេមិនបានឲ្យយើងហូបគ្រប់គ្រាន់ទេ គេយកអង្ករបីកំប៉ុងមកដាំបបរមួយខ្ទះត្នោតសម្រាប់យើងទាំងអស់គ្នាហូប ពេលខ្លះគេឲ្យយើងហូបដើមចេក កន្ទក់ និងពេលខ្លះទៀតគឺយើងត្រូវដាច់ពោះតែម្តង។ ក្រោយមកទៀត ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅជីកប្រឡាយលើកទំនប់ធ្វើផ្លូវពីទួលអំពិលមកទួលព្រំ ក្នុងស្រុកម៉ោងឫស្សី ដោយឲ្យហូបបបរវាល់វែក។ ក្នុងខែកក្កដា ឆ្នាំ១៩៧៨ មេកងបានប្រកាសថា *"អង្គការនឹងបើកឲ្យមានគ្រួសារ ហើយចំពោះយុវជន និងយុវនារីណាមិនត្រូវបានរៀបគ្រួសារនោះ គឺត្រូវផ្លាស់ទៅធ្វើការនៅភ្នំត្រជាក់ចិត្ត"*។ ដោយសារឮដូចនេះ ឪពុកម្តាយខ្ញុំបាននិយាយស្នើទៅម្តាយមិត្តនារី សឿង ចាន់ថន ដើម្បីឲ្យខ្ញុំបានរៀបការនឹងនាង។ នៅថ្ងៃទី២០ ខែសីហា ការរៀបការត្រូវបានធ្វើឡើងនៅផ្ទះរបស់មេភូមិ ពេលនោះមាន៦គូរដែលត្រូវរៀបការ។ អង្គការបានរៀបចំឲ្យគូទាំងនោះអង្គុយទល់មុខគ្នា ហើយមេភូមិបានធ្វើការណែនាំឲ្យចេះស្រលាញ់គ្នា និងត្រូវគោរពតាមការចាត់តាំងរបស់អង្គការ បន្ទាប់មកគេក៏ឲ្យគូរនីមួយៗឡើងប្តេជ្ញាចិត្ត។ ពេលប្តេជ្ញាចប់ គេឲ្យគូរនីមួយៗត្រឡប់ទៅផ្ទះរៀងៗខ្លួន។ នៅយប់នោះ ខ្ញុំនិងប្រពន្ធមិនបានប្រើជីវិតជាប្តីប្រពន្ធទេ ព្រោះយើងមិនដែលស្គាល់គ្នាពីមុនមក ហើយនូវមានអារម្មណ៍ខ្លាចគ្នា។ នៅយប់ទីពីរ ប្រពន្ធខ្ញុំបានរៀបចំអីវ៉ាន់ប្រុងរត់ទៅនៅជាមួយនឹងបងប្អូនរបស់នាង ព្រោះតែគាត់ខ្លាចខ្ញុំ ប៉ុន្តែខ្ញុំបានពន្យល់ប្រពន្ធថា *"បើសិនមិត្តនារីរត់ទៅ អង្គការដឹង គេនឹងយកយើងទាំងពីរទៅសំលាប់ចោលជាមិនខាន"*។ ក្រោយពីបានស្តាប់ការពន្យល់បែបនេះ ទើបប្រពន្ធខ្ញុំបង្ខំចិត្តរស់នៅជាមួយខ្ញុំបន្តទៀត។ ជិត១ខែ ទើបពួកយើងរស់នៅដោយប្រើជីវិតជាប្តីប្រពន្ធ។ ក្រោយមកទៀត ខ្មែរក្រហមបានឲ្យខ្ញុំទៅនេសាទតាមតំបន់ដែលគេចាត់តាំង រីឯប្រពន្ធឲ្យទៅលើកភ្លឺស្រែនិងច្រូតស្រូវនៅទួលគោកពោនជិតថ្នល់រទេះភ្លើង។ ខ្ញុំនិងប្រពន្ធមិនបានរស់នៅជុំគ្នាទេ។ នៅពេលចង់ត្រឡប់មកផ្ទះនោះ គឺត្រូវសុំការអនុញ្ញាតពីខ្មែរក្រហមជាមុនសិន។ តាមពិត មូលហេតុដែលខ្ញុំសម្រេចចិត្តរៀបការ ក៏ព្រោះតែចង់គេចពីការបញ្ជូនឲ្យទៅធ្វើការនៅតំបន់ឆ្ងាយ បើនិយាយពីការស្រលាញ់នោះគឺមិនមានទេ។

# MR. IM BUN CHHOEUN

*Mr. Im Bun Chhoeun was born in 1955 at Sangke district, Battambang province. He is a Civil Party in Case 002 of the Extraordinary Chambers in the Courts of Cambodia (ECCC).*

On 19 April 1975, the Khmer Rouge transferred my family and the people of Battambang city to live in the jungle area. There, we all had to find wood and thatch to make shelter for ourselves. The Khmer Rouge divided people into three groups – the old people group for farming, the youth group for building a dam and digging a canal, and the children's group. I was assigned to work in the youth group. The Khmer Rouge forced us to work hard according to their plan – one group consisted of thirty people had to build a dam and dig a canal (sized 4 meters across, 2 meters in height and 25 meters in length). They threatened that if the work was not completed, our food portions would be reduced or we would be sent for execution.

In 1976, the Khmer Rouge assigned ten people from the youth group to hoe land at Samor Highland in Thmey village, Hok commune, District 42, Region 4, Northwest Zone. I was one of them. Over there they did not give us enough food to eat. They brought three cans of husked rice to make a big pan of porridge for all of us to eat, and sometimes they made us eat the base of a banana tree. Sometimes we had nothing to eat. The Khmer Rouge later sent me to dig land to build a road from Tuol Ampil to Tuol Prum located in Maung Russey district, and they offered me a ladle of watery porridge to eat.

In July 1978, the unit chief announced, *"Angkar will allow people to make a family and any youth and female youth who do not get married will be sent to work in Tracheak Chitt Mountain"*. Hearing this, my parents went to propose to the mother of a female comrade, Soeung Chanthan, for me to marry her. On 20 August 1978, our wedding was held at the village chief's house and there were six couples who had been arranged to marry at the same time. Angkar arranged each pair to be seated face to face. The village chief advised us to love each other and to respect Angkar's orders. Each pair then had to stand up and make a commitment. When the commitment was finished, they ordered each newlywed couple to go home individually. On that night, my wife and I did not live together because we had never known each other before and felt scared of each other. On the second night, my wife prepared her belongings in order to run away to live with her relative because she was afraid of me. I explained to her, "if a female comrade runs and Angkar finds out, we will both be brought for execution". She decided to stay with me. For nearly one month, we lived together as husband and wife. After that, the Khmer Rouge forced me to go fishing depending on their assignments. My wife was sent to build the rice field dike and harvest rice at Kork Paun Highland near the railway. My wife and I did not live together anymore and whenever I wanted to go back home, I had to ask for permission from the Khmer Rouge in advance. Actually, the only reason I agreed to marry was to attempt to escape from being sent to work in a distant area, and if talking about love, I did not have any at the time.

# លោកស្រី ឡាយ គឹមឈាន



*លោកស្រី ឡាយ គឹមឈាន កើតក្នុងឆ្នាំ១៩៥៨ មានស្រុកកំណើតនៅស្រុកភ្នំក្រវ៉ាញ ខេត្តពោធិសាត់។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងសំណុំរឿង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។*

ក្នុងឆ្នាំ១៩៧៤ ដោយសារមានការប្រយុទ្ធគ្នារវាងទ័ពខ្មែរក្រហម និងទាហានលន់ នល់ ខ្មែរក្រហមបានជម្លៀសប្រជាជន រួមទាំងខ្ញុំ និងបងស្រី ពីស្រុកក្រវ៉ាញទៅទីរួមខេត្តពោធិសាត់។ ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសយើងពីទីរួមខេត្តពោធិសាត់ទៅស្រុកបាកាន។ នៅទីនោះ គេបានបង្ខំឲ្យខ្ញុំជីកប្រឡាយ រែកទឹក លើកប្រព័ន្ធភ្លឺស្រែ និងធ្វើស្រែប្រាំ ជាមួយអាហារហូបចុកមិនគ្រប់គ្រាន់ (មួយកំប៉ុងសម្រាប់មនុស្ស២០នាក់)។ លុះក្រោយមកទៀត ខ្មែរក្រហមបានបន្តជម្លៀសខ្ញុំនិងបងស្រីទៅស្វាយដូនកែវ។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំបានលួចរត់ពីស្វាយដូនកែវទៅនៅភូមិក្រូចសើច។ រស់នៅទីនោះបានប្រហែល ៤ខែ ខ្មែរក្រហមបានរៀបចំឲ្យខ្ញុំឡើងប្តេជ្ញាចិត្តយកគ្រួសារ ខ្ញុំបានប្រកែកថាខ្លួននៅក្មេងទើបតែមានអាយុ១៧ឆ្នាំ ហើយមិនទាន់យល់ថាអ្វីជាការរៀបការឲ្យមានប្តីប្រពន្ធអីនោះទេ។ ដោយសារតែការប្រកែកនេះ មេកងបាននិយាយគំរាមថា *"ប្រយ័ត្នអង្គការចែកដីឲ្យដើរ"*។ ប្រហែលជាកន្លះខែក្រោយមក មេកងបានមកនិយាយជាមួយខ្ញុំម្តងទៀតពីរឿងយកគ្រួសារ តែខ្ញុំនៅតែបដិសេធដដែល ហើយខ្ញុំក៏បានទទួលការគំរាមដូចលើកមុនដែរ។ លុះក្រោយមក គេបានមកសួរទៀត ខ្ញុំបានធ្វើការ ប្រកែកដូចលើកមុនៗអញ្ចឹង តែគ្មានសំណាងអាចគេចរួចទៀតទេ ព្រោះថាអ្នកដែលរៀបចំឲ្យមានពិធីរៀបការពេលនេះគឺជាគណៈឃុំ មិនមែនជាមេកងកាលពីលើកមុននោះទេ។ ការរៀបការនេះ គឺធ្វើឡើងមានចំនួន៧គូ ហើយកន្លែងរៀបចំពិធីគឺនៅមន្ទីរភូមិបឹងខ្នារ។ ពិធីនេះ គឺមិនមានការចូលរួមពីឪពុកម្តាយ ញាតិមិត្តបងប្អូនអ្វីនោះទេ គឺគ្រាន់តែនាំគ្នាឡើងប្តេជ្ញានៅចំពោះមុខអង្គការថា *"ប្តេជ្ញាចិត្តស្រលាញ់គ្នា ខិតខំធ្វើការបំរើអង្គការ និងបង្កើតកូនចៅឲ្យអង្គការ"*។ បុរសដែលជាគូនឹងខ្ញុំ គឺមានអាយុ១៩ឆ្នាំ។ ក្នុងចំណោម៧គូនោះ គឺមាន៥គូដែលមានអាយុ ក្មេងៗ។ នៅវេលាម៉ោង៧យប់ ពិធីរៀបការបានចាប់ផ្តើម ក្រោយពីការឡើងប្តេជ្ញារួច គេបានរៀបចំឲ្យគូនីមួយៗអង្គុយទល់មុខគ្នាដើម្បីហូបបាយជុំគ្នា។ បន្ទាប់មកគេបានឲ្យពួកយើងទៅស្នាក់នៅផ្ទះដែលគេបានរៀបចំទុកឲ្យ គឺផ្ទះមួយខ្នងនៅចំនួនពីរគូ ហើយផ្ទះនោះគ្មានភ្លើងបំភ្លឺទេ។ នៅយប់នោះ ក្រោយពេលចូលទៅដល់ក្នុងផ្ទះដែលគេរៀបចំឲ្យ ខ្ញុំបានលួចរត់ចេញពីបន្ទប់ ប៉ុន្តែត្រូវពួកឈ្លបដែលនៅយាមក្រោមផ្ទះនោះចាប់មកវិញ ហើយគេបានគំរាមថា *"បើមិនធ្វើតាមបក្សទេ ប្រយ័ត្នអង្គការចែកដីឲ្យដើរ"*។ ទោះបីជាមានការគំរាមក៏ដោយ ក៏ខ្ញុំនូវតែមិនព្រមរួមរស់ជាមួយប្តីខ្ញុំដែរ។ អង្គការបានដឹងពីរឿងនេះ ព្រោះគេតាមស៊ើបយើងរហូត ក្រោយមកគេបានយកខ្ញុំទៅកសាងចំនួនបីដង ដោយបានណែនាំ និងគំរាមថា *"បើសិនជានៅតែមិនព្រម គេនឹងយកទៅសម្លាប់ចោល"*។ បន្ទាប់ពីទទួលបានការណែនាំច្រើនដងមក ខ្ញុំបានសុខចិត្តរួមរស់ជាមួយប្តីដោយសារតែខ្លាចគេយកទៅសម្លាប់។ ខ្ញុំនិងប្តីបានរស់នៅជាមួយគ្នាបានប្រហែល២០ថ្ងៃប៉ុណ្ណោះ អង្គការបានបំបែកពួកយើងឲ្យទៅធ្វើការតាមកន្លែងរៀងខ្លួន។ របបខ្មែរក្រហមបានធ្វើឲ្យខ្ញុំបាត់បង់បងប្អូនប្រុសពីរនាក់ និងស្រីពីរនាក់ (ត្រូវគេសម្លាប់ និងស្លាប់ដោយសារការបង្អត់អាហារ) ចំណែករូបខ្ញុំក៏ត្រូវបានគេបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ ហើយរយៈពេល៧ ឬ៨ថ្ងៃទើបខ្មែរក្រហមអនុញ្ញាតឲ្យងូតទឹកម្តង។

# MRS. LAY KIM CHHEAN

*Mrs. Lay Kim Chhean was born in 1958 at Kravanh district, Pursat province. She is a Civil Party in the second case of the Extraordinary Chambers in the Courts of Cambodia (ECCC).*

In 1974, because there were fighting between the Khmer Rouge soldiers and Lon Nol Troops, the Khmer Rouge expelled many people, including my younger sister and me, from Kravanh district to Pursat Provincial capital. In 1975, the Khmer Rouge transferred us again from Pursat to live in Bakarn district. While there, they forced me to dig canal, carry water, build up the rice field dikes, and grow dry season rice crop with inadequate food to eat (we were offered on can of husked rice for 20 people). Later on, the Khmer Rouge moved my older sister and me to live in Svay Daun Keo area.

At the end of 1977, I escaped from Svay Daun Keo area to live in Kroch Seuch village. Staying in here for about 4 months, the Khmer Rouge arranged for me to make commitment for marriage, but I argued, *"I am still young, only 17 years old, and I do not understand what marriage is"*. Because I refused, the Khmer Rouge threatened, *"be careful, Angkar will measure land for you to walk"*. About two weeks later, the unit chief came and talked with me again about the wedding, but I still refused, and I was threatened again as the previous time. On the third time the Khmer Rouge came to ask me about the wedding and I refused as before, but unfortunately I could not escape this time because the person who set up the wedding at this time was from the commune committee, not the unit chief. There were seven pairs of who were to be married at that time. The wedding ceremony was held at Boeung Khnar village's department. Parents and relatives were not invited or allowed to join in the wedding ceremony. The wedding was celebrated with each couple standing up and making a commitment before Angkar to *"commit to love each other, make effort to serve Angkar and produce children for Angkar"*. The man I married was 19 years old. Among of those seven pairs, five pairs were still young in age. At seven at night, the wedding ceremony started, and after making the commitments, the Khmer Rouge prepared each newlywed couples to sit face to face on the table to have a communal meal. After the ceremony ended, the newlywed couples were ordered to stay in a house, one house for two couples with no lights inside, which the Khmer Rouge had already arranged. On that night, I ran from the room after going inside the house, but I was arrested and taken back by the Khmer Rouge militiamen who guarded the house. I was threatened that *"if you do not follow Angkar, be careful of Angkar measuring land to walk"*. Although I was threatened, I still refused to live with my husband. Angkar knew about this, because we were kept track of all the time. I received re-education three times and was threatened that if I still rejected, I would be taken for execution. After being re-educated many times, I agreed to live with my husband due to being afraid of being killed. My husband and I lived together for only twenty days, and then Angkar separated us to work differently. The Khmer Rouge regime caused me to lose two brothers and two sisters who were killed and who starved to death, whereas I was forced to work hard and during a period of seven or eight days the Khmer Rouge only allowed me to bathe once.

# លោកស្រី ស៊ូ សុទ្ធារី



*លោកស្រី ស៊ូ សុទ្ធារី កើតក្នុងឆ្នាំ ១៩៤០ មានស្រុកកំណើតនៅស្រុកទ្រាំង ខេត្តតាកែវ។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប និងជាអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំកំពុងរស់នៅផ្ទះជួលជាមួយមិត្តភក្តិភេទទីបីច្រើននាក់ស្ថិតក្នុងស្តាតអូឡាំពិក។ ខណៈនោះ ទាហានខ្មែរក្រហមបានចូលមកដល់កន្លែងខ្ញុំស្នាក់នៅ និងបានបាញ់រះដល់បន្ទប់ខ្ញុំរស់នៅ ធ្វើឲ្យមិត្តភក្តិខ្ញុំបួននាក់ស្លាប់។ ខ្ញុំភ័យខ្លាំងណាស់ពេលនោះ។ បន្ទាប់មក ពួកខ្មែរក្រហមបានភ្ជង់កាំភ្លើងបង្ខំឲ្យយើងចាកចេញ ដោយមិនទុកពេលឲ្យយើងរៀបចំអីវ៉ាន់ស្រួលបួលយកតាមខ្លួននោះទេ។ ខ្ញុំ និងមិត្តភក្តិម្នាក់បានធ្វើដំណើរជាមួយហ្វូងមនុស្សនៅតាមបណ្តោយផ្លូវព្រះមុនីវង្សរហូតដល់ក្បាលស្ពានព្រះមុនីវង្ស។ ខ្មែរក្រហមបានបាញ់គំរាមមិនឲ្យប្រជាជានបត់ទៅខាងផ្លូវជាតិលេខ២ទេ ពួកវាបានឲ្យយើងឆ្លងស្ពានព្រះមុនីវង្សសំដៅទៅផ្លូវជាតិលេខ១។

យើងបានធ្វើដំណើរតាមផ្លូវជាតិនេះរហូតដល់វត្តចំប៉ា ស្រុកគគីរ។ ដោយសារនៅទីនោះ មិនមានស្បៀងអាហារគ្រប់គ្រាន់ទេ ខ្ញុំ និងមិត្តភក្តិបានត្រឡប់ក្រោយទៅច្បារអំពៅវិញ ដើម្បីរកអង្ករ។ មកដល់ត្រឹមវត្តនិរោធ ពួកខ្មែរក្រហមមួយក្រុមតូចបានចេញមកឃាត់ដំណើរយើង ហើយពួកវាបាននាំមិត្តភក្តិខ្ញុំទៅ មួយសន្ទុះក្រោយមក ខ្ញុំបានឃើញមិត្តភក្តិខ្ញុំមានឈាមពេញខ្លួន ខ្ញុំមានអារម្មណ៍រន្ធត់ចិត្តយ៉ាងខ្លាំងព្រោះវាត្រូវគេរំលោភដោយប្រើអំពើហិង្សា។ ដោយសាររន្ធត់ខ្លាំងពេក ខ្ញុំក៏បានគេចចេញពីទីនោះតែឯងមកវត្តចំប៉ាវិញ ហើយក៏បានជួបមិត្តភក្តិផ្សេងទៀតនៅទីនោះ។ ដល់ស្អែកឡើង ពួកខ្មែរក្រហមបានជម្លៀសយើងទៅខាងល្វាឯម បន្ទាប់មកអរិយក្សត្រ និងស្វាយជ្រំ។ មកនៅស្វាយជ្រំបានបីយប់ ខ្ញុំបានរត់គេចមកល្វាឯមវិញ រួចក៏បានបន្តដំណើរតាមទូកទៅចំពុះក្អែក។ បន្ទាប់មក ខ្ញុំសម្រេចចិត្តហែលឆ្លងទឹកទន្លេបាសាក់មកវត្តព្រែកសំរោង ក្រុងតាខ្មៅ។ តែអកុសល មិត្តភក្តិខ្ញុំបានលង់ក្នុងទន្លេនោះស្លាប់។ ខ្ញុំបានបន្តដំណើរតែម្នាក់ឯងមកវត្តព្រែកហូរ។

នៅទីនេះ ខ្ញុំបានឃើញសាកសពជាច្រើនរួមទាំងព្រះសង្ឃផងដែរ ហើយក៏ឃើញប្រជាជនខ្លះមានជំងឺ ខ្លះមានរបួសស្រែកទ្រហោយំ។ ខ្ញុំតក់ស្លុតខ្លាំងណាស់ពេលឃើញសភាពបែបនេះ។ បន្ទាប់មក គេបានជម្លៀសយើងបន្តទៀតរហូតដល់ស្រុកកំណើតនៅភូមិកន្ទួតធំ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ។ មកដល់ទីនេះ ខ្មែរក្រហមបានបង្ខំឲ្យអ្នកចំណូលថ្មី (អ្នក១៧ មេសា) រួមទាំងខ្ញុំទៅនៅសហករណ៍ថ្មីនៅឯវាលពោធិ៍ពាច។ នៅទីនោះ ខ្ញុំបានរស់នៅដោយលាក់អត្តសញ្ញាណភេទខ្លួនឯង បង្ខំចិត្តកាត់សក់ដោយខ្លួនឯង ស្លៀកពាក់ជាបុរសទៅធ្វើការនិងរស់នៅជាមួយប្រុសៗ។ ថ្ងៃមួយ ខ្ញុំមុតជើងនឹងផ្លែចប ហើយត្រូវគេបញ្ជូនទៅពេទ្យសង្គមកិច្ចនៅទួលព្រៃព្រះ។ បីខែក្រោយមករបួសបានជាសះ ខ្ញុំបានសុំគេត្រឡប់មកកងវិញ។ ពេលមកដល់កង នៅយប់នោះ ខ្ញុំត្រូវកងឈ្លបរំលោភ។ បន្ទាប់មក ប្រធានភូមិបានបញ្ជូនខ្ញុំទៅចិញ្ចឹមជ្រូកនៅភូមិទ្រាំងស្បែក ហូបបបរវាល់វែក។ ព្រោះតែការអត់ឃ្លានខ្លាំង ខ្ញុំក៏បង្ខំចិត្តលក់ខ្លួនដើម្បីដូរយកបាយហូប។ មេកងបានដឹងរឿងនេះ ហើយយកខ្ញុំទៅដាក់គុកទ្រាំងឆេះ។ មិនយូរប៉ុន្មាន ទ័ពវៀតណាមបានវាយលុកចូលតំបន់នេះ ទើបខ្មែរក្រហមជម្លៀសអ្នកទោសទាំងអស់មកនៅឃុំដូង ខេត្តកណ្តាលវិញ។ នៅទីនេះ ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំរៀបការ។ ក្រោយមកទៀត ខ្ញុំបានស្រលាញ់គ្នាជាមួយនឹងមិត្តសនដែលជាកងឈ្លបមានចិត្តសប្បុរស។ ខ្មែរក្រហមបានដឹងរឿងនេះ ហើយបានយកយើងទាំងពីរទៅដាក់គុកភ្នំតាពែក។ នៅទីនោះ គេបង្ខំឲ្យខ្ញុំវាយថ្មក្នុង១ថ្ងៃឲ្យបានមួយម៉ែត្រគូប។ ថ្ងៃមួយ កងឈ្លបបួនដប់នាក់បានចាប់ខ្ញុំរំលោភរហូតដល់សន្លប់ មិត្តសនបានជួយគ្រាខ្ញុំមកខ្ទមវិញ។ ក្រោយមក យើងបាននាំគ្នារត់ចេញពីទីនេះ ពេលនោះខ្មែរក្រហមបានដេញតាមបាញ់យើងពីក្រោយ រហូតបាញ់ត្រូវមិត្តសនស្លាប់។ ខ្ញុំបានរត់តែឯងរហូតដល់ប្រទេសវៀតណាម។

# MS. SOU SOTHEAVY

*Ms. Sou Sotheavy, was born in 1940 at Traing district, Takeo province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 27 May 2013.*

On 17 April 1975, I was living with my transgender friends in a rental house at Olympic Stadium. On that day, the Khmer Rouge soldiers came to my house and shot at my room, killing four of my friends. I was very scared at that time. The Khmer Rouge pointed their rifles at us and forced us to move from our house, without giving us time to prepare our belongings. My friend and I walked with the crowd of people along Monivong Street to the edge of Monivong Bridge. The Khmer Rouge fired shots to threaten people not to move down National Road No.2, instead they forced us to go across Monivong Bridge to National Road No.1.

We were forced to travel along this national road until we reached the Champa pagoda in Korki district. There was insufficient food supply there, so my friend and I went back to Chbar Ampov area, in order to find food. When we arrived at the Niroth pagoda, a small group of Khmer Rouge soldiers came out to stop our journey. They took my friend away and a couple of minutes later I saw my friend come back with blood all over the body, because had been raped violently. I went back alone to Champar pagoda and met another friend over there. The Khmer Rouge forcibly transferred us again to Leav Em area, then to Ariykhsat area and Svay Chrum area. Staying in Svay Chrum area for three nights, I escaped back to Leav Em and then kept going by boat to Champus Kaek side. I later decided to swim across Basac River to Prek Samrong pagoda in Takhmao city. Unfortunately, my friend drowned in that river.

I kept traveling alone to Prek Ho pagoda. Over there, I saw many dead bodies including the bodies of Buddhist monks. I also saw some persons who were ill and injured crying loudly. Seeing this situation made me feel very scared. The Khmer Rouge kept transferring us until we reached my native village in Kantuot Thom village, Kralach commune, Traing district, Takeo province. Over there, the Khmer Rouge forced the newcomer people (17 April people), including me, to live in the new cooperative situated in Veal Pou Peach field. I hid my gender identity, cut my hair, dressed myself in the clothes of a man, and went to live and work with men. One day, my leg was hurt with hoe blade and I was sent to the Affair Department's hospital at Tuol Prey Preah Highland. Three months later when my injury had recovered, I asked to go back to the unit. When I arrived in the unit, I was raped by the Khmer Rouge militiaman.

I was sent by the village chief to feed the pigs at Traing Sbek village, where the food portion was only a ladle of watery porridge. Because I was starving, I was forced to sell myself in exchange for some food. The unit chief knew about this and put me in prison in the Traing Chheh area. A short time later, the Vietnam troops invaded this area, so the Khmer Rouge transferred all the prisoners to live in Dong commune, Kandal province. In Dong commune, the Khmer Rouge forced me to marry. Later, I made love with comrade Sorn, who was a very kind Khmer Rouge militiaman. The Khmer Rouge people knew about this and put me in the prison at Ta Pek Mountain. In prison, they forced me to hit rock, one cubic meter per day. One day, I was raped by around four to ten Khmer Rouge militiamen until I fainted and comrade Sorn helped bring me back to the cottage. A little while later, comrade Sorn and I fled from this place, and the Khmer Rouge chased after us, shooting at us until they shot comrade Sorn dead. I escaped alone to Vietnam.

ផ្នែក ៧
Chapter 7

# ការបង្អត់អាហារ

Starvation


Painted by Mr. Meoun Chan Sokha
Copyright © 2014 by CHRAC

# លោកស្រី ទឹង សុខា



*លោកស្រី ទឹង សុខា កើតក្នុងឆ្នាំ១៩៤៧ មានស្រុកកំណើតនៅស្រុកស្រីសន្ធរ  ខេត្តកំពង់ចាម។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋវេណីមួយរូបនៅក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២។*

នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនទាន់មានអ្នកណាមកប្រាប់ឲ្យចេញពីផ្ទះទេ ហើយនៅមានការបាញ់ផ្លោងចូលក្រុងភ្នំពេញខ្លះៗទៀត។ ដោយសារភ័យរន្ធត់ខ្លាំងពេក សមាជិកគ្រួសារខ្ញុំក៏បានបំបែកគ្នាខណៈនោះម្តាយក្មេកខ្ញុំបានរត់ទៅផ្ទះបងប្អូនគាត់នៅបឹងកេងកង មានកូនពីរទៅជាមួយផង។ បងស្រីជីដូនមួយឈ្មោះសយ និងប្តីគាត់ដែលរត់មកពីត្រាំខ្នារ បានប្រមូលអីវ៉ាន់នាំកូនរត់ទៅគីឡូលេខ៤ (ទឹកល្អក់) វិញ។ មួយសន្ទុះក្រោមមក គាត់ទាំងពីរនាក់និងកូនបានវិលមកផ្ទះខ្ញុំវិញ ដោយសារបងស្រីនោះត្រូវអំបែងគ្រាប់ផ្លោងធ្វើឲ្យរបួសជើងយ៉ាងដំណំ។

ពេលថ្ងៃជិតត្រង់ ស្ងាត់គ្រាប់ផ្លោង មានខ្មែរក្រហមបីបួននាក់បានមកនិយាយថា *"ញោមចេញតែបីថ្ងៃទេ ព្រោះគេសំអាតខ្មាំង"*។ នៅពេលរសៀលនោះ មានហ្វូងមនុស្សណែនណាន់ផ្លូវដើរកាត់តាមមុខផ្ទះខ្ញុំសំដៅទៅទិសខាងត្បូង។ ប្រហែលម៉ោង៥ល្ងាច ដោយគ្មានជម្រើស ក្រុមគ្រួសារខ្ញុំទាំងអស់១៤នាក់ ត្រូវបង្ខំចិត្តចាកចេញពីផ្ទះមួយរយៈទៅតាមផ្លូវព្រះមុនីវង្សរហូតដល់សាលាច្បាប់។ យើងបានស្នាក់នៅទីនោះមួយយប់។

នៅព្រឹកថ្ងៃទី១៨ ខែមេសា ក្រុមគ្រួសារខ្ញុំបានឆ្លងស្ពានមុនីវង្សហើយមកសម្រាកនៅគល់ស្ពានត្រើយខាងកើតមួយយប់ទៀត។ នៅទីនេះខ្ញុំបានឃើញមនុស្សស្លាប់បីបួននាក់នៅជិតមាត់ទន្លេ។

ដល់ព្រឹកថ្ងៃទី១៩ ខែមេសា ខ្ញុំបានលាឪពុកក្មេកសំដៅទៅខេត្តកំពង់ចាម។ ពេលនោះ ទាំងអស់គ្នាមានអារម្មណ៍ក្តុកក្តួល យំព្រោះមិនចង់បែកគ្នា។ បន្តិចក្រោយមក ឪពុកក្មេកខ្ញុំបានឲ្យប្អូនស្រីពីរនាក់រត់តាមហៅខ្ញុំនិងស្វាមីព្រមទាំងចៅទាំងពីរនាក់ឲ្យត្រឡប់មកវិញ ពេលជួបគ្នា ទឹកភ្នែកយើងកាន់តែហូរទប់លេងបាន។ តែដោយបងប្រុសជីដូនមួយបានហៅឲ្យទៅនៅកំពង់ស្ពឺវិញ យើងក៏សម្រេចចិត្តទៅនៅតាមគាត់ ហើយយើងក៏រកផ្លូវនិងវិធីចុះទៅខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ ពីរថ្ងៃក្រោយមក ខ្ញុំបាននាំបងប្អូនឆ្លងទូកទៅត្រើយខាងតាខ្មៅ ដើម្បីងាយស្រួលក្នុងការធ្វើដំណើរទៅមុខ។

នៅលើកំណាត់ផ្លូវពីតាខ្មៅទៅភូមិសិត្បូ ខ្ញុំបានឃើញសាកសពនាយទាហានម្នាក់មិនមានធំក្លិនស្អុយទេ ខោកាគីខ្លីត្រឹមជង្គង់ អត់មានអាវ អត់មានក្បាលនៅទទឹងផ្លូវស្តុក នាំឲ្យស្លុតស្មារតី ខ្ញុំក៏បានអោបកូនរត់វាងទាំងធ្មេចភ្នែក។ អស់រយៈពេល១១ថ្ងៃ ទើបក្រុមគ្រួសារខ្ញុំបានទៅដល់ភូមិថ្នល់ដាច់ ស្រុកបាទី ខេត្តតាកែវ។ នៅទីនោះ ពួកខ្មែរក្រហមបានដកយកវិទ្យុទំនើប និងម៉ូតូរបស់ខ្ញុំទាំងបង្ខំ ពួកវាប្រាប់ថាត្រូវការប្រើប្រាស់។ បន្ទាប់មកក្រុមគ្រួសារខ្ញុំត្រូវបានគេបំបែកឲ្យទៅធ្វើការនៅកន្លែងផ្សេងៗគ្នា។

ប្រហែលជានៅចុងខែកញ្ញា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំជាលើកទីពីរយកទៅចោលក្នុងព្រៃលិចទឹក ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង គ្មានជម្រក គ្មានអាហារ និងគ្មានថ្នាំសង្កូវ។ ការជម្លៀសលើកនេះគឺពិតជាទុក្ខលំបាក និងការឈឺចាប់ហួសប្រមាណ។ ទាំងអស់គ្នារស់នៅដូចជាសត្វព្រៃ ជួនកាលញុំាសត្វម្រើមព្រះ ញុំាជីងចក់ ដើមប្រោះស្វា ឯគល់ត្រកួន និងឫសកំប្លោកស្ទើររកពុំបាន។ល។ សូម្បីស្លឹកថ្នឹងដែលមានរសជាតិជូ បែរជាមានរសជាតិផ្អែម។ យើងឃ្លានស្ទើរស្លាប់ ភ្នែកប្រែពណ៌ល្អក់ មានសភាពដូចសាកព សម្លេងខ្សោយលឺសូរខ្សាវៗ។ ក្នុងឆ្នាំ១៩៧៦ ឪពុកក្មេកខ្ញុំស្លាប់ព្រោះដាច់ពោះ។ កូនស្រីខ្ញុំស្លាប់ដោយខ្វះអាហារ និងគ្មានថ្នាំព្យាបាល។ ប្អូនស្រីម្នាក់បាត់ខ្លួន និងម្នាក់ទៀតឈឺស្លាប់ព្រោះដាច់ពោះឯពេទ្យស្រុកម៉ោងឫស្សី។ ចំណែកស្វាមីខ្ញុំបានធ្វើអត្តឃាត ព្រោះតែភ័យខ្លាចនឹងការសម្លាប់ឆៅៗរបស់ពួកខ្មែរក្រហមដែលធ្វើឲ្យគាត់អស់សង្ឃឹមទីបំផុត។ សុរបសេចក្តីមក របបខ្មែរក្រហមបានធ្វើឲ្យខ្ញុំបាត់បង កូនស្រីម្នាក់ ឪពុកម្តាយ បងប្អូនសរុបចំនួន ៨នាក់។ ស្លាប់បងប្អូនជីដូនមួយសរុបចំនួន ២៥នាក់ (ផុតពូជ)។ ជីទូតមួយសរុប ចំនួន ៨នាក់។ មិត្តភក្តិជិតស្និទ្ធិសរុបចំនួន ៨នាក់។ ព្រមទាំងទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ (ផ្ទះ និងមាសចំនួន ៩២៥,១ដំឡឹង)។ ក្រោយរបបខ្មែរក្រហម ខ្ញុំស្ទើរតែអស់សមត្ថភាពក្នុងការបំពេញកិច្ចការ ធ្វើការងារតែដដែលៗ ដោយមិនអាចអភិវឌ្ឍខ្លួនឯងបាន។ ខ្ញុំនៅតែយល់សប្តិអាក្រក់ជាប្រចាំ។

# MRS. TING SOKHA

*Mrs. Ting Sokha was born in Srey Santhor district, Kampong Cham province. She is a Civil Party in Case 002 who testified before the Extraordinary Chambers in the Courts of Cambodia (ECCC) on 4 December 2012.*

On 17 April 1975, there was some explosion in Phnom Penh city but no soldiers had come to tell us to move out of our home. Because there was so much fear, my family members separated. At that time my mother-in-law moved to her relative's home at Boeung Keng Kang site with her two grandchildren. My sister cousin Sory and her husband (who had escaped from Traim Khnar area) packed their belongings and brought their children to Kilometer No.4 (Toek Laak area). But, a bit later, both of them and their children returned to my home because she had been seriously injured on her leg from a blast. At around noon, it was quiet in the city from the explosion. Three or four Khmer Rouge soldiers came to my home and said, *"you have to move for only three days, because we need to clean out the enemy"*. Late in the afternoon, there were crowds of people walking past my home towards the south. At about 5 pm, my family, fourteen members in total, was forced to leave our home and we left through Preah Monivong Street to reach the Law Faculty. We stayed there for the night.

In the morning of 18th April, my family walked across Monivong Bridge and stayed at the east of the edge of the bridge for one night. I saw at least three or four dead bodies near the edge of the river. On the morning of 19th April, I said goodbye to my father-in-law to go to Kampong Cham province. At that time, we all felt very scared and cried because we did not want to separate from each other. My father-in-law made two sisters run after us to call my husband and me back; our tears kept falling when we met each other again. Due to my brother cousin being persuaded to live in Kampong Speu province, we decided to follow him, and we tried to find the way toward Kampong Speu province and Takeo province.

Two days later, I brought my family members to take a boat to Takhmao side, as it would be easier for us to move on. On the road from Takhmao to Sitbo village, I saw the dead body of one soldier. It did not smell and the soldier lay there in khaki short pants and no shirt, without a head. Seeing this shocked and scared me, I tried to move quickly away from the body and tried to pretend that my eyes had not seen it. It took eleven days for my family to arrive in Thnal Dach village, Bati district, Takeo province. When we got there the Khmer Rouge confiscated one modern radio and one motorbike from us, saying that they needed to use them. My family members were separated to do different kinds of work.

At the end of September 1975, the Khmer Rouge transferred my family again to the inundated forest at Koas Kralor district, Battambang province, without shelter, food or medicine. This last transfer was extremely difficult for us and made us suffer beyond measure. We all lived the same, like wild animals. Sometimes we ate millipedes, lizards, wild plants, as the base of water convolvulus and root of water hyacinth were very hard to find. Vine leaves that tasted sour soon became sweet to us. We were so hungry that we were almost dead, while our eyes became bleary and our voices were weak and hoarse.

In 1976, my father-in-law died from starvation. Subsequently, my daughter also died because of starvation and because there was no medicine for treatment. One of my sisters disappeared and another sister died because of illness and starvation at Maung Russey district's hospital. My husband committed suicide because he feared being killed by the Khmer Rouge so much that it made him extremely hopeless.

The Khmer Rouge regime made me lose my daughter, my parents and my siblings. In total, I lost eight family members, twenty-five cousins, eight second cousins, and eight close friends, as well as my entire property (home and gold). After the Khmer Rouge regime ended, I was almost unable to do anything. I still do the same thing over and over; I am unable to develop and improve myself. I still have nightmares about the Khmer Rouge.

# លោកស្រី បៃ សុផានី



*លោកស្រី បៃ សុផានី កើតក្នុងឆ្នាំ១៩៤៥ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង។ លោកស្រីគឺជាដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ មានកាន់កាំភ្លើង ស្លៀកពាក់ឈុតខ្មៅ និងមានទឹកមុខមាំ ពួកគេបានបាញ់កាំភ្លើងឡើងលើបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងជាបន្ទាន់ ដោយពួកគេប្រាប់ថាអាមេរិកាំងនឹងទម្លាក់គ្រាប់បែកក្នុងទីក្រុង ហើយចាកចេញតែបីថ្ងៃទេ។ ខ្ញុំមានការភិតភ័យ និងរន្ធត់ជាខ្លាំង ព្រោះមានស្នូរកាំភ្លើងបាញ់ឡើងលើ និងការប្រកាសតាមមីក្រូឲ្យចេញជាបន្ទាន់។ ឃើញខ្មែរក្រហមបានខិតមកជិតដល់ផ្ទះរបស់ខ្លួនដូច្នេះ ខ្ញុំរិតតែភ័យខ្លាចនិងនឹកក្នុងចិត្តថាប្រសិនបើទាហានខ្មែរក្រហមបានចូលក្នុងផ្ទះខ្ញុំ ហើយបានឃើញរូបថតប្ដីខ្ញុំស្លៀកពាក់យោធានោះ ខ្ញុំនឹងត្រូវខ្មែរក្រហមសម្លាប់ចោលជាមិនខាន។ ហេតុដូច្នេះ ខ្ញុំនិងកូនតូចៗចំនួនបីនាក់ បានចាកចេញជាមួយនឹងហ្វូងមនុស្សជាច្រើនតាមផ្លូវចំការមនរហូតដល់ច្បារអំពៅ។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំបានឃើញសាកសពជាច្រើននៅលើផ្លូវដែលអ្នកទាំងនោះជាទាហានលន់ នល់ មនុស្សចាស់ជរា កូនក្មេង និងស្ត្រីមានផ្ទៃពោះ។

យើងបានចំណាយពេលជាច្រើនថ្ងៃ ដើម្បីចាកចេញពីទីក្រុងភ្នំពេញ។ ខ្ញុំនិងកូនតូចទាំងបីនាក់បានធ្វើដំណើររហូតដល់ត្រើយស្លា និងបានស្នាក់នៅក្រោមផ្ទះអ្នកមូលដ្ឋានមួយ។ ពេលទៅដល់ទីនោះ កូនស្រីខ្ញុំបានឈឺ ហើយអ្នកស្រុកបានឲ្យអាហារមកខ្ញុំនិងកូនៗបរិភាគ ប៉ុន្តែក្រោយមកទាហានខ្មែរក្រហមបានប្រាប់អ្នកមូលដ្ឋានឈប់ផ្ដល់អាហារឲ្យយើងព្រមទាំងលែងឲ្យខ្ញុំនិងកូនៗស្នាក់នៅក្បែរផ្ទះអ្នកមូលដ្ឋានទៀតហើយ ព្រោះខ្មែរក្រហមបានចាត់ទុកគ្រួសារខ្ញុំជា *"ប្រជាជនថ្មី ឬប្រជាជន១៧មេសា"*។ ខ្មែរក្រហមបានឲ្យខ្ញុំនិងកូនៗទៅរស់នៅជាយភូមិ និងសង់ជម្រកដោយខ្លួនឯង។ ដោយសារកូនស្រីខ្ញុំឈឺធ្ងន់ ខ្ញុំបានយកចិញ្ចៀនពេជ្រដែលជាចំណងដៃអាពាហ៍ពិពាហ៍របស់ខ្ញុំទៅដូរយកអង្ករ២៥កំប៉ុង បន្ទាប់មកបានយកអង្ករមួយចំនួនទៀតទៅដូរយកថ្នាំអាស្ពារីននិងថ្នាំរាគចំនួន១០គ្រាប់ពីអ្នកមូលដ្ឋាន ក្រោយមក ដោយសារអាការៈជំងឺកូនស្រីខ្ញុំកាន់តែធ្ងន់ធ្ងរឡើងគឺឈឺរាគមួល ក្អួត និងលែងទទួលអាហារបានទៀតហើយនោះ ខ្ញុំបានយកកូនទៅរកពេទ្យយោធាមួយដែលមានចំងាយប្រហែល ៤ ឬ៥គីឡូម៉ែត្រពីភូមិ។

ពេលទៅដល់ពេទ្យនោះ គេបានចាក់ថ្នាំឲ្យកូនខ្ញុំ បន្ទាប់ពីចាក់ថ្នាំរួចមកកូនខ្ញុំបានប្រកាច់ស្លាប់ភ្លាមៗ ខណៈនោះ ខ្ញុំបានយំអោបសាកសពកូន។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសខ្ញុំនិងកូនៗពីកន្លែងមួយទៅកន្លែងមួយ។ នៅថ្ងៃមួយកូនប្រុសខ្ញុំចង់តាមខ្ញុំទៅធ្វើការនៅឯស្រែ ឃើញដូច្នេះ ទាហានខ្មែរក្រហមពីរនាក់បានចាប់ទាញកូនប្រុសខ្ញុំចេញមក បន្ទាប់មកទាហានខ្មែរក្រហមម្នាក់បានយកកាំភ្លើងដាក់ចូលក្នុងមាត់កូនប្រុសខ្ញុំ ដោយបាននិយាយថា *"ជាកូនអាមេរិកាំង មិនមែនជាកូនខ្មែរទេ"* ពួកគេបានប្រាប់ខ្ញុំថានេះជាកាគំរាមកុំឲ្យកូនប្រុសហ្នឹងតាមខ្ញុំទៅធ្វើការទៀត ខណៈនោះ ទាហានខ្មែរក្រហមម្នាក់ទៀតបានយកកាំភ្លើងភ្ជង់ពីក្រោយខ្នងបង្ខំខ្ញុំឲ្យដើរទៅមុខ ខ្ញុំបានអង្វរពួកខ្មែរក្រហមកុំសម្លាប់កូនប្រុសខ្ញុំអី។ ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំនិងកូនៗទៅធ្វើការលត់ដំវាយថ្មនៅភ្នំជីសូរ ហើយកន្លែងនោះហើយដែលកូនប្រុសខ្ញុំបានធ្លាក់ខ្លួនឈឺធ្ងន់ធ្ងររហូតដល់ស្លាប់។ រំលងបាន១ខែ កូនស្រីខ្ញុំម្នាក់ទៀតដែលមានអាយុ៥ឆ្នាំក៏បានឈឺស្លាប់នៅទីនោះផងដែរ។ ខ្ញុំមិនមានសល់អ្វីឡើយក្រោយរបបខ្មែរក្រហម របបនេះបានធ្វើឲ្យកូនខ្ញុំបីនាក់ស្លាប់ (ដោយសារជំងឺគ្មានថ្នាំព្យាបាល ការអត់អាហារ និងការវាយដំ) ឪពុកម្ដាយនិងបងប្អូនទាំងគ្រួសារត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់ ចំណែកឯសមាជិកគ្រួសារខាងប្ដីខ្ញុំក៏បានត្រូវគេសម្លាប់ចោលអស់ផងដែរ។

# MRS. BAY SOPHANY

*Mrs. Bay Sophany was born in 1945 at Kampong Chhnang province. She is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 4th June 2013. Her story details her traumatic experience under the Khmer Rouge regime.*

On 17 April 1975, the Khmer Rouge soldiers arrived in Phnom Penh city. They held rifles and were dressed in black uniforms with the strength of character in their faces. Later on, they started shooting into the air to force people to urgently leave Phnom Penh city, because the Khmer Rouge said *"the Americans will bomb the city, so you all need to leave only for three days"*. I was very scared and shocked when I heard the sound of gunfire and the announcement to move quickly. When I saw the Khmer Rouge came close to my house, I became more frightened and thought *"if the Khmer Rouge come into my house and see a photo of my husband dressed in a military uniform, the Khmer Rouge will kill me"*. Therefore, my three small children and I left from home and traveled with the herd of the people on Chamkarmorn Street toward Chbar Ampove area. While traveling, I saw many corpses of Lon Nol soldiers, the elderly, children and pregnant women laid down on the road. We spent many days leaving Phnom Penh city.

My three small children and I moved to Treuy Sla area and stayed in a house of the base people. While there, my daughter became ill and the inhabitants offered food to my children and I to eat. But later the Khmer Rouge soldiers told the base people to stop providing us food. They also did not allow my children and me to stay nearby the house of the base people, because the Khmer Rouge considered my family as *"the new people"* or *"17 April people"*.

The Khmer Rouge sent my children and I to live at the edge of the village and make shelter by myself. Because my daughter got seriously ill, I took my wedding ring to exchange for 25 cans of husked rice and then brought some amount of husked rice to exchange for 10 tablets of Aspirin and diarrhea medicine from the base people to cure her illness. My daughter's illness became more serious – she got dysentery, vomiting and was unable to eat – I brought her to the military hospital, about 4 or 5 kilometers from the village. When I reached the hospital, the Khmer Rouge gave my daughter an injection and after the injection, my daughter started twisting her body and died. At that moment, I cried and hugged my daughter's dead body.

The Khmer Rouge then transferred my other children and I from place to place. One day, my son wanted to follow me to work in the rice fields. Seeing this, two Khmer Rouge soldiers grabbed my son away and then one of the Khmer Rouge soldiers put a gun into my son's mouth and said, *"this child is an American child, not a Cambodian child"*, and they told me that doing this *"just stopped your son following you to the rice field"*. Meanwhile, another Khmer Rouge pointed a gun behind my back to force me to move forward. I begged the Khmer Rouge not to kill my son. Later on, the Khmer Rouge sent my children and I to reeducation by hitting rock at Chiso Mountain, which was a place that caused my children to become seriously ill and lead to their death. One month later, one more of my daughters, only five years old, died as well. I did not have anything after the Khmer Rouge regime. This regime made me lose three children (who died because of illness, starvation and beating), parents and other relatives (who were killed with their entire families), including the relatives of my husband's side who were killed as well.

# លោកស្រី ប៉ូ ឌីណា



*លោកស្រី ប៉ូ ឌីណា មានអាយុ ៦០ឆ្នាំ មានស្រុកកំណើតនៅស្រុកមុខកំពូល ខេត្តកណ្តាល។ លោកស្រី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ និងប្តីកំពុងធ្វើការនៅស្ថានទូតថៃដែលស្ថិតនៅខាងជើងឆៀងខាងកើតមុខវាំង ខណៈនោះខ្មែរក្រហមបានមកដល់ និងសួររកម្ចាស់កន្លែងនេះម្តងហើយម្តងទៀត យើងបានប្រាប់ខ្មែរក្រហមថាយើងមិនមែនម្ចាស់ផ្ទះទេ តែខ្មែរក្រហមមិនជឿទេ។ ពួកវាបានចូលបោកសម្ភារៈនៅក្នុងផ្ទះខ្ទេចខ្ទីអស់ ហើយក៏បានចាប់ប្តីខ្ញុំទាត់ធាក់ វាយនឹងស្នាយកាំភ្លើង ឈាមហូររហាម។ យប់ម៉ោងប្រាំបី ពួកខ្មែរក្រហមមួយក្រុមទៀតបានមកដល់ ហើយបានប្រាប់ថាក្រុមគ្រួសារទាំងប៉ុន្មានត្រូវចេញឲ្យអស់ ព្រោះត្រូវការរៀបចំក្រុង។ ពេលនោះខ្ញុំបានអង្វរខ្មែរក្រហមថា *"ចាំភ្លឺទើបចាកចេញ ឥឡូវនេះយប់ហើយ"*។ ពួកវាថា *"អត់ទេ ត្រូវតែចេញ! អ្នកឯងចេញភ្លាម! បើមិនចេញទេ យើងត្រូវតែកម្ទេចចោលឲ្យអស់ឥឡូវហើយ"*។ យើងបានចាកចេញពីកន្លែង នោះទាំងបង្ខំទៅតាមផ្លូវមុនីវង្ស។

អស់រយៈពេលបីថ្ងៃ ទើបយើងធ្វើដំណើរដល់វត្តព្រែកឯង ហើយបានសម្រាកទីនោះមួយយប់។ ព្រលឹមឡើង គ្រួសារខ្ញុំបានឆ្លងដរម៉ុជ្រោយតាព្រហ្មទៅខាងអរិយក្សត្រ ដើម្បីរកផ្លូវទៅស្រុកកំណើតនៅភូមិកោះដាច់ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល។ ពេលដល់ស្រុកកំណើត យើងទទួលទុក្ខលំបាកណាស់ ព្រោះមិនមានទីជម្រកទេ យកមេឃធ្វើមុងនិងដំបូល ស្បៀងអាហារក៏មិនគ្រាប់គ្រាន់ ៣ថ្ងៃទើបខ្មែរក្រហមបើករបបម្តងបានអង្ករបួនកំប៉ុង។ នៅទីនោះប្រហែលមួយខែ ខ្មែរក្រហមបានកត់ឈ្មោះប្រមូលគ្រួសារអ្នក១៧មេសា ដើម្បីទៅនៅកន្លែងផ្សេង។ ខ្ញុំបានអង្វរខ្មែរក្រហមថាសុំនៅទីនេះ ព្រោះជាស្រុកកំណើត តែគេមិនអនុញ្ញាតទេ ហើយប្រាប់ថាប្រជាជន១៧មេសាមិនអាចរស់នៅជាមួយអ្នក១៨មេសាបានទេ។ បន្ទាប់មក នៅថ្ងៃមួយ ម៉ោង១២យប់ គ្រួសារ១៧មេសាត្រូវបានគេហៅឈ្មោះឡើងកាណូត កប៉ាល រួចចាកចេញទៅ។ ពេលដល់ចំណត យើងមិនដឹងថាយើងកំពុងស្ថិតនៅទីណានោះទេ។ បន្ទាប់មក ខ្មែរក្រហមបានដឹកយើងតាមឡានទ្រុងបន្តដំណើរទៅមុខទៀត។ ទីបំផុត ខ្មែរក្រហមបានដឹកគ្រួសារខ្ញុំទៅទំលាក់នៅសហករណ៍ស្វាយស ខេត្តពោធិសាត់។ នៅទីនោះ យើងជួបការលំបាកកាន់តែខ្លាំងឡើង ស្បៀងអាហារមិនគ្រប់គ្រាន់ និងគ្មានទីជម្រក។ ពួកខ្មែរក្រហមបានចាត់តាំងប្តីខ្ញុំឲ្យទៅភ្ជួរស្រែចំនួនបីលើក តែគាត់បានបាត់ខ្លួនពេលទៅភ្ជួរលើកទីបី។ ប្រហែល២ខែក្រោយមក ខ្ញុំបានឮថាប្តីខ្ញុំត្រូវបានគេយកទៅរៀនសូត្របាត់ហើយ ព្រោះខ្មែរក្រហមចោទថាគាត់ជាទាហានស័ក្តិប្រាំ ធ្វើឲ្យចិត្តខ្ញុំរន្ធត់យ៉ាងខ្លាំង។ ក្រោយមក កូនប្រុសខ្ញុំបានឈឺស្លាប់ដោយសារភាពអត់ឃ្លាន និងមិនមានថ្នាំសម្រាប់ព្យាបាល វាបានស្រែកដង្ហោយរកបាយហូបមុននឹងដាច់ខ្យល់ស្លាប់ថា *"ម៉ាក់ កូនឃ្លានបាយណាស់ កូនសុំបាយមួយម៉ាត់មក កូនឃ្លានណាស់"* ខ្ញុំឈឺចាប់ណាស់ពេលឮសម្តីកូនបែបនេះ មិនដឹងបានអ្វីឲ្យកូនហូប ព្រោះរបបអាហារដែលខ្មែរក្រហមបើកឲ្យមានតែគ្រាប់ពោតមួយស្លាបព្រា និងគ្រាប់សណ្តែកមួយស្លាបព្រាប៉ុណ្ណោះ។ បន្ទាប់មក ខ្ញុំបានដំណឹងថាម្តាយខ្ញុំដែលនៅកងកុមារបានធ្លាក់ខ្លួនឈឺធ្ងន់ ខ្ញុំបានសុំគេទៅមើលម្តាយ តែគេមិនអនុញ្ញាតសោះ ហើយបានប្រាប់ថា *"មិត្តឯងចេះដឹងអី មានពេទ្យមើលថែរក្សាហើយ មិត្តឯងគិតតែខំបំពេញពលកម្មទៅ"*។ នៅពេលម្តាយខ្ញុំស្លាប់ គេមិនឲ្យចូលទៅជិតទេ គេថា *"មិត្តឯងកុំមករញ៉េរញ៉ៃកន្លែងនេះ ព្រោះមានអ្នកថែរក្សាមន្ទីរពេទ្យនេះយកទៅចោលហើយ ត្រឡប់ទៅវិញទៅ"*។ លុះក្រោយមកទៀត ខ្មែរក្រហមបានបង្ខំឲ្យខ្ញុំរៀបការប្តីថ្មីទៀត តែខ្ញុំមិនព្រម។ ព្រោះតែការបដិសេធរបស់ខ្ញុំ ទើបខ្ញុំត្រូវបានគេវាយដំធ្វើបាប និងបញ្ជូនទៅដាក់គុក។

# MRS. PO DINA

*Mrs. Po Dina, 60 years old, was born in Mukh Kampoul district, Kandal province. She is a Civil Party in Case 002 who testified before the Extraordinary Chambers in the Courts of Cambodia (ECCC) on 30 May 2013.*

Before 17 April 1975, my husband and I were working in the Thailand Embassy located northeast of the Royal Palace. When the Khmer Rouge arrived and asked for the householder again and again, we told them that we were not the owner of this place but the Khmer Rouge did not believe us, and came to destroy everything inside the house. They held up my husband to kick and hit him with a rifle, which caused him to bleed. During night, another group of the Khmer Rouge arrived and told us that all the families had to move because they needed to prepare the city. At that moment, I begged the Khmer Rouge, *"let me wait until tomorrow to move, now it is nighttime"*. The Khmer Rouge replied, *"No, you have to move now! You have to leave immediately! If you do not move, we have to smash you all immediately"*.

We left forcibly from this place to Monivong Street. Three days later, we reached Prek Eng pagoda and stayed there for one night. In early morning, my family took a ferry to Ariy Ksat side in order to find way to the homeland, which situated in Koh Dach village, Koh Dach commune, Mukh Kampoul district, Kandal province. When we arrived in the homeland, we had difficulty because there was no shelter to stay, we considered the sky as our mosquito net and roof. We also did not have enough food to eat because in the period of three days the Khmer Rouge only offered a food portion one time - only four cans of husked rice.

Living there for about a month, the Khmer Rouge listed down the names of 17 April people's families, in order to move them to another place. I begged the Khmer Rouge to let me live in there because it was my homeland, but they refused and said that the 17 April people could not live with the 18 April people. One night, the 17 April people's families were called their names to be taken on motor driven boat and shipped away. When boats and ships landed, we did not know where the place was. The Khmer Rouge then loaded us on a truck to move on. Finally, the Khmer Rouge dropped my family at Svay Sor co-operative, Pursat province. Over there, we faced more difficulty, with not enough food and no shelter to stay. The Khmer Rouge assigned my husband to plow three times in the rice field, but he disappeared while plowing on the third time. About two months later, I heard that my husband was taken for re-education because the Khmer Rouge alleged that he was a colonel. It made me very fearful.

After that, my son became ill and died from starvation and because there was no medicine for treatment. He shouted for cooked rice to eat before he died, saying, *"Mother, I feel hungry, may I have a mouthful of cooked rice, I am very hungry"*. I felt pain when I heard my son say this and I was unable to offer anything for him to eat because the food portion offered by the Khmer Rouge was only a spoon of corn and a spoon of bean. Later, I heard that my mother who lived in the children's unit was seriously ill. I asked permission from Khmer Rouge to see my mother but they refused, and said that, *"None of your business, there is a doctor to see her, you think only of your work"*. When my mother died, the Khmer Rouge did not allow me come close to her dead body, they said, *"do not come to this place, because there are the keepers of hospital bringing her dead body to throw away, go back"*. After that, the Khmer Rouge forced me to remarry but I refused. Because of my denial I was mistreated and sent to prison.

# លោក ចៅ នី



*លោក ចៅ នី កើតក្នុងឆ្នាំ១៩៥៣ មានស្រុកកំណើតនៅស្រុកស្វាយទង ខេត្តអាយ៉ាង (ខ្មែរកម្ពុជាក្រោម)។ លោក បានចាកចេញពីខ្មែរកម្ពុជាក្រោមមករស់នៅក្រុងភ្នំពេញក្នុងឆ្នាំ១៩៧០។ លោក គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងសំណុំរឿង០០២ និងជាអ្នកដែលបានចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ និងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣។*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនៅផ្ទះបងប្រុសខ្ញុំនៅក្រោយផ្សារអូរឡាំពិក ហើយបានឃើញមនុស្សជាច្រើនបានអបអរសាទរចំពោះជ័យជំនះរបស់កងទ័ពខ្មែរក្រហម។ បន្ទាប់មក ពួកខ្មែរក្រហមបានប្រកាសតាមមីក្រូឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ។ បន្តិចក្រោយមក ខ្ញុំបានឮសម្លេងផ្ទុះអាវុធ លាយឡំនិងសម្លេងមនុស្សស្រែករកបងប្អូន កូនចៅ។ មួយសន្ទុះក្រោយមកទៀត ពួកទាហានខ្មែរក្រហមបានមកដល់ផ្ទះបងប្រុសខ្ញុំ ហើយក៏ស្រែកថា *"ពួកឯងម្តេចក៏យូរម្លេះ នៅបន្តិចទៀតយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកងាប់អស់ជាមិនខាន ចេញតែបីថ្ងៃទេ មិនចាំបាច់យករបស់របបទៅជាមួយទេ"*។ និយាយចប់ ពួកវាបានយកចុងកាំភ្លើងមករុញបងប្រុសខ្ញុំឲ្យចេញពីផ្ទះ។ ភ្លាមៗនោះ ខ្ញុំក៏បានស្ទុះចូលក្នុងផ្ទះដើម្បីយករបស់របរបន្តិចបន្តួចដាក់តាមខ្លួន ដើម្បីចាកចេញ។ ខ្ញុំនិងគ្រួសារបងប្រុស (ប្រពន្ធ និង កូនពីរនាក់) បានចាកចេញពីភ្នំពេញតាមផ្លូវជាតិលេខ២ ដើម្បីទៅស្រុកកំណើតនៅខ្មែរកម្ពុជាក្រោម។ យើងបានដើរអស់រយៈពេលប្រហែល១០ថ្ងៃ ទើបទៅដល់ភូមិត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។ ពេលស្នាក់នៅទីនេះ មានគេប្រាប់ខ្ញុំថា *"អ្នកដែលមកពីកម្ពុជាក្រោម នឹងត្រូវសម្លាប់ចោល ពេលទៅដល់ព្រំដែន"* ព្ធដូច្នេះ ខ្ញុំបានសម្រេចចិត្តរស់នៅក្នុងភូមិត្រពាំងសាបនេះ។ ខ្ញុំបានលាក់ប្រវត្តិរបស់ខ្លួនដែលជាខ្មែរក្រោម ហើយក៏បានប្តូរនាមត្រកូលរបស់ខ្លួនផងដែរ។ នៅទីនោះ ខ្ញុំត្រូវបានគេ ចាត់ទុកថាជាអ្នក១៧មេសា និងពួកនាយទុន។

ប្រហែល១០ថ្ងៃក្រោយមក ពួកខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំ និងអ្នក១៧មេសាផ្សេងទៀតឲ្យទៅនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ពេលទៅដល់ទីនោះ អ្នក១៧មេសា ត្រូវបានដឹកបន្តដោយរទេះគោទៅកាន់សហករណ៍រៀងៗខ្លួន ខណៈនោះគ្រួសារខ្ញុំត្រូវបានគេយកទៅដាក់នៅសហករណ៍ចកធំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ នៅទីនោះ ខ្មែរក្រហមឲ្យយើងហូបបបររាវបន្តិចបន្តួចតែប៉ុណ្ណោះ។ ស្នាក់នៅទីនេះបាន ៤ ទៅ ៥ ខែ ក្មួយប្រុសខ្ញុំម្នាក់ អាយុ៨ឆ្នាំ បានធ្លាក់ខ្លួនឈឺស្គមរីងរៃ ដោយសារគ្មានអាហារគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល ហើយក៏បានស្លាប់។ មួយរយៈក្រោយមកទៀត ក្មួយប្រុសខ្ញុំម្នាក់ទៀត អាយុ៥ឆ្នាំ ក៏បានស្លាប់ផងដែរ។ នៅដើមឆ្នាំ១៩៧៧ បងប្រុសខ្ញុំបានធ្លាក់ខ្លួនឈឺធ្ងន់រហូតដល់ស្លាប់ ដោយសារការបង្ខំឲ្យធ្វើការធ្ងន់ ការបង្អត់អាហារ និងមិនមានថ្នាំព្យាបាល។ មុនគាត់ដាចខ្យល់ស្លាប់ គាត់បានអង្វរថា *"ឲ្យសុំហូបបាយមួយម៉ាត់មក និងស្ករត្នោតមួយម៉ាត់មក"* មិនទាន់បានហូបផង គាត់ក៏ដាច់ខ្យល់ស្លាប់បាត់ទៅ។ រីឯបងស្រីខ្ញុំ បានកើតមានជំងឺវិបត្តិផ្លូវចិត្ត ហើយចេះតែទ្រាំរស់ជាមួយកូនប្រុសដែលទើបកើតក្នុងទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរ រហូតដល់បែករបបខ្មែរក្រហម។ គាត់បានស្លាប់ដោយសារជំងឺវិបត្តិផ្លូវចិត្តនៅឆ្នាំ១៩៨៩។

# MR. CHAU NY

*Mr. Chau Ny was born in 1953 at Svay Torng district, Ang Yang province, Vietnam (Khmer Kampuchea Krom area). He left from Khmer Kampuchea Krom area to live in Phnom Penh city in 1970. He is a Civil Party in Case 002 who testified before the Trial Chamber in the Extraordinary Chambers in the Courts of Cambodia (ECCC) on 23 November 2012 and 23 May 2013.*

At 9am on 17 April 1975, I was in my brother's house at Olympic Market and saw people welcoming the victory of the Khmer Rouge soldiers. The Khmer Rouge announced through loudspeakers that the people were ordered to leave from Phnom Penh city. Later, I heard gunfire mixed with the screams of people trying to find their relatives. The Khmer Rouge soldiers arrived at my brother's house and shouted, *"Why you all are late, the American aircraft will bomb everyone dead, so you have to move for only three days, no need to bring belongings with you"*. They pushed my brother with their bayonets to leave. I rushed inside my brother's home to take small belonging with me. My brother's family (his wife and 2 children) and I left from Phnom Penh through National Road No. 2 in order to go to our homeland in the Khmer Kampuchea Krom area.

When arriving in Trapaing Sab village, Bati district, Takeo province, I was told that *"the people who are from Khmer Kampuchea Krom will be killed, if they reach the border"*. Hearing this, I decided to live in Trapaing Sab village by concealing my background as Khmer Kampuchea Krom people and changed my family's name. I was considered as the *"17 April people"* and capitalist people. About ten days later, the Khmer Rouge sent the 17 April people, including my family, to live in Maung Russey district, Battambang province. Upon arriving there, the 17 April people kept going on the oxcarts to other cooperatives individually, but my family was sent to live in Chak Thom cooperative, Maung Russey district, Battambang province.

At the Chak Thom cooperative, the Khmer Rouge offered us only small portions of watery porridge to eat. After staying there for about four or five months, my nephew, 8 years old, became ill and skinny due to the insufficient food and no medicine for treatment died. A while later, another nephew of mine, only 5 years old, died as well. At the beginning of 1977, my brother became ill and died because he was forced to work hard while deprived of food, and was not given any medicine for treatment. Before dying, he begged, *"let me eat a mouthful of cooked rice and a mouthful of palm sugar"* but we could not find these things for him to eat before he passed away. After that, my sister became mentally ill and lived miserably with her newborn baby until the fall of the Khmer Rouge regime. She died of mental disease in 1989.



*លោក មឿន ច័ន្ទសុខា កើតថ្ងៃទី១២ ខែតុលា ឆ្នាំ ១៩៥៧ នៅសង្កាត់លេខ២ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។*

*Mr. Moeun Chan Sokha, born on 12 October 1957, at Sangkat No.2, Phnom Penh, Cambodia.*

# ជីវប្រវត្តិលោក មឿន ច័ន្ទសុខា

## លោក មឿន ច័ន្ទសុខា ជាអ្នកគូរគំនូរទាំងអស់ដែលមានក្នុងសៀវភៅនេះ លើកលែងតែគំនូរមួយផ្ទាំងដែលនៅគ្របខាងក្រោយ

ខ្ញុំមានបទពិសោធន៍លើការងារគូរគំនូរតាំងពីឆ្នាំ១៩៩៣ រហូតដល់សព្វថ្ងៃ។ ខ្ញុំបានចូលចិត្តគូរគំនូរតាំងពីអាយុ ៦ឆ្នាំមកម្លេះ។ ទោះបីជា ខ្ញុំរៀននៅសាលា ឬធ្វើការអ្វីក៏ដោយ ក៏ខ្ញុំនៅតែឆ្លៀតឱកាសគូររូបដោយខ្មៅដៃ, ពណ៌ទឹក ឬពណ៌ប្រេង។ សូម្បីនៅសម័យខ្មែរក្រហមដ៏ហត់នឿយ ក៏ខ្ញុំនៅតែឆ្លៀតគូរដីលេងនៅពេលខ្លះដែរ។

រូបភាពនៅក្នុងសៀវភៅនេះ គឺខ្ញុំបានគូរដោយស្រមៃទៅរកទិដ្ឋភាពដែលខ្ញុំធ្លាប់បានជួប និងឃើញផ្ទាល់ភ្នែក នៅសម័យខ្មែរក្រហម។ ខ្ញុំក៏ជាជនរងគ្រោះម្នាក់ដោយសាររបបខ្មែរក្រហមផងដែរ ព្រោះថាខ្ញុំបានបាត់បង់សាច់ញាតិចំនួនបីនាក់ក្នុងរបបនោះ មាន ឪពុក (បានស្លាប់ដោយសារជម្ងឺ) ប្អូនប្រុស (បានស្លាប់ដោយសារជម្ងឺ) និងបងប្រុស (ត្រូវបានខ្មែរក្រហមសម្លាប់)។

ខ្ញុំបានរៀបការក្នុងឆ្នាំ១៩៧៨ និងមានកូនចំនួនបីនាក់ (ស្រី២នាក់ និងប្រុស១នាក់)។

# BIOGRAPHY OF MR. MOEUN CHAN SOKHA

## Mr. Moeun Chan Sokha who painted the pictures for the front cover and each chapter inside this storybook

Mr. Moeun Chan Sokha, born on 12 October 1957, at Sangkat No.2, Phnom Penh, Cambodia.

I have been a painter since 1993. I liked to draw pictures since I was 6 years old. Whether I was at school or at work, I always used any opportunity to draw pictures with my pencil. Even during the Khmer Rouge regime, I managed to use some of my time to draw pictures.

I painted the pictures in this storybook based on my recollection of what I experienced and saw with my own eyes during the Khmer Rouge regime. I am a victim of the Khmer Rouge regime as well, because I lost three relatives including my father, who died because of illness, my younger brother, who died from a disease, and my older brother, who was killed by the Khmer Rouge. I got married in 1978 and have three children, two daughters and one son.

# ជីវប្រវត្តិលោក វ៉ាន់ ណាត

## លោក វ៉ាន់ ណាត គឺជាអ្នកគូរគំនូរមួយផ្ទាំងដែលស្ថិតនៅគ្របខាងក្រោយនៃសៀវភៅនេះ

លោក គឺជាអតីតអ្នកទោសគុកទួលស្លែង (មន្ទីរសន្តិសុខ ស-២១) ម្នាក់ក្នុងចំណោមអ្នករស់រានមានជីវិតប្រាំពីរនាក់ក្រោយរបបខ្មែរក្រហម។ មានអ្នកទោសជាងមួយម៉ឺនបួនពាន់នាក់ត្រូវបានធ្វើទារុណកម្ម និងបានបាត់បង់ជីវិតយ៉ាងអាណោចអាធ័មនៅគុកនោះ។ ក្រោយរបបខ្មែរក្រហម លោកបានចំណាយពេលវេលាជាច្រើន ដើម្បីគូរគំនូរស្តីអំពីជីវិតជនរងគ្រោះ និងអំពើឃោរឃៅដែលបានកើតឡើងក្នុងមន្ទីរ ស-២១ ក្នុងគោលបំណងបង្ហាញទៅកាន់សាធារណជន រួមទាំងមនុស្សជំនាន់ក្រោយឲ្យបានដឹង និងដើម្បីជាការឧទ្ទិស និងការគោរពដល់ជនរងគ្រោះនៃមន្ទីស-២១។ លោកបានខិតខំចូលរួមក្នុងការស្វែងរកយុត្តិធម៌នៅចំពោះមុខសាលាក្តីខ្មែរក្រហម ដោយបានចូលផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីសម្រាប់សំណុំរឿង០០១ ដែលកាត់ទោសប្រធានមន្ទីរ ស-២១ «ឌុច» ។ តែអកុសល លោកពុំមានឱកាសបានឃើញសាលក្រមកាត់ទោសឌុចឡើយ ព្រោះលោកបានទទួលអនិច្ចកម្មនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១ ដោយបន្សល់ទុកនូវស្នាដៃគំនូរទាំងនោះសម្រាប់អ្នកជំនាន់ក្រោយបានយល់ដឹង។ ទង្វើរបស់គាត់បានបង្ហាញពីសេចក្តីក្លាហាន និងវីរភាពក្នុងនាមជាជនរងគ្រោះម្នាក់ក្នុងការស្វែងរកយុត្តិធម៌ លើកតំលៃជនរងគ្រោះ ផ្សព្វផ្សាយពីការឈឺចាប់របស់ជនរងគ្រោះ និងទប់ស្កាត់មិនឲ្យមានសោកនាដកម្មដូចនៅក្នុងសម័យខ្មែរក្រហមកើតមានសារជាថ្មី។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់គ្រួសាររបស់លោក វ៉ាន់ ណាត ដែលបានអនុញ្ញាតឲ្យប្រើប្រាស់គំនូរមួយផ្ទាំងដែលបានគូរដោយលោក វ៉ាន់ ណាត សម្រាប់ដាក់នៅគ្របខាងក្រោយសៀវភៅនេះ។

# BIOGRAPHY OF MR. VANN NATH

## Mr. Vann Nath is a former prisoner at Tuol Sleng prison, also known as "Security Center S-21". He painted a picture on the back cover of this book.

He is one of seven people who survived imprisonment at S-21 during the Khmer Rouge Regime, a place where more than 14,000 prisoners were tortured and mournfully lost their lives. After the Khmer Rouge regime, he spent most of his time drawing pictures about the brutal acts that occurred at S-21 and the living conditions of the victims there. He wanted the public to know what happened, preserve his memories for the next generation and express his dedication and respect to the victims of S-21 Security Center. Furthermore, he made efforts to seek justice before the ECCC and testified as a witness in Case 001 that prosecuted "Duch", the former Chairman of S-21 Security Center.

Sadly, Mr. Vann Nath did not have the chance to witness the judgment sentencing "Duch" to life imprisonment, because he passed away on 05 September 2011, leaving behind his paintings as a legacy to the next generation. His acts have demonstrated courage and heroism as a victim seeking justice, epitomizing the victim's value, raising awareness about the victim's suffering, and contributing to the prevention of such atrocities from happening again in the future.

Finally, we would like to thank Mr. Vann Nath's family who contributed a picture painted by Mr. Vann Nath to be put on the back cover of this book. "

# ប្រភពឯកសារ

- ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាឆ្នាំ២០០១ (ធ្វើវិសោធនកម្មឆ្នាំ២០០៤)
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ២០០៣)
- ក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ២០០៧)
- វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨)
- ប្រតិចារឹកសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលសវនាការ
- គេហទំព័ររបស់ អ.វ.ត.ក: www.eccc.gov.kh

# REFERENCE SOURCES

- Law on the establishment of the Extraordinary Chambers in the Courts of Cambodia 2001 (amended 2004).
- Agreement Between the United Nations and the Royal Government of Cambodia Concerning the Prosecution under Cambodian Law of Crimes committed during the period of Democratic Kampuchea (2003)
- Cambodian Code of Criminal Procedure (2007)
- Internal Rule of the Extraordinary Chambers in the Courts of Cambodia (Revision 8)
- Transcripts of Civil Party Oral Testimony
- ECCC's website: www.eccc.gov.kh

សហការរៀបចំដោយ | CO-ORGANIZED BY

CHRAC

សមាគមអាដហុក
ADHOC

ឧបត្ថម្ភមូលនិធិដោយ | FUNDED BY

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

zfd Ziviler Friedensdienst
Civil Peace Service



គូរដោយលោក វ៉ាន់ ណាត | Painted by Mr. **Van Nath**